Websites: WatKhemaraRatanaram.org or WatKhmers.org

# ពុទ្ធប្បវត្តិកថា

បណ្ឌិត ឈឹម-សុមន៍

សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់

ប្រវត្តិទី១ នៃព្រះពុទ្ធសាសនា



បណ្ណាគារ សុមនសុវត្ថិ លេខ៤២
វិថីកេង-វ៉ា (មុខសាលាតេជោដំរិន)

ឧទ្ទិសដល់
ពុទ្ធសាសនិកជនក្នុងសកលកម្ពុជរដ្ឋ

# អារម្ភកថា

Websites: WatKhemaraRatanaram.org or WatKhmers.org

រឿងពុទ្ធប្បវត្តិ ដែលជាពុទ្ធភាសិត ក្នុងគម្ពីរព្រះត្រៃបិដក ជាសេចក្តីខ្លីៗ ឆ្លុកដោយដុំ ដោយអន្លើ, ក្នុងអដ្ឋកថា ទើបឃើញមាន សេចក្តីពិស្តារ, ប៉ុន្តែក៏មិនជាហូរហែប៉ុន្មានដែរ ។ ក្នុងជំនាន់ខាងក្រោយ មក ព្រះគន្ថរចនាចារ្យទាំងឡាយ បានតែងមករណវិសេស ជាច្រើន ដូចយ៉ាងគម្ពីរ ជិនមហានិទាន និងគម្ពីរបឋមសម្ពោធិជាដើម, នោះទើបមាន សេចក្តីពិស្តារទាក់ទងគ្នាល្អ ។ តមកទៀត ពួកអ្នកសិក្សាបានបំប្រួញសេចក្តី ពីរឿងដែលពិស្តារទាំងនោះឱ្យជាសេចក្តីខ្លីៗ ហៅថា រឿងពុទ្ធប្បវត្តិ ។ ឯពាក្យថា ពុទ្ធប្បវត្តិនេះ ស្រុបសេចក្តីវែងឆ្ងាយណាស់ គឺជំណាលពីរឿង ព្រះពុទ្ធជាម្ចាស់យើង តាំងពីផ្តើមកសាង ដរាបដល់បានត្រាស់ ចូលនិព្វាន និងសាសនារបស់ព្រះអង្គ រហូតមកដល់សព្វថ្ងៃនេះ ។ សេចក្តី ពុទ្ធប្បវត្តិដែលបំព្រួញទាំងនេះ ច្រើនតែសរសេរបម្លង តៗគ្នា ពុំសូវ ទៀងទាត់ ជាហេតុឱ្យលំបាកដល់ការសិក្សា នៃសិក្ខាកាមកុលបុត្រទាំង ឡាយ ក្នុងកម្ពុជរដ្ឋ ។ ដោយហេតុនេះបានជាខ្ញុំ ខំឆ្លៀតដកគម្ពីរ ជិនមហានិទាន (ភាសាបាលី) និងគម្ពីរបឋមសម្ពោធិ (ភាសាសៀម) និង ព្រះត្រៃបិដកខាងវិន័យខ្លះ ខាងព្រះសូត្រខ្លះ ព្រមទាំងអដ្ឋកថា និង បករណ-វិសេស ឯទៀតខ្លះ ដែលសំដែងពីរឿងនេះមកធៀបគ្នា បំព្រួញសេចក្តី រៀបរៀងបាន ជាសៀវភៅមួយឈុតនេះឡើង មាន៣ភាគគឺ: ពុទ្ធប្បវត្តិកថានេះ ដែលសំដែងពីរឿងព្រះពុទ្ធជា ម្ចាស់យើង តាំងពីបឋម-កប្ប ដរាបដល់បានត្រាស់ ចូលនិព្វាន១, សង្គីតប្បវត្តិ សំដែងពី បឋម សង្គាយនា ដល់បញ្ចមសង្គាយនា១, ពុទ្ធឃោសប្បវត្តិ សំដែងពីរឿង

ព្រះពុទ្ធឃោសាចារ្យ ដែលប្រែព្រះត្រៃបិដក ពីភាសាសីហឡ: មកជាភាសា
Websites: WatKhemaraRatanaram.org or WatKhmers.org
បាលី ដែលរាប់ជាសង្គាយនាទី៦, និងសង្គាយនាតៗមកទៀតខ្លះ រហូតដល់មកឧត្តមសង្គាយនា ឬ ឧត្តមសង្គីតិ ក្នុងកម្ពុជរដ្ឋដែលខ្ញុំអាចដឹងបាន នោះ១, ទាំងបីភាគនេះជាសៀវភៅមួយក្រុម ផ្នែកខាងពុទ្ធប្បវត្តិ ។ ភាគទី៣ គឺពុទ្ធឃោសប្បវត្តិ នោះ ពុទ្ធសាសនាបណ្ឌិត្យ បានបោះពុម្ពចូលក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ១៩៤៣ម្តងហើយ ខ្ញុំនឹងយកមកកែបន្ថែម បោះពុម្ពតទៅទៀត ។ ភាគទី១ គឺពុទ្ធប្បវត្តិកថានេះ ខ្ញុំបានបោះពុម្ពម្តង ពី ព.ស. ២៤៩២, ដល់មក ព.ស.២៤៩៤ នេះខ្ញុំបានជូនលោក ប៊ូ-ប៉ូ ជួយកែហើយ ខ្ញុំប្រគេន ព្រះតេជគុណព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុម្ភាជ សូមឱ្យលោកយកទៅពិគ្រោះ ពិនិត្យកែជាថ្មីទៀត ក្នុងសំណាក់សម្ដេចព្រះមហាសុមេធាធិបតី (ជួន ណាត) សង្ឃនាយកគណៈមហានិកាយ ។ សម្ដេចបានពន្យល់ឱ្យកែ ព្រមទាំងពិនិត្យឃើញថាត្រឹមត្រូវជាងមុន ទើបខ្ញុំយកមកបាត់ការបោះពុម្ពលើកទីពីរនេះទៀត សម្រាប់ការសិក្សាក្នុងសាលាបាលីរង និងសាលាធម្មវិន័យនៃកម្ពុជរដ្ឋ ។

ដោយអានុភាពនៃសេចក្តីព្យាយាមនេះ សូមសេចក្តីសុខចំរើនកើតឡើងដល់ខ្ញុំផង ដល់ក្រុមពុទ្ធបរិស័ទដែលបានសិក្សានូវរឿងនេះផង ។

សូមព្រះពុទ្ធសាសនា ថ្កើងរុងរឿងអស់កាលជាអង្វែងទៅហោង ។

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំថោះ ត្រីស័ក ព.ស.២៤៩៤

**ស៊ុមន៍**

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ **ប៊ិន សុផល**
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក **ជ្រុន ចន្ធី**

# ពុទ្ធប្បវត្តិកថា

## បណាមគាថា

តថាគតំ   ជិនំ   ពុទ្ធំ   សុទ្ធវិសំ   ជិនុត្តមំ
បារគុំ   សព្វធម្មានំ   នត្វា   បាបុបឃាតកំ
វក្ខាមិ   តស្ស   ពុទ្ធស្ស   ជនកានំ   មនោហរំ
វិសំ  វិសុត្តមំ  ធេយ្យំ  បីតិបាមោជ្ជវឌ្ឍនំ  ។

ខ្ញុំព្រះករុណាឈ្មោះសុមនាចារ្យ នត្វា សូមក្រាបថ្វាយបង្គំប្រណម្យចំពោះព្រះពុទ្ធតាគតជិនស្រី ទ្រង់មានព្រះវង្សដ៏បរិសុទ្ធឧត្តមជាងអ្នកប្រាជ្ញទាំងឡាយ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គសម្លាប់បង់នូវបាប ហើយខ្ញុំនឹងថ្លែង សំដែងនូវព្រះនាមព្រះវង្សដ៏ឧត្តម ដែលជាប់តៗគ្នាមក នៃព្រះពុទ្ធជាម្ចាស់អង្គនោះ ជាទីនាំមកនូវទឹកចិត្ត ជាទីញ៉ាំង បីតិនឹងបាមោជ្ជឱ្យចំរើនឡើងដល់ជនានុជនទាំងពួង ។

### ទូរេ និទាន

បុព្វេ   កិរ   គវេសន្តោ   ពោធិញ្ញាណំ   នរាសភោ
ទិជោ ហុត្វា មហាភោគោ សុមេធបណ្ឌិតវ្ហយោ ។

បានឮមកថា កាលពីព្រេងនាយ ព្រះសម្មាសម្ពុទ្ធជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ **ប៊ិន សុផល**
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក **ជ្រុន ចន្ធី**

Websites: WatKhemaraRatanaram.org or WatKhmers.org

នរាសភៈ កាលព្រះអង្គស្វែងរកនូវពោធិសញ្ញាណ ព្រះអង្គទ្រង់យោនយកកំណើតកើតជាព្រាហ្មណ៍ ព្រះនាមសុមេធបណ្ឌិត មានទ្រព្យសម្បត្តិច្រើន, បានលះបង់ទ្រព្យសម្បត្តិ ចេញទៅសាងផ្នួសបួសជាតាបសឥសី នៅព្រៃហេមពាន្ត បានសម្រេចឈាននឹងអភិញ្ញា ចរលីលាមកតាមអាកាស បានឃើញបណ្ដាជនមីរដើរដាសកំពុងធ្វើផ្លូវថ្នល់ ដើម្បីព្រះទសពលទ្រង់ព្រះនាមទីបង្ករ ទ្រង់ចេញអំពីវិហារសុទស្សនៈ ចូលទៅកាន់នគរអមរវតី តាបសឫសីក៏បានទទួលនាទីមួយកន្លែង ដើម្បីធ្វើដោយខ្លួនឯង ។ កាលបើផ្លូវថ្នល់នោះពុំទាន់សម្រេចនៅឡើយ, ជួនជាព្រះសម្មាសម្ពុទ្ធទ្រង់និមន្តមក ។ តាបសក្រាលស្បែកខ្លាឃ្មុំលើភក់ ប្រះខ្លួនដេកធ្វើជាស្ពាន និមន្តព្រះទ្រង់ញាណព្រមទាំងសង្ឃជាសាវ័ក ឱ្យជាន់លើខ្លួនឆ្លងភក់នោះទៅ ។ ព្រះសាស្ដាទ្រង់ឆ្លងផុតពីភក់ ហើយទ្រង់ព្យាករថា “ឯស ពុទ្ធង្កុរោ តាបសនេះជាពុទ្ធង្កុបណ្ដូលសារពេជ្ញញាណ អំណោតឹះទៅ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ។

តាំងពីកាលនោះរៀងមកដរាបមក ព្រះពោធិសត្វជាម្ចាស់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

យើងទាំងឡាយ ខំបំពេញបារមីទាំង ៣០ប្រការ ឥតមានសម្រាកឱ្យអាក់ខាន អស់កាលប្រមាណបួនអសង្ខេយ្យ នឹង មួយសែនកប្ប ដរាបមកទល់នឹងភទ្ទកប្បនេះ ។

---

## មហាសម្មតិវង្សបរិច្ឆេទទី ១

ក្នុងកាលជាខាងដើមនៃភទ្ទកប្បនេះ ព្រះបរមពោធិសត្វជាម្ចាស់យើងទាំងឡាយ ទ្រង់កើតជាស្ដេចព្រះនាមមហាសម្មតិទេវរាជ បឋមក្សត្រ សោយរាជសម្បត្តិក្នុងសកល ជម្ពូទ្វីបនេះ, ទ្រង់មានព្រះរាជឱរសព្រះនាមរោជរាជ, ព្រះបាទរោជរាជនោះមានព្រះរាជឱរសព្រះនាមវររោជរាជ, ព្រះបាទវររោជរាជនោះមានព្រះរាជឱរសព្រះនាមកល្យាណរាជ, ព្រះបាទកល្យាណរាជនោះមានព្រះរាជឱរសព្រះនាមវរកល្យាណរាជ, ព្រះបាទវរកល្យាណ-រាជនោះមានព្រះរាជឱរសព្រះនាមសក្កមន្ធាតុរាជ, ព្រះបាទមន្ធាតុ-រាជនោះ មានព្រះរាជឱរសព្រះនាមសក្កមន្ធាតុ,(១) ព្រះបាទសក្ក-មន្ធាតុនោះមាន ព្រះរាជឱរសព្រះនាមឧបោសថរាជ, ព្រះបាទឧបោសថរាជនោះ មានព្រះរាជឱរសព្រះនាមវររាជ, ព្រះបាទ

---

(១) ព្រះបាទសក្កមន្ធាតុរាជនេះ ដែលក្នុងអដ្ឋកថាធម្មបទសំដែងថា ជាតួអង្គពោធិសត្វម្ចាស់យើង, មានព្រះជន្មបំបួប ៣៦ កត្រតន្ត្រ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

វិរាជនោះ មានរាជឱរសព្រះនាមឧបវិរាជ, ព្រះបាទឧប-វិរាជនោះ មានព្រះរាជឱរសព្រះនាមមឃទេវរាជ បានសោយរាជសម្បត្តិតព្រះវង្សជាលំដាប់មក ។ លំដាប់ពីនោះមកព្រះរាជវង្សានុវង្សបានសោយរាជសម្បត្តិតៗគ្នា ចំនួន ៨៤.០០០ ព្រះអង្គទៀត ទើបដល់មកឱកាកវង្សទាំង៣ព្រះអង្គគឺព្រះបាទបឋមឱកាករាជ, ទុតិយឱកាករាជ, តតិយឱកាករាជ ។ ព្រះបាទតតិយឱកាករាជនេះ មានព្រះមហេសី ៥ ព្រះអង្គគឺ ព្រះនាងហត្ថា១, ព្រះនាងចិត្តា១, ព្រះនាងជន្តុ១, ព្រះនាងជាលិនី១, ព្រះនាងវិសាខា១ ។

ព្រះនាងហត្ថា ដែលជាអគ្គមហេសី មានព្រះរាជបុត្រ៤ព្រះអង្គគឺ ឱកាកមុខរាជកុមារ១, ករណ្ឌរាជកុមារ១, ហត្ថិនិកេ-សីរាជកុមារ១, និបុររាជកុមារ១ នឹងព្រះរាជធីតា៥ព្រះអង្គទៀតគឺ ព្រះនាងបិយារាជកុមារី១, សុបិយារាជកុមារី១, អានន្ទារាជកុមារី១, វិជិតារាជកុមារី១, វិជិតសេនារាជកុមារី១, រួមព្រះរាជបុត្រព្រះរាជធីតាទាំងអស់បាន៩ព្រះអង្គ ។

ក្នុងកាលជាខាងក្រោយមក ព្រះនាងហត្ថាជាអគ្គមហេសីបម្បង់ទ្រង់សោយព្រះទិវង្គត។ ព្រះរាជាទ្រង់លើកមហេសី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទី២ ជាអគ្គមហេសីឡើង ។ ព្រះអគ្គមហេសីថ្មីនេះ បានព្រះរាជបុត្រាមួយព្រះអង្គ បានព្រះជន្ម ៥ខែ ក៏ព្រះនាងនាំទៅគាល់ព្រះវររាជបិតា ។ ព្រះមហាក្សត្រទ្រង់មានព្រះហឫទ័យស្នេហាទ្រង់ត្រាស់ព្រះរាជឱង្ការថា "យើងឱ្យពរនាង នាងប្រាថ្នាអ្វី ចូរឱ្យបានសម្រេចដូចចិត្ត" ។ ព្រះអគ្គមហេសីក៏ទូលសូងព្រះរាជឱង្ការថា "ខ្ញុំម្ចាស់ចង់បានតែរាជសម្បត្តិឱ្យកូននេះ សូមទ្រង់ព្រះរាជទាន ឱ្យបានសម្រេចដូចប្រាថ្នា" ។ ព្រះរាជាក៏ទ្រង់ធ្នក់ក្នុងព្រះឱរាមានព្រះរាជហឫទ័យកន្ទះរា នឹងលៃថាដូចម្ដេចក៏ពុំកើត ទើបត្រាស់ព្រះរាជឱង្ការឱ្យព្រះរាជបុត្រទាំង៤ព្រះអង្គមកជួបជុំហើយត្រាស់ថា "ហៃបាទាំងឡាយ! បិតាជ្រុលសំដី នឹងអគ្គមហេសីនេះ, បើដូច្នេះចូរអ្នកទាំងឡាយជួយពិចារណា, តើគួរឱ្យបិតាថាដូចម្ដេចទៅវិញ! ព្រះរាជបុត្រាទាំង៤ព្រះអង្គក្រាបបង្គំទូលថា "ពុំគួរព្រះវររាជបិតាបង់សច្ចៈទេ" ។ព្រះរាជាត្រាស់ថា បើដូច្នោះ មានតែអ្នកទាំងឡាយ ចេញទៅព្រៃសិនចុះ, អ្នកទាំងឡាយចង់បានអ្វី ក៏ជញ្ជូនយកទៅចុះ លើកតែគ្រឿងប្រដាប់សម្រាប់រាជ្យចេញ ។ ព្រះរាជបុត្រាទាំង៤ព្រះអង្គមានឱកាកមុខរាជកុមារជាប្រធាន បានថ្វាយបង្គំលា ព្រះវររាជបិតា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

និងព្រះរាជវង្សានុវង្ស ទ្រង់ព្រះកន្សែងថ្លែងព្រះសំណោកសោកអាល័យ ហើយនាំគ្នាចេញចាករាជបុរី ព្រមទាំងព្រះរាជភគិនីទាំង៥ព្រះអង្គ នឹងបណ្ដាជនប្រុសស្រីចេញទៅតាំងជាច្រើនបន្ដគ្នាអស់មាត្រាបំនួន៣យោជន៍ ក៏ពុំទាន់អស់ពពួកពលនិកាយទាំងនោះផង ។

ព្រះរាជកុមារកុមារីទាំងអស់ ប្រឹក្សាគ្នាថា "ពួកសេនាទាហានមានបំនួនច្រើន បើនឹងទៅច្បាំងដណ្ដើមយកនគរស្ដេចសាមន្តរាជឯណានីមួយក៏បាន, ប៉ុន្តែប្រយោជន៍អ្វី ដោយការបៀតបៀនគេដូច្នេះ ហេតុនេះគួរយើងទៅនៅឯព្រៃហេមពាន្តទៅចុះ" ហើយនាំគ្នាសំដៅទៅព្រៃហេមពាន្ត ពិនិត្យរកទីឋានដើម្បីកសាងព្រះនគរថ្មី ។

គ្រានោះព្រះពោធិសត្វជាម្ចាស់យើង កើតក្នុងត្រកូលព្រាហ្មណមហាសាលព្រះនាមកបិលព្រាហ្មណ៍ លះបង់សម្បត្តិចេញទៅសាងផ្នួសបួសជាតាបសឫសីនៅក្នុងអាស្រមមួយ នាសំយាយព្រៃហេមពាន្ត ។ កបិលតាបសនោះចេះស្ទាត់ជំនាញខាងភូមិគលវិទ្យា ស្គាល់គុណនឹងទោសនៃផែនដីសព្វអន្លើបានឃើញភូមិភាគត្រង់កន្លែងនោះជាទីមានជ័យល្អ ព្រោះថា

Websites: WatKhemaraRatanaram.org or WatKhmers.org

បើសត្វសាហាវទាំងឡាយ មានសីហៈនឹងខ្លាជាដើម ដេញម្រឹគទៅក្ដី ឆ្មាដេញកណ្ដុរទៅក្ដី ពស់ដេញកង្កែបទៅក្ដី ដល់ទៅត្រង់កន្លែងនោះ, សត្វដែលឥតអំណាចទាំងនោះ អាចបែរគម្រាមតនឹងសត្វដែលមានអំណាចវិញ, សត្វដែលមានអំណាចក៏រត់ថយបេញទៅទីឯទៀតទៅ ។

កាលបើព្រះរាជកុមារទាំងឡាយ មានឱកាកមុខរាជកុមារជាដើម កំពុងស្វែងរកទីកសាងព្រះនគរ, ក៏ព្រះកបិលតាបសប្រគលទីបណ្ណសាលានោះ ថ្វាយព្រះរាជា ។ ក្សត្រទាំងនោះព្រមទាំងពពួកពលយោធាក៏នាំគ្នាចាត់ការសាងនគរ ហើយតាំងនាមករថា "កបិលវត្ថុបុរី" ដោយហេតុថាទីនោះជាទីអាស្រមរបស់កបិលឥសី ។

តពីនោះមក អាមាត្យ៨នាក់ដែលព្រះបាទឱកាកៈបរមរាជបិតាចាត់មកជារាជបរិវ័ក្ស ដើម្បីមើលការខុសត្រូវនៃព្រះរាជបុត្រាបុត្រីទាំងនោះ ក៏ប្រជុំពិភាក្សាគ្នាថា "ព្រះរាជកុមារកុមារីទាំងឡាយបានចំរើនវ័យវឌ្ឍនាការគ្រប់ព្រះអង្គហើយ, គួរយើងរៀបចំធ្វើរាជាភិសេក" ហើយក៏នាំគ្នាទៅក្រាបបង្គំគាល់ទូលស្នើរសេចក្ដីនោះ នឹងព្រះរាជកុមារកុមារីគ្រប់ព្រះអង្គ សម្រេចសេចក្ដី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាត្រូវតាំងព្រះជេដ្ឋភគិនី (ព្រះរាជធីតាច្បង) ក្នុងទីជាព្រះមាតា ត្រូវអភិសេកព្រះរាជកុមារទាំង៤ ព្រះអង្គ ជាគូនឹងព្រះរាជកុមារី ប្រឡូកប្រឡំដោយលោហិតនៃជនដែលមិនបរិសុទ្ធ ។ ព្រះរាជ-វង្សនេះ មាននាមបញ្ញត្តិថា "សក្យរាជវង្ស" បានសោយរាជ-សម្បត្តិ តៗគ្នាមកជាច្រើនផ្លូវក្សត្រ ដរាបដល់ព្រះបាទសិវិរាជ, ព្រះបាទសញ្ជយរាជ និងព្រះបាទវេស្សន្តររាជ ។ ក្នុងសិវិរាជ-វង្សនេះ បានកែប្រែនាម នគរកបិលវត្ថុ ហៅថានគរជេតុត្តរវិញ ។ ព្រះបាទវេស្សន្តររាជ សោយព្រះទិវង្គតទៅ ព្រះរាជឱរស ព្រះនាមជាលី ដែលបានរាជាភិសេកជាមួយនឹងព្រះនាងកណ្ហាជិនា ជាព្រះកនិដ្ឋភគិនី បានសោយរាជសម្បត្តិតរៀងមក មាន ព្រះរាជឱរសព្រះនាម សិវិវាហនៈ, ព្រះបាទសិវិវាហនៈ មានព្រះ រាជឱរសព្រះនាម សីហសររាជ បានសោយរាជ្យ តៗមក ១៦១.០០០ ព្រះអង្គ ទើបដល់មករាជ្យព្រះបាទជយសេន ។ ព្រះបាទជយសេនមានព្រះរាជបុត្រ ព្រះនាមសីហហនុរាជ បាន រាជាភិសេកជាមួយ នឹងព្រះអគ្គមហេសីព្រះនាមនាងកាញ្ចនា ជា កនិដ្ឋភគិនីព្រះបាទអញ្ជនៈ នគរទេវទហៈ ហើយទ្រង់ផ្លាស់

Websites: WatKhemaraRatanaram.org or WatKhmers.org

នាមនគរជាកបិលវត្ថុ វិញ ។ ព្រះបាទសីហហនុមានព្រះរាជបុត្រា ៣(១) ព្រះអង្គគឺ សុទ្ធោទនៈ១ សុក្កោទនៈ១ អមិត្តោទនៈ១ មានព្រះរាជធីតា ២ ព្រះអង្គគឺ ព្រះនាង អមិត្តា១, បមិត្តា១ ។ បំណែកខាងនាង យសោធរារាជបុត្រីព្រះបាទជយសេន បានជាមហេសីព្រះបាទអញ្ជនៈ មានព្រះរាជបុត្រី២ ព្រះអង្គគឺ ព្រះនាងមាយា១, បជាបតី១, រាជបុត្រា ២ ព្រះអង្គគឺ សុប្បពុទ្ធ១ ទណ្ឌបាណិ១ ។

(ចប់មហាសម្មតិវង្សបរិច្ឆេទទី១)

---

## អាវាហបរិច្ឆេទ ទី២

(១) តទា សីហហនុរាជា អភិសេកំ កាតុកាមោ កាលនោះព្រះបាទសីហហនុរាជ មានព្រះរាជហឫទ័យប្រាថ្នានឹងអភិសេកសិរីសុទ្ធោទនរាជកុមារ ទ្រង់ឱ្យអញ្ជើញព្រាហ្មណ៍៨ នាក់មក ទ្រង់ត្រាស់ព្រះរាជបញ្ជាឱ្យទៅស្វែងរកព្រះរាជកញ្ញាប្រកបដោយបញ្ចពិធកល្យាណីនឹងលក្ខណៈ៦៤ប្រការ ទើប

---

(១)ក្នុងបឋមសម្ពោធិថា ៣ ព្រះអង្គ, ពុទ្ធប្បវត្តិប្បាប់ខ្លះថា ៤ ព្រះអង្គ គឺមានពោរតោទនៈ១ ឃនិតោនៈ១ ទៀត។ ពុទ្ធប្បវត្តិរបស់សម្ដេចព្រះមហាសមណៈ (ប៉ៃ) មាននបរលក្ខណៈ ពន្យល់ថា ធោពោទនៈ និងតោទនៈមិនសូវប្រាកដក្នុងបករណ៍ទាំឡាយបានជាក្នុងប្បាប់ខ្លះថា ព្រះរាជបុត្រព្រះសីហហនុមានតែ ៣ព្រះអង្គ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ **ប៊ិន សុផល**
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក **ជ្រុន ចន្នី**

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ៨០០០ កហាបណៈដល់ព្រាហ្មណ៍ព្រមទាំងមណិបិលន្ធនៈហើយផ្តាំថា បើព្រាហ្មណ៍រកបានខត្តិយកញ្ញា, ត្រូវប្រដាប់នូវគ្រឿងប្រដាប់នេះជា សំគាល់ ។ ព្រាហ្មណ៍ទាំង៨នាក់ក៏ទទួលទៅស្វែងរក ។

(២) ក្នុងកាលនោះនាងសិរីមហាមាយា មានមូលបណិធិកុសលកសាងតាំងពីពីសាសនាព្រះពុទ្ធវិបស្សីជរាបមក នាងបានមកកើតជាព្រះរាជធីតា ព្រះបាទអញ្ជនៈជនាធិបរាជ នាងប្រកបដោយបញ្ចពិធកល្យាណីនឹងលក្ខណៈ៦៤ ប្រការមានវ័យវឌ្ឍនាព្រះជន្ម ១៦វស្សា ក្នុងកាលបិត្តមាសបុណ្ណមីខាងដើមគិម្ហរដូវនាងនាំបរិវារស្តេចទៅក្រសាលក្នុងឧទ្យាន ។

(៣) ក្នុងកាលនោះ ព្រាហ្មណ៍ទាំង ៨ នាក់ដែលព្រះបាទសីហហនុរាជត្រាស់ប្រើមក ក៏ដើរស្វែងរកនគរដទៃៗ មិនបាន លុះមកដល់ទេវទហនគរ ក៏ដើរទៅក្នុងឧទ្យានបានឃើញព្រះនាងសិរីមហាមាយា ដែលប្រកបដោយបញ្ចពិធកល្យាណីនឹងលក្ខណៈ ៦៤ប្រការ, ព្រាហ្មណ៍សន្ទនាសាកសួរសព្វគ្រប់ហើយ ក៏ថ្វាយមណិបិលន្ធនៈដល់ព្រះនាង, ទើបទៅកាន់សំណាក់ព្រះបាទជនាធិបរាជ ក្រាបទូលសព្វសេចក្តី ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបាទជនាធិបរាជទ្រង់ព្រមនឹងថ្វាយ ។ ព្រាហ្មណ៍ទាំងឡាយក៏ត្រឡប់ទៅកាន់កបិលវត្ថុបុរី ក្រាបបង្គំទូលសេចក្តីដល់ព្រះបាទសីហហនុរាជសព្វគ្រប់ប្រការ ។

(៤) ក្នុងថ្ងៃដែលព្រាហ្មណ៍មកដល់ បំណែកព្រះបាទសីហហនុរាជទ្រង់ឃើញសុបិននិមិត្តក្នុងវេលារាត្រី ។ ឯសុបិននិមិត្តនោះប្រាកដជាពីរប្រការ គឺទ្រង់ឃើញថា រតនវិមានមួយមានជាន់ ១៨ ផុះឡើងអំពីភូមិភាគក្នុងទីពាក់កណ្តាលជម្ពូទ្វីបទៅដល់ភវគ្គព្រហ្មប្រការ ១ ទ្រង់ឃើញថា មានមហាគង្គាមួយវែងជ្រៅក្រៃពេក ដំដេរដាសដោយរបៀបនៃរលកធំមានអគ្គបុរសមួយនាក់ដែលនៅក្នុងប្រាសាទនោះ តាក់តែងសំពៅនឹងចម្លងនូវសត្វទាំងអម្បាលនោះ អំពីត្រើយអាយទៅកាន់ត្រើយនាយប្រការ១ ។

(៥) ព្រះបាទសីហហនុរាជ កាលបានទ្រង់ព្រះសណ្តាប់ពាក្យព្រាហ្មណ៍ក្រាបបង្គំទូលដូច្នោះ ព្រះអង្គមានព្រះរាជហឫទ័យរីករាយ ទ្រង់បង្គាប់ឱ្យអាមាត្យតាក់តែងមគ្គវិថីអំពីកបិលវត្ថុបុរីទៅដល់ទេវទហនគរ, ព្រះអង្គក៏យាងទៅកាន់ទេវទហនគរ,លុះទៅដល់លុម្ពិនីវ័នឧទ្យាន ក៏ជួបនឹងព្រះបាទអញ្ជនៈជនាធិបរាជស្តេច

Websites: WatKhemaraRatanaram.org or WatKhmers.org

សន្មតាដោយព្រះរាជឱង្ការផ្សេងៗ ទ្រង់ត្រាស់បង្គាប់ជាងការយ៉ាងឯកឱ្យតាក់តែងមហាប្រាសាទនឹងរៀបការអភិសេក ។

តស្មឹ ខណេ ខណៈនោះក៏កម្បុតាការដល់បណ្ឌុកម្ពលសិលាអាសនាសម្តេចអមរិន្ទ្រាធិរាជ ទ្រង់អាវជ្ជនាការជ្រាបច្បាស់នូវហេតុ ទ្រង់បង្គាប់ទៅវិស្សុកម្មទេវបុត្រឱ្យមកនិម្មិតប្រាសាទដ៏ប្រកបដោយគ្រឿងឧបករណ៍ទាំងពួង ។

(៦) ព្រះរាជានឹងខត្តិយវង្សទាំងពីរព្រះនគរ ក៏នាំពួកពលទៅប្រជុំរៀបមង្គលការ អភិសេកព្រះរាជបុត្រាបុត្រីក្នុងប្រាសាទដ៏ប្រសើរជាស្រេចការ ហើយក៏ត្រឡប់ទៅកាន់ ព្រះនគរវិញ ។

ចំណែកខាង ព្រះបាទសិរីសុទ្ធោទនៈនឹងព្រះនាងសិរីមហាមយាទេវី ក៏ឧបដ្ឋាកព្រះជនកព្រះជននីដោយគោរព, ព្រះអង្គប្រតិបត្តិក្នុងបញ្ចង្គិកសីលនឹងទសពិធរាជធម៌ ១០ ប្រការ តាមបុរាណរាជប្បវេណីគ្រប់ប្រការ ។ សីហហនុរាជា ព្រះបាទសីហហនុរាជ ទ្រង់ព្រះជរាទីវង្គតទៅព្រះរាជឱរសនឹងព្រះរាជសុណិសា ខត្តិយវង្ស អមច្ចាមាត្យទាំងពួងក៏រៀបចំធ្វើឈាបនកិច្ច

Websites: WatKhemaraRatanaram.org or WatKhmers.org

បូជាព្រះភ្លើងស្រេចហើយ ព្រះបាទសិរីសុទ្ធោទនទ្រង់សោយរាជសម្បត្តិស្នងព្រះវររាជបិតាជាសុខ ក្សេមក្សាន្តប្រសើរ ។

(ចប់អាវាហបរិច្ឆេទ ទី២)

---

អវិទូរេ និទាន

តុសិតបរិច្ឆេទ ទី៣

(១) បុព្វេ កិរ គវេសន្តោ ពោធិញាណំ នរាសភោ បានឮមកថា ព្រះសម្ពុទ្ធជានរាសភៈនៃយើងទាំងឡាយ កាលស្វែងរកពោធិញ្ញាណ ព្រះអង្គបាននូវពុទ្ធព្យាករណ៍អំពីសំណាក់ព្រះពុទ្ធ ២៤ព្រះអង្គមានព្រះពុទ្ធទីបង្ករជាដើម ព្រះអង្គឧស្សាហ៍បំពេញបារមីធម៌ ៣០ ប្រការ នឹងបរិច្ចាគ ៥ ប្រការ ក្នុងកាលជាបន្ទោះនេះ ដរាបដល់បានពុទ្ធព្យាករណ៍អំពីព្រះពុទ្ធកស្សបជាបរិយោសាន បំនួន ៤ អសង្ខេយ្យនឹង១សែនកប្ប ។

(២) វេបោ សុត្វា ពោធិសត្តោ បសាទេត្វានមត្តនោ ព្រះបរមពោធិសត្តឈ្មោះជោតិបាលភិក្ខុ បានស្ដាប់នូវពុទ្ធព្យាករណ៍នៃព្រះកស្សបសម្មាសម្ពុទ្ធ ក៏តាំងចិត្តនៃខ្លួនឱ្យជ្រះថ្លាឧស្សាហ៍បំពេញនូវបារមីធម៌ លុះច្យុតចាកអត្តភាពនោះហើយ ក៏អន្ទោលទៅក្នុងភពតូចនឹងភពធំ ដរាបមកដល់កើតក្នុងនគរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជេតុត្តរ ទ្រង់នាមប្បញ្ញត្តិជាវេស្សន្តររាជ ។ ព្រះបាទវេស្សន្តរ-រាជ ទ្រង់ព្រះរាជទាននូវសត្តសតកមហាទាន ដល់ពួកយាចក។ តេជានុភាពនៃទានរបស់ព្រះអង្គ អាចញ៉ាំងមហាប្រឹថពីឱ្យញាប់ញ័រ ព្រះអង្គចេញទៅសាងបព្វជ្ជាជាឥសី គង់នៅក្នុងបណ្ណសាលា ទៀបភ្នំគិរីវង្កត ព្រះអង្គបរិច្ចាគព្រះរាជបុត្រាបុត្រីភរិយាជាកំពូលបារមីដល់ព្រាហ្មណ៍ ទើបព្រះអង្គយាងមកគង់ក្នុងព្រះនគរវិញ លុះអស់ព្រះជន្មសោយព្រះទីវង្គតទៅបានទៅកើតក្នុង តុសិតបូរី ទ្រង់ព្រះនាមថា សន្តុសិតទេវបុត្រសោយនូវឥស្សរិយយសដ៏ប្រសើរ ។

(៣) អាយុនោ បរិយោសានេ សន្តុសិតបរមពោធិសត្តព្រះអង្គបិននៅក្នុងតុសិតពិភព លុះអស់ព្រះជន្មប្រមាណ ៤.០០០ ឆ្នាំទិព្វ ត្រូវជា ៥៧ កោដិនឹង ៦០ សែនឆ្នាំមនុស្សក៏ទេវតាដែលបិននៅក្នុងចក្កវាឡទាំងមួយហ្មឺន ចូលទៅអារាធនាដោយពាក្យថា “កាលនេះជាកាលគួរដល់ព្រះអង្គ សូមព្រះអង្គប្បតទៅកើតក្នុងផ្ទៃមាតា បានត្រាស់ដឹងនូវផ្លូវព្រះនិព្វានហើយបម្លង សត្វលោកព្រមទាំងទេវតា ឱ្យរួចបាកវដ្តសំសារៈ” ។

ព្រះបរមពោធិសត្តទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់រមិល

Websites: WatKhemaraRatanaram.org or WatKhmers.org
មើលនូវមហាវិលោកនៈទាំង៥ ប្រការគឺ រមិលមើលនូវកាល១, ប្រទេស១, ទ្វីប១, ត្រកូល១, មាតា១, ទើបឱ្យបដិញ្ញាដល់ទេវតា ហើយបញ្ជូនទេវតាទាំងនោះទៅ ។

(៤) កាលំ ទេសញ្ច ទីបញ្ច កុលំ មាតរមេវ ច ព្រះបរមពោធិសត្វដែលរមិលមើលនូវមហាវិលោកនៈ ទាំង៥ ប្រការនោះ ព្រោះអាស្រ័យហេតុជាធម្មតាថា បើកាលណាសត្វមានអាយុច្រើនជាងមួយសែនឆ្នាំឡើងទៅ ឋយតិចបុះពី ១០០ឆ្នាំមក, កាលនោះព្រះពុទ្ធមិនដែលចុះមកកើតទេ ។ អាយុមនុស្សយ៉ាងច្រើនត្រឹម ១ សែនឆ្នាំ, យ៉ាងតិចត្រឹម ១០០ ឆ្នាំ ទើបព្រះពុទ្ធចុះមកកើតក្នុងលោក ។ ព្រះពោធិសត្វរមិលមើលនូវប្រទេសនោះ ដ្បិតថាព្រះពុទ្ធមិនដែលកើតក្នុងបច្ចន្តប្បទេសទេ, បុគ្គលទាំងឡាយមានយសច្រើនមានព្រះពុទ្ធជាដើមរមែងកើតតែក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ។ ព្រះពោធិសត្វរមិលមើលនូវទ្វីបនោះ ព្រោះទ្វីបទាំង៣ព្រះពុទ្ធមិនដែលកើត តែងកើតតែក្នុងជម្ពូទ្វីបមួយប៉ុណ្ណោះ ។ ព្រះពោធិសត្វរមិលមើលនូវត្រកូលនោះ ដ្បិតថាព្រះពុទ្ធ មិនដែលកើតក្នុងត្រកូលទាប, តែងកើតតែក្នុងត្រកូលពីរគឺ ខត្តិយត្រកូល១ ព្រាហ្មណ-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រកូល១ៗ ព្រះពោធិសត្វរមិលមើលនូវមាតានោះ ដ្បិតថា ស្រីដែលជាពុទ្ធមាតាមិនមែនជាស្រីឡេះឡោះ មិនមែនជាអ្នកលេងសុរាជាដើម, ឯពុទ្ធមាតានោះជាស្រីមានអភិនីហារកសាងមកអំពីអតីតភព មានបារមីធម៌បំពេញគ្រប់១សែនកប្បហើយៗ

(៨) បុតោ សក្កកុលេ តស្មិំ បដិសន្ធិំ គហេសិ សោ សន្តុសិតទេវរាជនោះ រមិលមើលនូវបញ្ចមហាវិលោកនៈស្រេចហើយ ព្រះអង្គច្យុតចាកតុសិតពិភព មកកាន់យកនូវបដិសន្ធិក្នុងផ្ទៃនៃនាងសិរីមហាមាយាខាសក្យត្រកូល ក្នុងថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំរកា សឹងប្រកបដោយមហាឆ្ឆរិយៈ អស្ចារ្យផ្សេងៗ ។

(បប់តុសិតបរិច្ឆេទ ទី៣)

---

## គព្ភាភិនិក្ខមនបរិច្ឆេទ ទី៤

(១) តទា កិរ មហាមាយា បុរេ បុណ្ណមីទិវសតោ បានឮមកថា ក្នុងកាលមុន ៧ ថ្ងៃ អំពីថ្ងៃពេញបូណ៌មី ខែអាសាឍនោះ មហាជនក្នុងនគរកបិលវត្ថុនោះ បបួលគ្នាលេងមហោស្រព ។ ឯនាងសិរីមហាមាយា ក៏តាក់តែងកាយដោយគ្រឿងសុគន្ធវិលេបនៈ ហើយក្រសាលនក្ខត្តឫក្សអស់៧ថ្ងៃ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់ថ្ងៃបុណ្ណមីវេលាព្រឹក នាងទេវីស្រង់ស្រេចហើយ ក៏បរិច្ចាគទ្រព្យចំនួន៤សែនកហាបណៈ ឱ្យជាទាន នាងសោយស្រេចក៏សមាទានឧបោសថសីល ហើយ ឡើងផ្ទំលើសិរីសយនា ។

(២) បច្ឆិមយាមេ លុះដល់បច្ឆិមយាម ព្រះនាងទេវីបានឃើញសុបិននិមិត្ត ។ ឯ សុបិនិមិត្តនោះនាងឃើញថា "បាតុម្មហារាជទាំង៤ មកលើកព្រះនាងទាំងសិរីសយនានាំទៅកាន់ព្រៃហិមវន្ត ហើយតាំងទុកលើមនោសិលាដ៏ធំ ប្រមាណ ៦០ យោជន៍ ខាងក្រោមដើមរាំងធំ មួយកំពស់ ៧យោជន៍, កាលនោះនាងទេវីទាំងឡាយរបស់មហារាជទាំងនោះ មកអញ្ជើញព្រះនាងទៅស្រង់ទឹកក្នុងស្រះអនោតត្ត ដុះជំរះព្រះកាយថ្វាយព្រះនាង ហើយលាបដោយគន្ធវិលេបនៈជាទិព្វ ក្នុងទីជិតស្រះនោះមានភ្នំប្រាក់មួយ មានសុវណ្ណវិមាន១ឋិតនៅលើភ្នំប្រាក់នោះ, នាងទេពធីតាក៏អញ្ជើញព្រះនាងទៅឱ្យផ្ទំក្នុងសុវណ្ណ-វិមាន ឱ្យយកព្រះសិរទៅទិសខាងកើត ក្នុងទីជិតរជតបព៌តនោះមានសុវណ្ណគិរី១, មានសេតហត្ថី១ ត្រាច់បរលើសុវណ្ណ-បព៌ត ចុះបាកសុវណ្ណគិរីមក ឡើងលើរជតបព៌ត សេតហត្ថីនោះមានប្រមោយកាន់យកនូវសេតបទុមជាតិ បន្លឺនូវកោញ្ចនាទ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចូលមកក្នុងសុវណ្ណវិមាន ដើរប្រទក្សិណព្រះនាង៣ជុំ ហើយហាក់បីដូចជាចូលទៅក្នុងឧទរប្រទេសខាងស្តាំ” ។ ព្រះបរម-ពោធិសត្តចុះចាប់បដិសន្ធិក្នុងកាលនោះ ។

(៣) ទ្វត្តិំសបុព្វនិមិត្តានិ បុព្វនិមិត្ត ៣២ ប្រការ មានកម្បនាទលោកធាតុជាដើម មានឱភាសភ្លឺទូទៅជាទីបំផុត ដើម្បីសំដែងនូវគុណនោះៗ ក៏កើតឡើងក្នុងកាលនោះ ។ កាលបើរាត្រីភ្លឺឡើង, ព្រះនាងក៏យាងទៅក្រាបបង្គំទូលសួរនូវសុបិននិមិត្តនោះដល់ព្រះបាទសិរីសុទ្ធោទនៈ ។ ព្រះអង្គទ្រង់ត្រាស់ឱ្យរាជបុរសទៅអញ្ជើញព្រាហ្មណ៍មកទាយ ។ ព្រាហ្មណ៍សោតក៏ធ្វើទំនាយ តាមប្រភេទគ្រប់ប្រការ ។

(៤) សា គព្ភំ ធារេន្តី កាលព្រះនាងទេវីទ្រង់គភ៌ ចាតុម្មហារាជទាំង៤ ក្នុងចក្កវាឡនេះមានព្រះហស្តកាន់ព្រះខ័ន មកជួយរក្សា មិនត្រឹមតែស្តេចទាំង៤ ក្នុងចក្កវាឡនេះប៉ុណ្ណោះឡើយ សូម្បីចាតុម្មហារាជទាំង១មុឺនចក្កវាឡក៏មានព្រះហស្តកាន់ព្រះខ័ន មកជួយអភិបាលបីបាច់រក្សាព្រះនាងជាពុទ្ធមាតាដែរដរាបដល់គ្រប់១០ខែជាកំណត់ ។

បំណែកខាងព្រះពោធិសត្តដែលនៅក្នុងឧទរ ព្រះអង្គគង់

Websites: WatKhemaraRatanaram.org or WatKhmers.org

ពៃនព្រះភ្នែនបែរព្រះភក្ត្រទៅខាងព្រះឧទរព្រះមាតា ព្រះបិដ្ឋិបែរទៅខាងបិដ្ឋិព្រះមាតា មិនដូចជាសត្វទាំងឡាយដទៃឡើយ។

(៥) សា បរិបុណ្ណគព្ភា លុះនាងទេវីមានគភ៌បរិបូណ៌ក៏មានប្រាថ្នានឹងយាងទៅកាន់ទេវទហនគរជាជាតិភូមិនៃខ្លួន ទើបទៅក្រាបបង្គំទូលដល់ព្រះភស្តា ។ ព្រះរាជាទ្រង់អនុញ្ញាតហើយ ទ្រង់ត្រាស់ព្រះរាជបញ្ជាឱ្យរាជអាមាត្រតាក់តែងនូវរាជវិថីជាទីទៅតាំងពីនគរ កបិលភ័ស្តុជរាបដល់នគរទេវទហៈ ។ លុះដល់បុព្វណ្ហសម័យថ្ងៃបុណ្ណមីនៃខែវិសាខ ព្រះនាងទេវីក្រាបថ្វាយបង្គំលាព្រះភស្តា ស្តេចទៅដោយសុវណ្ណសិវិកា (វរមាស) ដល់លុម្ពិនិវនុយ្យាន ជាចន្លោះនៃនគរទាំងពីរ គឺកបិលភ័ស្តុ១ ទេវទហៈ១ ។

(៦) សា ទេវី សាលវនំ បស្សន្តី ព្រះនាងទេវីកាលបានទស្សនាសាលវ័ន ក៏មានព្រះរាជហឫទ័យចង់ចូលទៅប្រពាតក្នុងព្រៃនោះ ។ រាជអាមាត្រក៏អញ្ជើញព្រះនាងចូលទៅ ។ ព្រះនាងយាងទៅដល់ខាងក្រោមដើមសាលព្រឹក្សហើយ ក៏មានព្រះរាជហឫទ័យតោងមែកសាលព្រឹក្ស មិនអាចនឹងឈោងព្រះហស្តទៅចាប់បានឡើង ។ ខណៈនោះមែកសាលព្រឹក្សក៏

Websites: WatKhemaraRatanaram.org or WatKhmers.org
ទន់ទោរចូលមកឱ្យព្រះនាងចាប់ ។ កាលព្រះនាងកំពុងចាប់នូវមែកសាលព្រឹក្ស, ខ្យល់កម្មជវាតក៏កំរើកឡើង ។ ជនទាំងឡាយបានដឹងហេតុ ក៏យកព្រះសន្ធិយាទៅបិទបាំងក្រោមដើមសាលព្រឹក្សហើយបេញមកខាងក្រៅ ។ ទេវតាទាំង ១ ម៉ឺនលោកធាតុ ក៏មកប្រជុំព្រមក្នុងទីនោះ ។ ព្រះពោធិសត្វក៏ប្រសូតចាកព្រះឧទរនៃព្រះមាតា មានព្រះកាយដ៏បរិសុទ្ធល្អក្នុងឆ្នាំច ខែវិសាខ ថ្ងៃសុក្រ ពេញបណ៌មីនោះ ។

(៧) តស្មឹ ខណេ ក្នុងខណៈដែលព្រះពោធិសត្វប្រសូតនោះ មានទេរទឹកក្តៅត្រជាក់ហូរធ្លាក់ចុះមកលាងមន្ទិលគភ៌ ។ សុទ្ធាវាសមហាព្រហ្មទាំង៤អង្គ ក៏ចុះមកទទួលព្រះពោធិសត្វដោយបណ្តាញមាស ។ ចាតុម្មហារាជទាំង ៤ ក៏ទទួលពីមហាព្រហ្ម ។ ពួកស្រីស្នំទទួលពី ចាតុម្មហារាជទៅទៀត ។ ឯមហាបុរសក៏ចុះចាកហត្ថាស្រីស្នំ ទ្រង់ឈរលើភូមិភាគដោយព្រះបាទទាំងពីរ ។ មហាព្រហ្មក៏យកស្វេតច្ឆ័ត្រមកបើកបាំងថ្វាយ ។ សុយាមទេវរាជក៏យកវាលវិជនីមកបក់ថ្វាយ ។ ទេវបុត្រមួយ អង្គកាន់យកកែវ៧ប្រការ ។ ទេវបុត្រមួយអង្គកាន់យក

Websites: WatKhemaraRatanaram.org or WatKhmers.org

សុវណ្ណបាទុកា ។ ទេវបុត្រមួយអង្គកាន់មកុដគ្រឿងកកុធ-ភ័ណ្ឌទាំង៥ ។ នោះឃើញប្រាកដល់ភ្នែកមនុស្ស ។

(៨) ឧត្តរាភិមុខោ មហាបុរិសោ មហាបុរសទ្រង់ឈរលើភូមិភាគបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ យាងទៅបាន៧ជំហានហើយពោលអសភិវាចា, ទ្រង់យាងទៅលើផែនដីប្រាកដដូចជាយាងទៅដោយអាកាស, ព្រះកាយមិនបានបិទបាំងដោយសំពត់ប្រាកដដូចជាទ្រង់ប្រដាប់សំពត់ នឹងគ្រឿងអាភរណៈទាំងពួង, ព្រះអង្គជាកុមារតូចប្រាកដដូចជាមនុស្សធំអាយុ ១៦ ឆ្នាំ ។

(៩) តស្មឹ ជាតទិវសេ ក្នុងថ្ងៃដែលមហាបុរសប្រសូតនោះ មានសហជាតវត្ថុដែល កើតព្រមក្នុងថ្ងៃនោះ ៧ គឺនាងពិម្ពា១, ព្រះអានន្ទជាបុត្រនៃព្រះសុក្កោទនៈ១, នាយឆន្នអាមាត្រមួយ១, កាឡុទាយីអាមាត្រ១, កណ្ឋករាជអាជានេយ្យ១, ដើមមហាពោធិព្រឹក្ស១, កំណប់ទ្រព្យ ទាំងបួន១ ។ កំណប់ ទ្រព្យមួយឈ្មោះសង្ខនិធិ មានសំណុំមាត់មូលវិញកន្លះយោជន៍ ។ មួយឈ្មោះឯលនិធិ មានសំណុំមាត់មូលជុំវិញកន្លះយោជន៍ ។ មួយឈ្មោះឧបលនិធិ មានសំណុំមាត់មូលជុំវិញ ៣ គាវុត ។ មួយឈ្មោះបុណ្ឌរីកនិធិ មានសំណុំមាត់មូលជុំវិញ ១ យោជន៍ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដំរៀរហូតដល់ទីបំផុតនៃផែនដីជួបគ្នាទាំង៤ ។ ក្នុងកាលនោះ ពួកខត្តិយទាំងពីរនគរ ក៏កើតបីតិសោមនស្ស អញ្ជើញមហាបុរសព្រមទាំងព្រះជននីត្រឡប់ចូលទៅក្នុងក្រុងកបិលវត្ថុវិញ។

(ចប់គព្ភាភិនិក្ខមនបរិច្ឆេទ ទី៤)

---

## លក្ខណបរិគ្គហណបរិច្ឆេទ ទី៥

(១) តំ ទិវសំ តាវត្តឹសា ទេវា អត្តមនា ក្នុងថ្ងៃដែលមហាសត្វប្រសូតនោះ ទេវតាទាំងឡាយ ដែលនៅក្នុងតាវត្តិង្សពិភព មានសម្តេចអមរិន្ទ្រាធិរាជជាដើម មានព្រះទ័យត្រេកអរបរបាដល់គ្នានឹងគ្នាថា "ព្រះរាជបុត្ររបស់ព្រះបាទសិរីសុទ្ធោទនមហារាជដែលប្រសូតនោះ នឹងបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធទ្រង់នឹងសំដែងធម្មចក្រ, យើងនឹងបានឃើញនូវព្រះពុទ្ធមិនខាន" ទើបទេវតាទាំងឡាយក៏បបួលគ្នាថ្វាយពរស័ព្ទសាធុការធ្វើសក្ការបូជាច្រើនក្រៃលែង នូទៅទាំងទេវលោក ។

(២) តស្មឹ សមយេ កាឡទេវលោ នាម តាបសោ ក្នុងសម័យនោះ តាបសឈ្មោះកាឡទេវិល ជាអ្នកបាននូវអដ្ឋសមាបត្តិ មានរិទ្ធិច្រើន ជាជីតុនព្រះបាសិរីសុទ្ធោទន បានឮពាក្យទេវតាដូច្នោះ ក៏ចេញចាកទិវាវិហារ ចុះចាកទេវលោក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

មកកាន់សំណាក់ព្រះបាទ សិរីសុទ្ធោទន ដល់ហើយក៏ថ្វាយព្រះពរសួរថា "បុត្រមហារាជប្រសូតហើយឬ? អាត្មាភាពចង់ ឃើញ" ។ ព្រះរាជាទ្រង់ត្រាស់ព្រះរាជបញ្ជាឱ្យនាំព្រះរាជបុត្រមក ដើម្បីឱ្យថ្វាយបង្គំព្រះតាបស ។ ខណៈនោះព្រះបាទទាំងពីរនៃព្រះមហាសត្វ ក៏ត្រឡប់ទៅជាប្រតិស្ឋានលើជដាតាបសវិញ ។ តាបសឃើញហេតុជាអស្ចារ្យ ក៏ក្រោកចាកអាសនៈធ្វើអញ្ជលីទូលព្រះបាទមហាសត្វ ។ ព្រះវរបិតាទតឃើញហើយ ក៏ធ្វើ អភិវន្ទនាការព្រះរាជឱរសដោយសេចក្ដីសំគាល់ថា ដូចជាមហាព្រហ្ម ។

(៣) តាបសោ លក្ខណសម្បត្តិ ទិស្វា តាបសបានឃើញនូវបវរលក្ខណសម្បត្តិនៃពោធិសត្វ ក៏ពិចារណាថា "ព្រះរាជកុមារនេះបានត្រាស់ឬទេ" ទើបដឹងច្បាស់ដោយញាណថា "ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធមិនមានសង្ស័យឡើយ" លុះដឹងដូច្នេះហើយ ក៏សើចហើយត្រឡប់ជាយំវិញ ។ មនុស្សទាំងឡាយសួរហេតុនោះ ។ ទើបតាបសប្រាប់ហេតុនោះថា ដែលអាត្មាសើចនោះដោយសេចក្ដីត្រេកអរនឹងព្រះអយ្យបុត្រនេះបានត្រាស់ជាព្រះពុទ្ធ, ដែលអាត្មាយំនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយគំនិតអាណិតខ្លួនថា ជាមនុស្សផុតភ័ព្វ មិនបានទាន់ព្រះអយ្យបុត្រដែលនឹងបានត្រាស់ជាព្រះពុទ្ធ ។

(៤) តតោ តាបសោ លំដាប់នោះតាបសពិចារណាតទៅទៀត បានឃើញនាឡកៈជា ក្មួយថានឹងបានទាន់, ទើបថ្វាយព្រះពរលាទៅកាន់សំណាក់ប្អូនស្រីនៃខ្លួន ដល់ហើយក៏ឱ្យហៅនាឡកៈកុមារមក, កាលបើនាឡកកុមារមកដល់ហើយ, តាបសប្រាប់ថា "ម្នាលបាឡកៈ, ព្រះរាជឱរសនៃព្រះបាទសិរីសុទ្ធោទន នឹងបានត្រាស់ជាព្រះពុទ្ធ, បាឯងនឹងបានទាន់ព្រះអង្គ, ចូរបាឯងបួសក្នុងថ្ងៃនេះចុះ" ។ នាឡកកុមារបានស្តាប់ពាក្យឪពុកធំហើយក៏ទទួលព្រម ទើបផ្គងអញ្ជលីឆ្ពោះទៅរកព្រះពោធិសត្តថា "បុរសឯណាជាឧត្តមបុគ្គលក្នុងលោក,បព្វជ្ជារបស់ខ្ញុំឧទ្ទិសចំពោះបុរសនោះ" ហើយឱ្យគេកោរសក់នឹងពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយ៍ប្រកបាត្រក្នុងស្លោកស្ពាយចូលទៅនៅធ្វើសមណធម៌ក្នុងព្រៃហេមពាន្ត(១) ។ ចំណែកតាបស លុះធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងអរូបភព ។

---

(១) ក្នុងគម្ពីរ ឯកនិបាតជាតក, គម្ពីរអដ្ឋកថាធម្មចក្កប្បវត្តនសូត្រ, គម្ពីរជិនមហានិទានមានសេចក្តីត្រូវគ្នាដូច្នេះតែបែបមួយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

(៥) ពោធិសត្តោ បញ្ចាហំ និក្ខន្តោ ចំណែកព្រះបរម-ពោធិសត្វ រាប់អំពីថ្ងៃប្រសូតមកបាន៥ថ្ងៃ ព្រះវររាជបិតាទ្រង់នឹងថ្វាយព្រះនាម ទើបទ្រង់ឱ្យតាក់តែងរាជពិភព រោយរាយដោយបុប្ផជាតិមានលាជជាគំរប់ប្រាំ, ព្រះរាជាឱ្យតាក់តែងមធុ-បាយាស ទើបទ្រង់ឱ្យប្រជុំខត្តិយៈ នឹងព្រាហ្មណ៍សេនាប្រមុខ-មាត្យក្នុងរាជនិវេសន៍, ព្រះរាជាឱ្យអញ្ជើញព្រាហ្មណ៍ ១០៨ នាក់ មកគង់លើអាសនៈ អង្គាសដោយភត្តាហារដ៏ប្រណីតស្រេចហើយបញ្ជូនទៅ ទុកតែព្រាហ្មណ៍៨នាក់ ដែលមាននាមប្រាកដគឺ រាមព្រាហ្មណ៍១, លក្ខណព្រាហ្មណ៍១, យញ្ញ-ព្រាហ្មណ៍១, ធជព្រាហ្មណ៍១, សុភោជព្រាហ្មណ៍១, សុទត្ត-ព្រាហ្មណ៍១, សុយាមព្រាហ្មណ៍១, កោណ្ឌញ្ញព្រាហ្មណ៍១, សុទ្ធសឹងជាអ្នកចេះចាំស្ទាត់ក្នុងត្រៃវេទជាងព្រាហ្មណ៍ទាំងពួង ។

(៦) សត្ត ព្រាហ្មណា ព្រាហ្មណ៍ទាំងឡាយ៧នាក់លើកម្រាមដៃពីរហើយទាយដោយចំណែកពីរថា "បពិត្រព្រះសម្មតិទេព កុមារដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះ សឹងប្រកបដោយគតិពីរប្រការ គឺបើកុមារនៅគ្រប់គ្រង់គេហដ្ឋាន នឹងបានសោយរាជសម្បត្តិជាស្តេចចក្រ ប្រកប

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយធម៌, បើចេញទ្រង់បព្វជ្ជា នឹងបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធក្នុងលោក ។ តេសំ បន ទុហរោ កោណ្ឌញ្ញោ បំណែកកោណ្ឌញ្ញព្រាហ្មណ៍ ដែលក្មេងជាងព្រាហ្មណ៍ទាំងឡាយនោះ បានឃើញនូវលក្ខណៈហើយក៏លើកម្រាមដៃមួយទាយថា "កុមារនេះពុំមែននៅគ្រប់គ្រងគេហដ្ឋានទេ, ពិតជានឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ" ។

(ចប់លក្ខណបរិគ្គហណបរិច្ឆេទ ទី៥)

---

## រាជាភិសេកបរិច្ឆេទ ទី៦

(១) អថស្ស នាមំ គណ្ហន្តា សព្វលោកស្ស អត្ថសិទ្ធិករត្តា សិទ្ធត្ថោតិ នាមំ អកំសុ កាលនោះព្រាហ្មណ៍ទាំងឡាយ ក៏ថ្វាយព្រះនាមដល់ព្រះពោធិសត្វថា "សិទ្ធត្ថកុមារ" ព្រោះហេតុព្រះពោធិសត្វ ជាអ្នកសម្រេចនូវប្រយោជន៍ដល់សត្វលោកទាំងពួង ។ លុះកាលជា បំណែកខាងក្រោយមកពោធិសត្វបានព្រះនាមថាគោតម ដោយអំណាចនៃគោតតមគោត្រ ។ ព្រះរាជាទ្រង់ត្រាស់សួរព្រាហ្មណ៍ថា បុត្ររបស់យើងឃើញនូវអារម្មណ៍ដូចម្ដេច ទើបចេញទៅបួស? ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា ព្រះរាជបុត្រនៃព្រះអង្គបានឃើញនិមិត្ត៤ប្រការ គឺមនុស្ស

Websites: WatKhemaraRatanaram.org or WatKhmers.org

ជរា១, មនុស្សឈឺ១, មនុស្សស្លាប់១, អ្នកបួស១ ។

(២) តំ សុត្វា រាជា ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ក្រាបទូលហើយ ទើបបង្គាប់រាជអាមាត្យថា "តាំងអំពីថ្ងៃនេះទៅ អ្នកទាំងឡាយកុំឱ្យមនុស្សមានសភាពយ៉ាងនេះចូលមកកាន់ទីជិតកូនយើងឡើយ" ហើយទ្រង់តាំងទុកនូវការរក្សាបំងាយមួយគាវុតៗ ក្នុងទិសទាំង៤ ដើម្បីមិនឱ្យមនុស្សមានសភាពដូច្នោះចូលទៅត្រង់វង់ចក្ខុរបស់ព្រះរាជកុមារ ។

(៣) អថ តេ ព្រាហ្មណា លំដាប់នោះព្រាហ្មណ៍ទាំងឡាយនោះផ្ដាំបុត្រទាំងឡាយរបស់ខ្លួនថា "យើងចាស់ហើ, ព្រះរាជឱរសព្រះបាទសិរីសុទ្ធោទន គង់បានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ, យើងមិនទាន់ទេ, កាលបើព្រះរាជឱរសនោះទ្រង់បព្វជ្ជាបានត្រាស់ជាព្រះពុទ្ធហើយ ចូរអ្នកទាំងឡាយបួសក្នុងសំណាក់ព្រះពុទ្ធនោះចុះ ។ ព្រាហ្មណ៍ទាំងឡាយ៧នាក់ឋិតនៅជរាបដល់អស់អាយុក៏ទៅកើតតាមយថាកម្មរបស់ខ្លួន ។ បំណែកខាងកោណ្ឌញ្ញព្រាហ្មណ៍ មិនមានរោគាព្យាធិក៏ឋិតនៅឡើយ ។

(៤) ទ្វេអសីតិ ញាតិគណា បំណែកពពួកញាតិប៉ែតសិបពាន់ពីរជង ក៏ប្រជុំគ្នាថា ព្រះសិទ្ធត្ថរាជកុមារនេះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

បានត្រាស់ជាព្រះពុទ្ធក្តី បានជាស្តេចចក្រពត្តិក្តី យើងនឹងថ្វាយបុត្រម្នាក់ៗ គ្រប់ៗគ្នា ។

ចំណែកព្រះនាងសិរីមហាមាយា រាប់អំពីថ្ងៃដែលប្រសូតពោធិសត្វមកបាន៧ថ្ងៃ នាងក៏សោយទិវង្គតទៅកើតក្នុងតុសិតពិភព ។ ព្រះនាងសោយព្រះទិវង្គតនោះដោយហេតុដែល ប្រសូត្រព្រះពោធិសត្វក៏ទេ, ពិតជាដោយអស់ព្រះជន្ម ។

(៥) ឥន្ទុកុមារោ ឯព្រះឥន្ទុកុមារក្មេងជាងព្រះបរមពោធិសត្វពីរបីថ្ងៃ ។ កាលឥន្ទុកុមារប្រសូត្រមក, នាងបជាបតិគោតមី បានឱ្យមេនំបំបៅ, នាងសោតក៏សម្រេចកិច្ចជាមេនំបំបៅព្រះបរមពោធិសត្វជាលំដាប់រៀងរាបដរាបមក ។

អបេរកទា រាជា ក្នុងកាលថ្ងៃមួយជាខាងក្រោយមក ព្រះរាជាទ្រង់ឱ្យអាមាត្យតាក់តែងព្រះនគរ, កាលទ្រង់ស្តេចទៅកាន់ទីប្រត់ព្រះនង្គ័ល ព្រះអង្គឱ្យនាំព្រះរាជឱរសទៅផង, ទ្រង់ស្តេចទៅជាមួយពួកព្រាហ្មណ៍នឹងគហបតីនឹងអាមាត្យទាំងពួង ។

(៦) តតោ អវិទូរេ ក្នុងទីជិតកសិដ្ឋាននោះ មានដើមជម្ពូព្រឹក្ស១ ដើមមានមែកនឹងស្លឹកក្រាស់ជិតមានសណ្ឋានដូចជាមណ្ឌប ។ ព្រះរាជាទ្រង់ឱ្យរៀបចំទីសយនាថ្វាយពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

ផ្ទំក្រោមដើមព្រីងនោះ ទើបស្ដេចយាងប្រត់ព្រះនង្គ័ល ។ មេនំទាំងឡាយឱ្យព្រះពោធិសត្វផ្ទំ ហើយក៏បបួលគ្នាទៅមើលស្ដេចប្រត់ព្រះនង្គ័ល ។ ពោធិសត្តោ ព្រះបរមពោធិសត្វទ្រង់ទតមិនឃើញអ្នកណាមួយសោះ ក៏តើនបាកសយនា គង់ផ្គត់ព្រះភ្នែនកំណត់យក អានាបានស្សតិ ញ៉ាំងបឋមជ្ឈានឱ្យកើតឡើង ។ ស្រមោលឈើទាំងឡាយឯទៀតជ្រេទៅ, ឯស្រមោលដើមព្រីងនោះនៅមូលប្ញឹតតជ្រេឡើយ ។ មេនំត្រឡប់មកវិញបានឃើញព្រះពោធិសត្វគង់លើសយនា ទើបទៅក្រាបបង្គំទូលព្រះរាជា ។ ព្រះអង្គយាងមកឃើញនូវបាដិហារ្យក៏ថ្វាយបង្គំព្រះរាជបុត្រម្ដងទៀត ។

(៧) រាជា កម្មន្តេ បយោជេត្វា ព្រះបាទសិរីសុទ្ធោទនទ្រង់ប្រត់ព្រះនង្គ័លរួចស្រេចហើយ, លុះសាយណ្ហសម័យទ្រង់នាំពោធិសត្វចូលកាន់នគរវិញ ។ ព្រះបរមពោធិសត្វចំរើនបានព្រះជន្មពវិស្សា ព្រះរាជាទ្រង់ត្រាស់សួរអាមាត្យទាំងឡាយថា ក្មេងអាយុ ៧ ឆ្នាំស្រឡាញ់របស់អ្វី? អាមាត្យក្រាបបង្គំទូលថា ក្មេងអាយុ៧ឆ្នាំ ចូលចិត្តលេងទឹក ។ ទើបព្រះរាជាទ្រង់ឱ្យជាងជីកស្រះបោក្ខណី ។ ខណៈនោះក្ដៅទៅដល់អាសនា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្ដេចអមរិន្ទ្រាធិរាជ, ទើបស្ដេចត្រាស់ប្រើវិស្សុកម្មទេវបុត្រមកនិម្មិតស្រះថ្វាយ ។ វិស្សុកម្មទេវបុត្រចុះមកនិម្មិតស្រះបោក្ខរណីប្រកបដោយកែវ៧ ប្រការ ។

(៨) តតោ បដ្ឋាយ មហាសត្តោ ចាប់ផ្ដើមពីកាលនោះមក ព្រះមហាសត្វក៏យាងទៅក្រសាលក្នុងស្រះបោក្ខរណីជាលំដាប់ដរាបដល់ព្រះជន្ម ១៦ វស្សា ទើបព្រះបាទសិរី-សុទ្ធោទនទ្រង់ឱ្យជាងសាងប្រាសាទ ៣ សមគួរដល់រដូវទាំង៣ គឺប្រាសាទ១មានជាន់៩ សមគួរដល់ហេមន្តរដូវ, ប្រាសាទ ១ មានជាន់ ៧ សមគួរដល់គិម្ហរដូវ, ប្រាសាទ ១ មានជាន់ ៥ សមគួរដល់វស្សានរដូវ ។ លុះធ្វើស្រេចព្រះរាជាទ្រង់បញ្ជូនព្រះរាជបណ្ដាំដល់ស្ដេចសក្យៈទាំងពួង ឱ្យបញ្ជូនព្រះរាជធីតាមកថ្វាយ ។ ស្ដេចសក្យៈទាំងឡាយក៏តបមកវិញថា ព្រះរាជបុត្រព្រះអង្គគ្រាន់តែមានរូបល្អ តែពុំចេះ សិល្បសាស្ត្រសោះ ។

(៩) រាជា បុត្តស្ស សន្តិកំ គន្ត្វា ព្រះបាទសិរីសុទ្ធោទនទ្រង់ជ្រាបហើយ ក៏យាងទៅកាន់សំណាក់ព្រះរាជបុត្រប្រាប់តាម ដំណើរ ។ ព្រះពោធិសត្វក៏ទូលថា សូមព្រះវរបិតាឱ្យប្រជុំព្រះញាតិបុះ ខ្ញុំព្រះអង្គនឹងសំដែងសិល្បថ្វាយ ។ ព្រះរាជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់ឱ្យប្រជុំពួកព្រះញាតិហើយ ទើបឱ្យពោធិសត្វលើកធ្នូ សហស្សថាមធនូ, ស្ទួរស័ព្ទក៏លាន់ឮទៅជាអស្ចារ្យ ។ សក្យរាជទាំងពួងក៏ខ្លាចហើយទើបប្រដាប់នូវរាជធីតាបញ្ជូនមកថ្វាយ ។ ខត្តិយកញ្ញា ទាំងអស់៤ម៉ឺនព្រះអង្គ ។ ព្រះរាជាទ្រង់ឱ្យរៀបចំធ្វើរាជាភិសេកពោធិសត្វក្នុងរាជសម្បត្តិ មានព្រះនាងពិម្ពាយសោធរាជាអគ្គមហេសី ក្នុងឆ្នាំធូរ ។ ព្រះបរមពោធិសត្វគង់នៅក្នុងប្រាសាទ ទាំង៣ក៏សមគួរដល់ឧតុកាល ។

(ចប់រាជាភិសេកបរិច្ឆេទ ទី៦)

---

## មហាភិនិក្ខមនបរិច្ឆេទ ទី៧

(១) អថេកទិវសំ ពោធិសត្តោ ឧយ្យានភូមឹ គន្តុកាមោ ក្នុងសម័យថ្ងៃមួយជាខាងក្រោយមក ព្រះបរមពោធិសត្វទ្រង់សព្វព្រះរាជាហឫទ័យនឹងស្ដេចទៅក្រសាលក្នុងឧទ្យាន ទ្រង់ឱ្យនាសារថីទឹមរាជរថ ដោយសេះសន្ធពជាមង្គលពីរគូស្រេច មហាបុរសទ្រង់ឡើងគង់លើរាជរថ មានពួកសេវកាមាត្យហែមរោមជាបរិវារ ទ្រង់ស្ដេចទៅកាន់ឧទ្យាន ។ លំដាប់នោះសុទ្ធាវាសទេវតាមកនិម្មិតជាមនុស្សចាស់ជរាដើរទៅពីមុខ ។ ពោធិសត្វនឹងនាយសារថីបានឃើញប្រាកដ ។ ពោធិសត្វសួរ, នាយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

សារថីក៏ក្រាបបង្គំទូលសព្វគ្រប់ប្រការ ។ ព្រះអង្គមានសេចក្ដីសង្វេគ ទ្រង់ឱ្យនាយសារថីត្រឡប់ព្រះរាជរថមកវិញ ។

(២) បុនេកទិវសំ លុះថ្ងៃមួយជាខាងក្រោយមកទៀត ព្រះអង្គទ្រង់ស្ដេចទៅម្ដងទៀត បានជួបនឹងមនុស្សមានព្យាធិឈឺបំរះនឿល ។ ទ្រង់ស្ដេចទៅក្នុងវារៈជាគំរប់៣បានជួបនឹងមនុស្សស្លាប់ ។ ព្រះអង្គសាកសួរ, នាយសារថីក្រាបទូលសព្វប្រការ ទ្រង់មានសេចក្ដីសង្វេគក៏ត្រឡប់វិលមកវិញ ។ ព្រះបរមពោធិសត្ដទ្រង់ស្ដេចទៅក្នុងវារៈ ជាគំរប់៤ ក៏ជួបនឹងមនុស្សទ្រង់ភេទបព្វជ្ជា, ទ្រង់ត្រាស់សួរ នាយសារថីក៏ក្រាបបង្គំទូលតាមដំណើរ ។ នាយសារថីដែលក្រាបទូលនូវទេវទូតទាំង៤បាន ដោយអំណាចសុទ្ធាវាសទេវតាបញ្ចូលចិត្ត ។ ព្រះបរមពោធិសត្ដទ្រង់ព្រះសណ្ដាប់ហើយ មានព្រះរាជហឫទ័យសោមនស្សក្នុងភេទបព្វជ្ជា ទើបព្រះអង្គស្ដេចទៅក្រសាលក្នុងឧទ្យាន ដល់ហើយទ្រង់យាងចុះស្រង់ក្នុងស្រះបោក្ខរណីជាមង្គល ស្រេចហើយទ្រង់យាងឡើងមកគង់លើផែនសិលាមានប្រាថ្នានឹងប្រដាប់ដោយគ្រឿងប្រដាប់ ក៏វិស្សុកម្មទេវបុត្រក្លែងភេទជាខ្មាន់ព្រះកេសមកប្រដាប់ថ្វាយ។ ព្រះពោធិសត្ដ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្តេចទៅកាន់ឧទ្យានម្តងៗកន្លង៤ខែ ។ ព្រោះ ព្រះពុទ្ធជាម្ចាស់យើងព្រះជន្មតិច ។

(៣) តស្មឹ ខណេ ខណៈនោះ នាងពិម្ពាក៏ប្រសូតព្រះរាជបុត្រគឺរាហុលកុមារ ។ ព្រះបាទសិរីសុទ្ធោទន៍បញ្ជូនអាមាត្យឱ្យទៅក្រាបទូលដល់ពោធិសត្វ ។ កាលបើអាមាត្យទៅក្រាបបង្គំទូលតាមព្រះរាជបណ្តាំហើយ, ទ្រង់មានព្រះរាជឱង្ការថា "រាហុលកុមារជាចំណងធំប្រសូតហើយ" ទើបព្រះអង្គឡើងគង់លើរាជរថរតឡប់ទៅដល់រាជនិវេសន៍ ក៏បានទ្រង់ព្រះសណ្តាប់នូវគាថា ដែលនាងខត្តិយកញ្ញាឈ្មោះកីសាគោតមី ពោលថា:

និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា
និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតិ ។

សេចក្តីថា ព្រះសិទ្ធត្ថអង្គនេះ បើបានជាបុត្រនៃព្រះមាតាណា ព្រះមាតនោះរលត់ទុក្ខដោយពិត, បើបានជាបុត្រនៃព្រះបិតាណា ព្រះបិតានោះរលត់ទុក្ខដោយពិត, បើបានជាប្តីនៃនារីណា នារីនោះរលត់ទុក្ខដោយពិត ។

ពោធិសត្វបានទ្រង់ព្រះសណ្តាប់ហើយ មានព្រះរាជបាឬ-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ័យសោមនស្ស ទ្រង់ដោះកែវមុក្តាហារអំពីព្រះសូរងបញ្ជូនទៅព្រះរាជទានដល់នាងខត្តិយកញ្ញានោះ ។

(៤) មហាបុរិសោ ព្រះមហាបុរសយាងឡើងលើប្រាសាទសោយស្រេចហើយ ទ្រង់យាងចូលទៅកាន់ទីសយនាគ្រឡាព្រះបន្ទំស្តប់ស្តល់អស់បឋមយាម ។ នាងនាដកិត្តិ្ស្រីរបាំដែលប្រគំតូរ្យតន្ត្រី លែងប្រគំដេកលក់ទៅ ក៏សំដែងវិប្បការផ្សេងៗមានដេកអាក្រាតកាយជាដើមៗ លុះដល់មជ្ឈិមយាមទ្រង់តើនឡើងទតឃើញវិប្បការនៃស្រីរបាំ ក៏មានសេចក្តីសង្វេគព្រោះឃើញទីប្រាសាទដូចជាពាសពេញដោយសាកសព, ទើបទ្រង់ដាស់ឆន្នអាមាត្យឱ្យទៅនាំយកកណ្ឋកអាជានេយ្យមក ព្រះអង្គយាងចូលទៅក្នុងបន្ទប់ប្រាថ្នានឹងលើកបីព្រះរាជបុត្រ ទ្រង់ទតឃើញនាងយសោធរាពិម្ពាផ្ទំដាក់ព្រះហស្តគងលើព្រះរាជឱរស ព្រះអង្គយាងចេញមកវិញដោយទ្រង់ព្រះចិន្តាថា “គ្រាក្រោយសឹមមកឃើញមុខកូន” ព្រះអង្គយាងចុះចាកប្រាសាទឡើងគង់លើខ្នងអស្សពាហន៍មានខ្លួនប្រវែង១៨ហត្ថ ទ្រង់ឱ្យឆន្នអាមាត្យតោងកន្ទុយ ព្រះអង្គយាងចាករាជនិវេសន៍ទៅដល់ខាងក្រៅនគរទ្រង់បែរទតមកនគរវិញ ។ ទីនោះឈ្មោះអនិវត្តនចេតិយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ហឹង សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

(៥) តស្មឹ ខណេ មារោ បាបិមា ខណៈនោះ មារមានចិត្តបាបដឹងហេតុហើយ ចុះបាកទេវលោកមកឋិតនៅក្នុងអាកាសពោលឃាត់ថា "នែសិទ្ធត្ថ! អ្នកកុំចេញទៅបួសឡើយ នៅតែ៧ថ្ងៃទៀតសម្បត្តិចក្រពត្តិនឹងមកដល់ហើយ" ។ ពោធិ-សត្វថា "យើងដឹងហើយ យើងមិន អាល័យទេ" ។ មារក៏ចៀសចេញទៅ ។

មហាបុរសសោតមានទេវតាចោមរោមជាបរិវារ ព្រះ-អង្គយាងរំលងនគរទាំង៣គឺនគរកបិលវត្ថុ១, សាវត្ថី១, វេសាលី១, អស់ផ្លូវចម្ងាយ៣០យោជន៍ ទៅដល់ស្ទឹងអនោមា ទ្រង់សួរ ឆន្នអាមាត្យគ្រប់ប្រការ ព្រះអង្គក៏បរសេះឆ្លងទៅត្រើយឆាយ ខ្វាបព្រះវរបិតាឱ្យទៅតាម ។

(៦) អថ ពោធិសត្តោ គ្រានោះ ព្រះពោធិសត្វទ្រង់ចុះបាកខ្នងកណ្ឋកៈគង់លើផ្ទុកខ្សាច់ ហើយត្រាស់បង្គាប់ឱ្យឆន្នអាមាត្យនាំសេះយកគ្រឿងប្រដាប់មកវិញ ដើម្បីថ្វាយដំណឹងដល់ព្រះវរបិតា ។ នាយឆន្នអាមាត្យក៏នាំសេះទៅផុតទីបន្តិច សេះក៏បែកហឫទ័យស្លាប់ដោយសេចក្តីទុក្ខ បានទៅកើតក្នុងតាវត្តិង្សវិមាន ឈ្មោះកណ្ឋកទេវបុត្រ ។ ព្រះមហាបុរស

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រាថ្នា នឹងកាត់ព្រះកេសា ។ ខណៈនោះ វត្ថុទាំងពួកគ្រឿងជាទិព្វ ក៏ធ្លាក់ចុះមកពីអាកាស ។ ព្រះអង្គកាត់ព្រះកេសាទុកឱ្យសល់ប្រវែង២ធ្នាប់ នោះក៏វិលជាទក្ខិណាវដ្ត ។ ទើបព្រះអង្គអធិដ្ឋានមោលីហើយបោះទៅក្នុងអាកាស ។ ព្រះឥន្ទ្រយកប្រអប់កែវមកដាក់យកទៅបញ្ចុះទុកក្នុងចូឡាមណីចេតិយក្នុងឋានតាវត្តិង្ស ។

(៧) ពោធិសត្តោ បុន ចិន្តេសិ ព្រះបរមពោធិសត្វទ្រង់ព្រះចិន្តានឹងរកត្រៃចីវរទៀត ។ លំដាប់នោះឃដិការមហាព្រហ្មក៏នាំនូវគ្រឿងបរិក្ខារ៨គឺ ចីវរ៣, បាត្រ១, កាំបិតកោរ១, បំពង់ម្ជុល១, វត្ថពន្ធ១, ដំរងទឹក១, មកថ្វាយ ។ ព្រះមហាបុរសទ្រង់ទទួលគ្រឿងបរិក្ខារហើយ សមាទាននូវទង់ព្រះអរិយៈទ្រទ្រង់ត្រៃចីវរទ្រង់បព្វជ្ជាស្រេចហើយ ទើបប្រទាននូវសំពត់១គូដល់មហាព្រហ្ម ។ ឃដិការមហាព្រហ្មក៏ទទួលយកទៅបញ្ចុះទុកក្នុងទុស្សចេតិយកំពស់១២យោជន៍ ក្នុងព្រហ្មលោក ។

ព្រះពោធិសត្វដែលយាងចេញសាងបព្វជ្ជានេះ ព្រះជន្ម ២៩ឆ្នាំ ចេញទៅក្នុងវេលាមជ្ឈិមយាមថ្ងៃព្រហស្បតិ៍ បុណ្ណមី ខែអាសាឍ ឆ្នាំថោះ ។

(ចប់មហាភិនិក្ខមនបរិច្ឆេទ ទី៧)

---

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

# ទុក្ករកិរិយាបរិច្ឆេទ ទី៨

(១) ធនេ្នា មតំ កណ្ឌកំ ទិស្វា នាយឆន្នអាមាត្យ ឃើញសេះកណ្ឋកៈស្លាប់ដូច្នោះហើយក៏កើតសេចក្ដីទុក្ខទួញយំ, លុះបន្ធោរបង់នូវសេចក្ដីសោកហើយ ក៏ស្រាយគ្រឿងប្រដាប់អំពីកណ្ឋកៈ រៀបជាបង្វិចស្ពាយដើរទៅ, លុះទៅដល់នគរកបិលវត្ថុហើយ ក៏នាំគ្រឿងប្រដាប់ទាំងអស់ទៅថ្វាយព្រះបាទសិរីសុទ្ធោទន៍ ក្រាបទូលតាមបណ្ដាំព្រះបរមពោធិសត្វ ។

បំណែកកោណ្ឌញ្ញព្រាហ្មណ៍ បានដឹងជាមហាបុរសចេញសាងបព្វជ្ជា ទើបបបួលកូនព្រាហ្មណ៍ទាំង៧នាក់ ដែលទាយលក្ខណៈព្រះមហាបុរស ។ បំណែកកូនព្រាហ្មណ៍ក៏មិនព្រមចិត្តគ្នាទាំង ៧ នាក់ឡើយ, ព្រមតែ ៤ នាក់ រួមទាំងកោណ្ឌញ្ញព្រាហ្មណ៍ម្នាក់ទៀតផង ត្រូវជា៥នាក់ នាំគ្នាចេញទៅសាងបព្វជ្ជា មានឈ្មោះថា បញ្ចវគ្គិយភិក្ខុ ។

(២) មហាបុរិសោ អនុបិយម្ពវនេ វសន្តោ ព្រះមហាបុរសទ្រង់បព្វជ្ជាហើយ ក៏យាងទៅគង់ក្នុងអនុបិយម្ពវ័ន ទ្រង់មិនសោយអាហារអស់៧ថ្ងៃ ព្រះអង្គញុំាងកាលឱ្យប្រព្រឹត្តកន្លងទៅ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវ៉ិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយសេចក្ដីសុខក្នុងបព្វជ្ជា ។ លុះដល់ថ្ងៃជាគំរប់៨ព្រះមហាបុរសទ្រង់ប្រដាប់ដោយបាត្រនឹងចីវរ ស្ដេចបរសំដៅទៅនគររាជគហៈដើម្បីបិណ្ឌបាត ។ មនុស្សក្នុងនគរបានឃើញនូវព្រះពោធិសត្វមានរូបល្អ ក៏មានចិត្តត្រេកអរសោមនស្សរីករាយរាល់គ្នា ។

(៣) រាជបុរិសោ បន បំណែករាជបុរសបានឃើញព្រះពោធិសត្វ ក៏ទៅក្រាបបង្គំទូលព្រះបាទពិម្ពិសារថា បពិត្រព្រះសម្មតិទេព, មានមនុស្សម្នាក់រូបល្អបំណាប់ខ្ញុំព្រះអង្គពុំស្គាល់ជាទេវតាឬគ្រុឌ គន្ធព្វឬយក្ស ឬក៏នាគទេ ត្រេចបរបិណ្ឌបាតក្នុងនគរ ។ តំ សុត្វា រាជា ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យរាជបុរសក្រាបបង្គំទូលហើយ ក៏ទ្រង់បើកសីហបញ្ជរ ទតទៅឃើញមហាបុរស ទ្រង់ត្រាស់ព្រះរាជបញ្ជរឱ្យរាជអាមាត្យទៅចាំឃ្លាំមើល ។

(៤) មហាបុរិសោ សន្តិន្ទ្រិយោ ព្រះមហាបុរសមានឥន្ទ្រិយសង្រួមល្អប្រពៃត្រេចបរបិណ្ឌបាត, លុះបានភត្តាហារល្មម១បំអែត ទ្រង់ក៏យាងចេញចាកនគរទៅគង់ក្នុងញកភ្នំបណ្ឌវបពិតប្រារព្ធនឹងសោយភត្តាហារដោយបដិកូលសញ្ញា ទុន្នាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវខ្លួនហើយទើបព្រះអង្គធ្វើនូវភត្តកិច្ច ។ រាជបុរសដែលតាមមើលនោះ លុះបានឃើញព្រះបរមពោធិសត្តសោយភត្តាហារក្នុងញកភ្នំក៏ទៅក្រាបបង្គំទូលព្រះបាទពិម្ពិសាររាជវិញ តាមដំណើរសព្វគ្រប់ប្រការ ។

(៥) រាជា តំ សុត្វា ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវហេតុនោះហើយ ទើបព្រះអង្គយាងទៅកាន់សំណាក់ព្រះពោធិសត្វទ្រង់សាកសួរជាតិត្រកូល ។ ព្រះពោធិសត្វក៏ថ្វាយព្រះពរសព្វគ្រប់ប្រការ ។ ព្រះបាទពិម្ពិសាររាជជ្រាបហើយ ក៏អញ្ជើញពោធិសត្វដោយរាជសម្បត្តិពាក់កណ្ដាល ។ ព្រះពោធិសត្វមិនព្រមទទួល ។ ព្រះរាជាទ្រង់ប្ដេជ្ញាថា បើមហាមិត្របានត្រាស់ហើយ, សូមមកប្រោសញោមជាមុន ។ ព្រះពោធិសត្វក៏ទទួលសេចក្ដីប្ដេជ្ញានៃព្រះបាទពិម្ពារសាររាជ។ ព្រះរាជាក៏ទ្រង់ស្ដេចចូលទៅក្នុងនគរវិញ ។

(៦) ពោធិសត្តោ តស្សេវ បដិញ្ញំ ទត្វា ព្រះបរមពោធិសត្វថ្វាយសេចក្ដីប្ដេជ្ញាដល់ព្រះបាទពិម្ពិសាររាជហើយ ព្រះអង្គក៏យាងចាកភ្នំបណ្ឌវៈទៅកាន់សំណាក់អាឡារតាបស, ទ្រង់ខំរៀនបានសមាបត្តិ៧, ទើបទ្រង់យាងទៅកាន់សំណាក់ឧទ្ទក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

តាបស, ព្រះអង្គទ្រង់បំរើនបានសមាបត្តិ៨ហើយព្រះអង្គសួរធម៌វិសេសតទៅទៀត ។ ឧទ្ទកតាបសក៏ទាញទាល់ ។ ទ្រង់ក៏សន្និដ្ឋានថា "ផ្លូវនេះមិនមែនជាផ្លូវត្រាស់ដឹងទេ" ទើបព្រះអង្គយាងទៅកាន់ឧរុវេលនិគម ទ្រង់តាំងទុកនូវមហាបធាន (កិរិយាព្យាយាមធំ) ក្នុងទីនោះ ។

(៧) តេន ខោ បន សមយេន ក្នុងសម័យនោះ កោណ្ឌញ្ញដែលបានឃើញបានទាយលក្ខណៈមហាបុរសហើយបបួលគ្នាទៅបួសនោះ ក៏ដើរត្រេចរកបិណ្ឌបាត្រក្នុងស្រុកនិងនិគម បានទៅដល់ទីលំនៅព្រះបរមពោធិសត្វ ហើយធ្វើកិច្ចការបំរើ ។ ព្រះពោធិសត្វទ្រង់ធ្វើបធានកិរិយាអស់៦វស្សាមិនទាន់បានត្រាស់ ក៏ព្រះអង្គបន្ថយអាហារជាលំដាប់ៗ ដរាបដល់តតសោយសោះ ។ ទេវតាក៏នាំយកឱជារសទិព្វមកដាក់ក្នុងរណ្ដៅនៃរោម ។ ព្រះពោធិសត្វទ្រង់ធ្វើព្យាយាមដរាបដល់ដួលសន្លប់លើផែនដី ។ ខណៈដែលព្រះអង្គដួលនោះ ទេវតាជាមារកាយិកា (បក្សពួកមារ) ឃើញពោធិសត្វដួល គិតស្មានជាព្រះអង្គសុគត ក៏ហោះទៅទូលព្រះបាទសិរីសុទ្ធោទន៍ ។ ព្រះរាជាទ្រង់មិនបានជឿ ។ បំណែកមារក៏ហោះចុះមកពោលពាក្យ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

បំអកបំអន់ផ្សេងៗ ហើយត្រឡប់ទៅ ។ សក្កទេវរាជយកពិណមានខ្សែ៣ មកដេញថ្វាយ, រឹតខ្សែ១តឹងណាស់ដាច់ទៅ, រឹតខ្សែ១ ធូរណាស់មានសំឡេងមិនពិរោះ, រឹតខ្សែ១ យ៉ាងកណ្តាលសំឡេងសោតក៏ពិរោះស្រួលល្អ។ ព្រះអង្គមានព្រះស្មារតីឡើង ទ្រង់ពិចារណាថា "អាត្មាអញធ្វើព្យាយាមតឹងណាស់ បានជាមិនបានត្រាស់" ដល់ថ្ងៃក្រោយមកទៀតទ្រង់យាងបិណ្ឌបាតសោយអាហារតាមធម្មតាវិញ ។ លក្ខណសម្បត្តិក៏ពេញបរិបូណ៌ដូចដើម ។

(៨) អថ ខោ បញ្ចវគ្គិយា ភិក្ខូ លំដាប់នោះឯងភិក្ខុទាំង៥អង្គ បានឃើញមហាបុរសសោយភោជនាហារវិញដូច្នោះក៏គិតគ្នាថា ព្រះសិទ្ធត្ថនេះខំធ្វើទុក្ករកិរិយាអស់ ៦ វស្សាមិនបានត្រាស់, ឥឡូវនេះត្រឡប់សោយភត្តាហារវិញហើយកាលណានឹងបានត្រាស់! ប្រយោជន៍អ្វីយើងនឹងនៅបំរើ ។ បញ្ចវគ្គិយភិក្ខុមិនបានបិតនៅក្នុងព្យាករណ៍របស់ខ្លួន ក៏យកបាត្រត្រៃចីវរដើរបោលមហាបុរសទៅកាន់ផ្លូវចម្ងាយ ១៨ យោជន៍បបួលគ្នាទៅនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបនគរពារាណសី តាមសេចក្តីសប្បាយ ។

(៩) តតោ មហាបុរិសោ លំដាប់នោះ មហាបុរសទ្រង់ឃើញមហាសុបិននិមិត្តទាំង៥ ក្នុងវេលាបច្ចូសសម័យថ្ងៃ១៤កើត ខែវិសាខ ។ ឯសុបិននិមិត្តទាំង ៥ នោះដូច្នេះគឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គឃើញមហាប្រឹថពីជាទីសយនាក្រឡាបន្ទំ, ភ្នំហិមវន្តជាខ្នើយរងព្រះសិរ,ព្រះហស្តខាងឆ្វេង សណ្ដូកចុះក្នុងមហាសមុទ្រខាងទិសបូព៌, ព្រះហស្តខាងស្តាំសណ្ដូកចុះក្នុងមហាសមុទ្រខាងទិសបស្ចិម, ព្រះបាទទាំងពីរសណ្ដូកចុះក្នុងមហាសមុទ្រទិសទក្សិណ, នេះជាមហាសុបិនទី១ ។ ទ្រង់ឃើញស្មៅចិញ្ចៀនដុះលេចពីព្រះនាភីឡើងទៅទល់នឹងអាកាស, នេះជាមហាសុបិនទី២ ។ ព្រះអង្គឃើញដង្កូវទាំងឡាយខ្លួនសក្បាលខ្មៅ វារឡើងពីចុងព្រះបាទាដរាបដល់ព្រះជាណុមណ្ឌល, នេះជាមហាសុបិនទី៣ ។ ព្រះអង្គឃើញសត្វបក្សី៤ពួកមានវណ្ណៈផ្សេងៗហើរពីទិសទាំង៤ មកក្រាបទៀបព្រះបាទ ហើយត្រឡប់ជាមានវណ្ណៈសទាំងអស់, នេះជាមហាសុបិនទី៤ ។ ព្រះអង្គទ្រង់ឃើញថា ទ្រង់យាងចង្ក្រមលើភ្នំលាមកដ៏ធំ ព្រះបាទមិនបានប្រឡាក់ដោយលាមកឡើយ, នេះមហាសុបិនទី៥ ។

(១០) មហាបុរិសោបិ ឥមេ បញ្ច មហាសុបិនេ ទិស្វា

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះមហាបុរស ទ្រង់ឃើញមហាសុបិនទាំង៥នេះហើយ ព្រះអង្គតើនបាកទីសយនាទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា "អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ" ព្រះអង្គទាយដោយព្រះអង្គឯងសព្វគ្រប់ប្រការថា ការផ្ទំលើផែនដី ជាបុព្វនិមិត្តនៃកិរិយាបាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ, ភ្នំហិមវន្តជាខ្នើយរងព្រះសិរជាបុព្វនិមិត្តនៃកិរិយាបាននូវខ្នើយ គឺសព្វញ្ញុតញ្ញាណ, ការសណ្ដូកព្រះហស្តនឹងព្រះបាទចុះក្នុងសមុទ្រនោះ ជាបុព្វនិមិត្តនៃកិរិយាសំដែងនូវធម្មចក្រ ដល់ទេវតានឹងមនុស្ស, ការផ្ទំផ្ងារលើ ផែនដីជាបុព្វនិមិត្តនៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ចុះឱ្យផ្ងារឡើង,កិរិយាផ្ទំបើកព្រះនេត្រ ជាបុព្វនិមិត្តនៃកិរិយាបាននូវទិព្វចក្ខុ, ការឃើញនូវពន្លឺភ្លឺឯរាបដល់ភវគ្គព្រហ្មជាបុព្វនិមិត្តនៃអនាវរណញ្ញាណ, ការឃើញតិណជាតិដុះអំពីនាភី ជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គ, ការឃើញដង្កូវប្រែកាយ ជាបុព្វនិមិត្តនៃបរិស័ទទាំង៤ ដល់នូវត្រៃសរ-ណគមន៍ស្មើដោយជីវិត, ការឃើញថាសត្វបក្សី៤ពួក ជាបុព្វនិមិត្តនៃត្រកូល ទាំង៤ បេញសាងបព្វជ្ជាប្រព្រឹត្តតាមធម៌វិន័យ ការឃើញថាចង្រ្កមលើភ្នំលាមក ជាបុព្វនិមិត្តនៃ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

បតុបច្ច័យដែលកើតឡើងដល់ព្រះអង្គ តែព្រះរាជហឫទ័យមិនជាប់ចំពាក់ក្នុងបច្ច័យទាំង ៤ ឡើយ ។

(ចប់ទុក្ករកិរិយាបរិច្ឆេទ ទី៨)

---

## ពុទ្ធបូជាបរិច្ឆេទ ទី៩

(១) តេន ខោ បន សមយេន ឧរុវេលាយំ សេនានិគមោ ក្នុងសម័យនោះ មានស្រុកមួយឈ្មោះសេនានិគម ក្នុងឧរុវេលាប្រទេស ។ មានទារិកាម្នាក់ឈ្មោះនាងសុជាតា ជាធីតានៃសេនកុដុម្ពីនៅក្នុងប្រទេសនោះ ។ នាងមានវ័យចំរើនឡើង បានធ្វើនូវសេចក្ដីប្រាថ្នាទៀបដើមជ្រៃមួយដើមថា "បើខ្ញុំបានប្ដីមានជាតិត្រកូលស្មើគ្នាហើយបានកូនប្រុសច្បង, ខ្ញុំនឹងធ្វើគ្រឿងពលិកម្ម ដោយការបរិច្ចាគទ្រព្យមួយសែនកហាបណៈដល់លោករាល់ៗឆ្នាំ" ។ លុះកាលជាខាងក្រោយមកសេចក្ដីប្រាថ្នានៃនាងសុជាតា ក៏សម្រេចមិនមានឃ្លាត ។

(២) តស្ស ឆព្វស្សានិ ទុក្ករកិរិយំ ករោន្តស្ស កាលដែលមហាបុរសធ្វើទុក្ករកិរិយាអស់៦វស្សា, នាងសុជាតា មានប្រាថ្នាដើម្បីធ្វើពលិកម្មដល់ទេវតា, នាងបង្គាប់ឱ្យមនុស្សនាំមេគោ១.០០០ មកលែងក្នុងព្រៃឈើឯម ឱ្យមេគោបរិភោគឈើ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯម ។ លុះដល់វេលាល្ងាច នាងឱ្យយកភាជនៈ៥០០ត្រង់ទឹកដោះមេគោ ៥០០ យកមកឱ្យមេគោ ៥០០ ដែលមិនរីតទឹកដោះនោះផឹក ។ នាងសុជាតាឱ្យបែងពាក់កណ្ដាលៗ យ៉ាងនេះ ដរាបដល់នៅសល់តែមេគោ៨ ។ នាងសុជាតាធ្វើយ៉ាងនេះ ដើម្បីឱ្យទឹកដោះនោះមានរសផ្អែម។

(៣) វិសាខបុណ្ណមីទិវសេ បាតោវ នាងសុជាតាគិតថា "វេលាព្រឹកស្អែកនេះជាថ្ងៃបុណ្ណមីខែវិសាខ, អាត្មាអញនឹងធ្វើពលិកម្មដល់ទេវតារក្សាដើមព្រះជ្រៃ" លុះព្រឹកឡើងនាងឱ្យរីតទឹកដោះមេគោទាំង៨, នាកាលភាជនៈដែលគេបង្អោនចូលទៅជិតដើមដោះមេគោ, ទឹកដោះក៏ហូរចុះមកខ្លួនឯង ។ តំ អច្ឆរិយំ ទិស្វា នាងសុជាតាបានឃើញហេតុជាអស្ចារ្យដូច្នោះ ក៏កាន់យកទឹកដោះដោយដៃខ្លួនឯងទៅចាក់ចុះក្នុងភាជនៈថ្មី បង្កាត់ភ្លើងដោយដៃខ្លួនឯង ប្រារព្ធនឹងចំអិនមធុបាយាស ។ ពពុះសោតក៏វិលជាទក្ខិណាវដ្ដប្រព្រឹត្តទៅជុំវិញមិនបានស្រក់ធ្លាក់ចុះខាងក្រៅភាជនៈឡើយ ។

(៤) តស្មឹ ខណេ ចត្តារោ មហារាជានោ ខណៈនោះចតុលោកបាលទាំង៤ ក៏ចុះមកជួយរក្សាបង្អ្រាន ។ មហា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រហ្មយកស្វេតច្ឆត្រមកបើកបាំង ។ សម្តេចអមរិន្ទ្រាធិរាជមកថែភ្លើង ។ ទេវតាដែលនៅក្នុងចក្កវាឡ ក៏នាំទិព្វឱជារសមកដាក់ក្នុងមធុបាយាសដោយអានុភាពនៃខ្លួន ។ នាងសុជាតាឃើញហេតុជាអស្ចារ្យដូច្នោះ ក៏ហៅនាងបុណ្ណាទាសីមកប្រាប់ថា “បុណ្ណាអើយ ថ្ងៃនេះទេវតាមានចិត្តត្រេកអរនឹងយើងក្រៃពេក, ហេតុជាអស្ចារ្យដូច្នោះក៏មិនធ្លាប់ឃើញទេ, ចូរឯងទៅបោសក្រោមព្រះជ្រៃជាទីលំនៅទេវតាឱ្យស្អាត” ។ នាងបុណ្ណាទាសីក៏ទទួលតាមពាក្យនៃនាងសុជាតា ។

(៨) ពោធិសត្តោ តស្សា រត្តិយា អច្ចយេន លុះរាត្រីនោះកន្លងទៅ ព្រះបរមពោធិសត្តទ្រង់ធ្វើសរីរកិច្ចស្រេចហើយព្រះអង្គគង់រង់ចាំភិក្ខាចារវេលា ទើបទ្រង់ស្តេចទៅគង់នៅនាដើមព្រះជ្រៃ ។ លំដាប់នោះ នាងបុណ្ណាទាសីដើរទៅបានឃើញព្រះពោធិសត្តគង់ទតលោកធាតុ បែរទៅខាងកើត មានរស្មីផ្សាយចេញអំពីព្រះកាយ មានវណ្ណៈដូចជាមាស ក៏កំណត់ថា “ថ្ងៃនេះទេវតាយើងចុះបាកដើមជ្រៃមករង់ចាំទទួលគ្រឿងពលិកម្មដោយដៃខ្លួនឯង” នាងក៏មានចិត្តត្រេកអរត្រឡប់ទៅជម្រាបហេតុនោះដល់នាងសុជាតា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

(៦) សុជាតា តស្សា វចនំ សុត្វា នាងសុជាតាបាន ស្ដាប់ពាក្យបុណ្ណទាសី ក៏មានចិត្តត្រេកអរ ស្រដីតបទៅ ថា "បើពិតដូច្នោះមែន, តាំងពីថ្ងៃនេះទៅនាងចូរឋិតនៅក្នុងទី ជាធីតានៃយើង" ទើបនាងសុជាតាឱ្យគ្រឿងប្រដាប់ទាំងពួង ដល់នាងបុណ្ណទាសីតាមសមគួរ ហើយឱ្យយកភាជនៈមាស មានតម្លៃ១សែនមកដាក់មធុបាយាស យកភាជនៈដទៃមកគ្រប ស្រេចរុំដោយសំពត់ស ។ នាងសុជាតាតែងខ្លួនស្រេចហើយ ឱ្យនាងបុណ្ណទាសីទូលភាជនៈដើរតាមក្រោយ ទៅដល់ដើម ព្រះជ្រៃ ក៏បានឃើញព្រះពោធិសត្វគង់នៅក្រោមដើមព្រះជ្រៃ នោះ ទើបលើកមធុបាយាសទៅថ្វាយ ។ បាត្រដីដែលឃដិការ មហាព្រហ្មថ្វាយក៏បាត់ទៅ ។ ព្រះពោធិសត្វងាករកបាត្រ មិនឃើញ ។

(៧) សា ពោធិសត្តស្ស អាការំ សល្លក្ខេត្វា នាង សុជាតាកំណត់ដឹងអាការនៃព្រះពោធិសត្វ ហើយនាងក៏ថ្វាយ ទាំងភាជនៈដោយពាក្យថា "សេចក្ដីប្រាថ្នានៃខ្ញុំសម្រេចហើយ, ខ្ញុំថ្វាយមធុបាយាសព្រមទាំងភាជនៈមាសនេះ" ហើយនាងក៏ ចៀសចេញទៅ ។ បំណែកខាងមហាបុរស ក៏ក្រោកចាក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

អាសនៈធ្វើប្រទក្សិណដើមព្រះជ្រៃបីជុំហើយ ព្រះអង្គកាន់យកភាជនៈមាសនោះយាងទៅកាន់ស្ទឹងនេរញ្ជរា, ដល់ហើយព្រះអង្គដំកល់ភាជនៈទុកទៀបឆ្នេរស្ទឹង ទើបទ្រង់យាងចុះស្រង់ក្នុងស្ទឹង, ស្រង់ស្រេចហើយ ទ្រង់ស្លៀកដណ្តប់ត្រៃចីវរគង់បែរព្រះភក្ត្រទៅកាន់បុរត្ថិមទិស, ព្រះអង្គពូតមធុបាយាសជាពំនូតប៉ុនគ្រាប់ត្នោតបានចំនួន៤៩ពំនូត ។

(៨) សោ បរិភុញ្ជនបរិយោសានេ ព្រះបរមពោធិសត្តទ្រង់សោយមិនមានសល់ ស្រេចហើយទើបព្រះអង្គកាន់យកនូវសុវណ្ណភាជនៈ ទ្រង់អធិដ្ឋានថា "បើអាត្មាអញបានត្រាស់ជាព្រះពុទ្ធពិតប្រាកដក្នុងថ្ងៃនេះមែន, សូមឱ្យសុវណ្ណភាជនៈអណ្តែតប្រាសទឹកឡើងទៅ" ទើបព្រះអង្គបណ្តែតទៅក្នុងស្ទឹង ។ ភាជនៈនោះហាក់បីដូចជាមានចេតនា ក៏អណ្តែតប្រាសទឹកឡើងទៅដើម្បីសំដែងនូវសព្វញ្ញុតញ្ញាណនិមិត្ត, លុះអណ្តែតប្រាសទឹកទៅបាន៨០ហត្ថហើយ ក៏លិចចុះក្នុងអន្លង់មួយជាទីជិតពិភពកាឡនាគ ទង្គិចនឹងភាជនៈព្រះពុទ្ធ៣ព្រះអង្គពីបុរាណៗ សូរក្រិកៗ ហើយសៀតស៊កទ្រពីខាងក្រោមភាជនៈទាំង៣នោះ។

Websites: WatKhemaraRatanaram.org or WatKhmers.org

(៩) កាឡនាគរាជា តំ សុត្វា បពុជ្ឈិត្វា ស្តេច កាឡនាគ បានឮសូរភាជនៈទង្គិចគ្នា ក៏ភ្ញាក់ឡើងគិតថា "ពីថ្ងៃម្សិលមិញព្រះពុទ្ធបានត្រាស់ ១ ព្រះអង្គ ថ្ងៃនេះព្រះពុទ្ធបានត្រាស់១ព្រះអង្គទៀតហើយ" ទើបទៅជិតភាជនៈមាសពោលសរសើរព្រះពុទ្ធគុណ ។

បំណែកខាងព្រះពោធិសត្វ ទ្រង់សម្រាកព្រះកាយក្នុងសាលវ័នទៀបឆ្នេរស្ទឹង, លុះដល់សាយណ្ហសម័យ ព្រះអង្គយាងបាកសាលវ័ន ។ ពពួកទេវតាក៏ធ្វើសក្ការៈដោយទិព្វមាលា ។ ពពួកទេវតាក្នុងលោកធាតុទាំង ១ ហ្មឺន ក៏ថ្វាយស័ព្ទសាធុការបូជាដោយផ្ការភ្ញី ។ ព្រះអង្គទ្រង់យាងឆ្ពោះទៅកាន់ពោធិព្រឹក្ស ។

(១០) តស្មឹ សមយេ ក្នុងសម័យនោះ សោត្ថិយព្រាហ្មណ៍ អ្នកប្រួតស្មៅ[១] បានឃើញ ព្រះពោធិសត្វហើយ ក៏ថ្វាយស្មៅ ។ ព្រះពោធិសត្វទ្រង់ស្តេចទៅដល់ពោធិព្រឹក្ស ប្រទក្សិណហើយគង់នៅត្រង់ទក្ខិណទិស, បស្ចិមទិស, ឧត្តរទិស តាមវារៈទ្រង់

១ ពីដើមធ្លាប់ប្រែថា ស្បូវភ្លាំង ។តែពីកាល ព.ស. ២៤៩៣ សម្តេចព្រះសង្ឃនាយក (ជួន-ណាត) និមន្តទៅឥណ្ឌៀបានសង្កេតឃើញថាវត្ថុនោះជាស្មៅទេ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ទី

Websites: WatKhemaraRatanaram.org or WatKhmers.org

បែរព្រះភក្ត្រទៅកាន់ពោធិព្រឹក្ស ។ ចក្កវាឡក្នុងទិសនោះៗ ក៏ញាប់ញ័របើដូចជាក្រាបទូលថា "ទីនេះមិនមែនជាទីកើតរតនបល្ល័ង្កទេ" ។ ព្រះអង្គទ្រង់ជ្រាបហេតុនោះហើយ ទើបយាងទៅគង់ខាងបុរត្ថិមទិសបែរព្រះភក្ត្រ ទៅកាន់ទិសបស្ចិម ។ ទីនោះមិនបានញាប់ញ័រ ។ ព្រះអង្គក៏សន្និដ្ឋានថា "ទីនេះជាទីកើតបល្ល័ង្ក" ទើបទ្រង់ក្រាលនូវស្មៅតាមធម្មតា ។ តិណជាតិនឹងកើតជារតនបល្ល័ង្កក៏ទេ ។ ឯវជិរាសនៈដ៏ហើយដោយកែវវជិរកំពស់១៤ហត្ថ ក៏ផុសឡើងក្នុងកាលនោះ ។

(១១) ពោធិសត្តោ រតនបល្លង្កំ ទិស្វា ព្រះពោធិសត្តឃើញរតនបល្ល័ង្កហើយ ឡើងគង់ទ្រង់អធិដ្ឋានព្យាយាមប្រកបដោយអង្គ៤ថា "ស្បែកសរសៃឆ្អឹងឈាមនៃយើងចូរវិងស្ងួតអស់ទៅចុះ, បើអាត្មាអញមិនបានត្រាស់ទេ, នឹងមិនក្រោកបាករតនបល្ល័ង្កនេះឡើយ" ទ្រង់អធិដ្ឋានស្រេចហើយ ទើបបែរព្រះបិដ្ឋិទៅកាន់ដើមពោធិព្រឹក្សដ៏មានកំពស់៥០ហត្ថ ។ ក្នុងកាលនោះ សក្កទេវរាជកាន់យកស័ង្ខមកផ្លុំថ្វាយ ។ គន្ធព្វទេវបុត្រយកពិណមកប្រគំថ្វាយ ។ សុយាមទេវបុត្រយកចាមរទិព្វមកបក់ថ្វាយ ។ សហម្បតិព្រហ្មយកស្វេតច្ឆត្តមក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

បាំងថ្វាយ ។ មហាកាឡនាគរាជក៏នាំយកនាងកញ្ញាមករាំថ្វាយ។ ទេវតាក្នុងបក្កវាឡទាំង១ហ្មឺន នាំយកទិព្វមាលាមកធ្វើសក្ការបូជា ថ្វាយស័ព្ទសាធុការដល់ព្រះបរមពោធិសត្វរាល់ៗ គ្នាហើយ ឈរនៅក្នុងទីនោះ ។

(ចប់ពុទ្ធបូជាបរិច្ឆេទ ទី៩)

---

## មារវិជយបរិច្ឆេទ ទី១០

(១) តស្មិំ សមយេ មារោ ទេវបុត្តោ ក្នុងសម័យនោះ ទេវបុត្តមារមានចិត្តបាបគិតក្នុងចិត្តថា "ព្រះសិទ្ធត្ថរាជកុមារនេះប្រាថ្នាដើម្បីកន្លងនូវវិស័យនៃអញ, ឥឡូវអញមិនឱ្យព្រះសិទ្ធត្ថនេះកន្លងបានទេ" ទើបមារកេណ្ឌសេនាឃោសនានាំមារពលចេញមក ។ ឯសេនានៃមារនោះកម្រាសខាងមុខ១២យោជន៍ ខាងឆ្វេងស្តាំ១២យោជន៍ដូចគ្នា ។ មារសេនាទាំងអម្បាលនោះក៏ឋិតនៅដេរដាសពាសពេញផែនដីរាបដល់កណ្តាប់បក្កវាឡ ។ មារសេនាបំណែកខាងលើ មានប្រមាណ៩យោជន៍ ។ សម្លេងដែលមារឃោសនានោះ ឮខ្ទរខ្ទាយទៅចម្ងាយ១សែនយោជន៍ដោយជុំវិញ បីដូចជាសន្ធឹកក្រើកផែនដីទាំងមូល ។

(២) មារោ ទេវបុត្តោ បញ្ញាសាធិកយោជនសតុព្វេធំ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

មារទេវបុត្រ ឡើងជិះលើដំរីគិរីមេខលមានកំពស់១៥០យោជន៍ និម្មិតដៃមួយពាន់ កាន់គ្រឿងអាវុធមានប្រការផ្សេងៗ ។ បំណែកមារសេនាសោតក៏និម្មិតកាយផ្សេងៗ មានវណ្ណៈខៀវ លឿងជាដើម មានដៃកាន់គ្រឿងអាវុធផ្សេងៗគ្នា ។ មារសេនាពួកខ្លះមានខ្លួនជាសត្វមានក្បាលជាយក្ស, ជំពូកខ្លះមានខ្លួនជាយក្សមាន ក្បាលជាសត្វម្រឹគនឹងបក្សីជាដើម មានកាយខ្ពស់ផ្សេងៗគ្នា, ជំពូកខ្លះកំពស់១គាវុត, ខ្លះ២គាវុត, ខ្លះ៣គាវុត, ខ្លះ១យោជន៍ ដើរបួលទៅកាន់ពោធិមណ្ឌលរាល់ៗគ្នា ។

(៣) មារេ ពោធិមណ្ឌលំ អសម្បត្តេ ឆាកាលមារនឹងពលនៃមារមិនទាន់ដល់ពោធិមណ្ឌលនៅឡើយ, ទេវតាទាំងឡាយដែលនៅក្នុងចក្កវាឡទាំង១ហ្មឺន ដែលមកចោមរោមព្រះបរមពោធិសត្តគ្រាន់តែឮសម្លេងសន្ធឹកគឹកកងនៃមារសេនាលើកមក ក៏រត់ទៅកាន់ទីជនៃទផ្សេងៗ ។ បំណែកសក្កទេវរាជក៏កាន់សង្ខវិជយុត្ត លាក់ក្រោយខ្នងរត់ទៅឈរនៅលើភ្នំចក្កវាឡ។ មហាព្រហ្មក៏ចាប់កំពូលស្វេតច្ឆ័ត្របោះរត់ទៅ ។ ស្តេចកាឡនាគក៏នាំកញ្ញាទាំងអស់ រត់ជ្រែកដីចុះទៅកាន់ពិភពនាគមានប្រមាណ៥០០យោជន៍យកដៃខ្ទប់មុខដេក ។ កាលបើទេវតា

Websites: WatKhemaraRatanaram.org or WatKhmers.org

រត់ទៅអស់, ព្រះបរមពោធិសត្តគង់នៅតែមួយអង្គឯង បីដូចជាមហាព្រហ្មបិតនៅក្នុងវិមាន មិនខ្លាចនូវមារពលនោះឡើយ ។

(៤) អថ មារោ អត្តនោ បរិសំ អាហ លំដាប់នោះ មារាធិរាជក៏ស្រែកប្រាប់សេនាជាបរិស័ទនៃខ្លួនថា "ម្នាលអ្នករាល់គ្នា បុរសដទៃស្មើនឹងព្រះសិទ្ធត្ថនេះគ្មានទេ, យើងមិនអាចនឹងធ្វើសង្គ្រាមក្នុងទីបំពោះមុខនៃសិទ្ធត្ថនេះបានឡើយ, យើងចូលទៅបានតែខាងឆ្វេង ខាងស្តាំនឹងខាងក្រោយប៉ុណ្ណោះ" ។ ឯមហាបុរសទ្រង់ទតទៅឃើញទិសទាំងបីស្ងាត់ ព្រោះទេវតារត់ទៅអស់ ទ្រង់ឃើញមារពលលើកមកខ្ទាត់ខ្ទាប់អំពីទិសឧត្តរ ទើបទ្រង់ព្រះចិន្តាថា "ជនទាំងអម្បាលនេះ លះបង់អាត្មាអញរត់ទៅអស់ ឱ្យតែអាត្មាអញនៅម្នាក់ឯង, មាតាបិតាបងប្អូនញាតិសន្តាននៃអាត្មាអញឯណាៗនីមួយមិនមានឡើយ, បារមីនៃអាត្មាអញទាំង ១០ប្រការនេះ ដូចជាជនជាបរិវារនៃអាត្មាអញអស់កាលជាយូរណាស់មកហើយ" ។ ព្រះអង្គនឹងបារមីទាំង១០ប្រការស្រេចហើយគង់នៅព្រងើយ ។

(៥) អថ មារោ ទេវបុត្តោ លំដាប់នោះ ទេវបុត្តមារក៏បណ្ដាលនូវមណ្ឌលខ្យល់ឱ្យតាំងឡើងដោយគិតថា "អញនឹង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យព្រះសិទ្ធត្ថនេះរត់ចេញដោយខ្យល់នេះ" ។ ឯខ្យល់នោះខ្លាំងណាស់ អាចបក់បោកបំបាក់កំពូលភ្នំបាន, លុះមកដល់ព្រះពោធិសត្តក៏មិនអាចនឹងបក់ សូម្បីតែជាយចីវរឱ្យកំរើកបាន ។ លំដាប់នោះ ទេវបុត្រមារក៏បណ្ដាលភ្លៀងធំ, ភ្លៀងដុំថ្ម, ភ្លៀងគ្រឿងប្រហារ, ភ្លៀងរងើកភ្លើង, ភ្លៀងផេះក្ដៅ,ភ្លៀងដីខ្សាច់, ភ្លៀងភក់, បណ្ដាលឱ្យងងឹតផ្សែងអ័ព្ទអស់ទិសទាំង៤, សភាវៈទាំងឡាយមានខ្យល់ជាដើមនោះ មិនអាចបៀតបៀនព្រះពោធិសត្តបានឡើយ, ត្រឡប់ក្លាយទៅគ្រឿងបូជាវិញ ។

(៦) ឯវំ មារោ ឥមាហិ នវហិ វាតវុដ្ឋីហិ ឯមារាធិរាជ មិនអាចដើម្បីឱ្យព្រះពោធិសត្តរត់ទៅដោយហេតុទាំង៩ប្រការ មានខ្យល់នឹងភ្លៀងជាដើមបាន ទើបបង្គាប់ពួកពលសេនាឱ្យចូលទៅចាប់ព្រះបរមពោធិសត្ត សម្លាប់ឬបណ្ដេញឱ្យរត់ចេញទៅ ។ បំណែកក្រុងមារ ក៏ឡើងអង្គុយលើដំរីមានដៃកាន់យកអាវុធ១ពាន់ បរដំរីចូលទៅជិតហើយពោលថា "នែសិទ្ធត្ថ! ចូរអ្នកក្រោក ចេញចាករតនបល្ល័ង្កនេះៗ មិនត្រូវបានអ្នកទេ, ត្រូវបានយើងទេតើ" ។ ព្រះពោធិសត្តក៏ពោលតបទៅមារថា "ម្នាលមារអើយ! បារមីទាំង ៣០ប្រការ មហា-

Websites: WatKhemaraRatanaram.org or WatKhmers.org

បរិច្ចាគ៥ ចរិយា ៣ប្រការ អ្នកឯងមិនបានបំពេញទេ,បល្ល័ង្ក នេះមិនមែនកើតឡើងសម្រាប់អ្នកទេ, បល្ល័ង្កនេះកើតឡើង ដោយបុណ្យបារមីនៃយើងទេតើ” ។

(៧) មារោ បាបិមា រសិតមានសោ មារមាន ចិត្តបាបបានឬហើយ ក៏ខឹងក្រេវក្រោធ កាន់យកចក្រាវុធមាន មុខដ៏មុតបោលផ្ដរង់ទៅព្រះបរមពោធិសត្វ ។ ឯចក្រាវុធក៏ក្លាយ ទៅជាពិតានឋិតនៅខាងលើព្រះបរមពោធិសត្វ ។ បំណែកមារ បរិស័ទក៏លើកយកកំពូលភ្នំធំៗ បោលទៅសំដៅព្រះពោធិសត្វ ។ កំពូលភ្នំក៏ក្លាយទៅជាមាលាបុប្ផាវិញ ។ បំណែកទេវតាដែលរត់ បោលព្រះពោធិសត្វទៅឈរលើភ្នំចក្រវាឡចាំមើល ក៏គិតគ្នាថា “ប្រហែលជាព្រះសិទ្ធត្ថនោះវិនាសទៅដោយដៃមារហើយដឹង” ។ ព្រះមហាបុរសទ្រង់ព្រះចិន្ដាថា “បល្ល័ង្កដែលកើតដល់ពោធិសត្វ ទាំងឡាយក្នុងថ្ងៃជាទីត្រាស់ដឹង បានកើតដល់អាត្មាអញ” ទើបទ្រង់សួរទៅមារថា “អ្នកណាជាបន្ទាល់របស់អ្នក?” មារក៏តបថា “ពួកពលសេនាទាំងឡាយនេះបន្ទាល់ របស់យើង” ។ ពោធិសត្វតបទៅថា “មារអើយ, បន្ទាល់របស់ អ្នកសុទ្ធសឹងមានចេតនា, បុគ្គលណាជាបន្ទាល់នៃយើងមិន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

មាន”, ព្រះអង្គនឹកដល់ទានដែលព្រះអង្គឱ្យហើយក្នុងកាលកើតជាព្រះវេស្សន្តរ, ទើបព្រះអង្គបញ្ចេញព្រះហស្តពីក្នុងចំវរបង្អុលទៅផែនដីហើយតបទៅថា “មារអើយ, មកហាប្រឹថពីនេះ ជាបន្ទាល់របស់យើង” ។ ផែនដីក៏លាន់ឮសម្លេងឡើង ហាក់ដូចជាក្រាបទូលថា “យើងខ្ញុំជាបន្ទាល់ព្រះអង្គ” ។

(៨) តតោ មហាបុរិសោ លំដាប់នោះ មហាបុរសពិចារណាទានបារមី ដែលព្រះអង្គឱ្យដំរីក្នុងកាលដែលទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ។ ឯដំរីនាឡាគិរីនោះក៏ទប់ទល់មិនបានទន់ជង្គង់លុតចុះលើផែនដី ។ មារសោតក៏លើកដៃទាំង១ពាន់ដាក់លើសិរសាពោលដោយគាថា ថា:

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆិន្នោ តិណ្ណោ តារេហិ មំ បជន្តិ

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ, ក្នុងលោកនេះព្រមទាំងទេវលោក មិន

Websites: WatKhemaraRatanaram.org or WatKhmers.org

មានបុគ្គលណាមួយប្រៀបផ្ទឹមស្មើនឹងព្រះអង្គបានឡើយ, ព្រះអង្គជាព្រះពុទ្ធ, ព្រះអង្គជាសាស្តាចារ្យ, ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់គ្របសង្កត់នូវពួកមារ, ព្រះអង្គជាអ្នកកាត់ផ្តាច់នូវអនុសយក្កិលេស ទ្រង់ឆ្លងផុតបាកសង្សារហើយ សូមទ្រង់ចម្លងនូវខ្ញុំព្រះអង្គជាសត្វផង ។

មារនមស្សការហើយហោះរត់ទៅ ។ មារសេនារត់ទៅកាន់ទីដទៃៗ ។ បំណែកទេវតា បានឃើញមាររត់ទៅដូច្នោះ ក៏ប្រឹក្សាគ្នាថា "មារបរាជ័យចាញ់មហាបុរសរត់ទៅអស់ហើយ, ព្រះសិទ្ធត្ថនៃយើងមានជ័យឈ្នះមារហើយ" គិតហើយក៏កាន់យកនូវគន្ធមាលា ហោះចុះមកកាន់ពោធិបល្ល័ង្ក មានចិត្តត្រេកអរ ក៏ស្រែកឃោសនាថ្វាយជ័យរាល់ៗគ្នាក្នុងគ្រានោះ ។

(ចប់មារវិជយបរិច្ឆេទ ទី១០)

---

## អភិសម្ពោធិបរិច្ឆេទ ទី១១

(១) មហាបុរិសោ សុរិយេ អនត្ថង្គតេ ឯវំ មារពលំ វិធមេត្វា នាកាលព្រះអាទិត្យកំពុងអស្តង្គតនៅឡើយ, ព្រះមហាបុរសកំចាត់បង់នូវពលនៃមារដោយបារមី ស្រេចហើយ ស្លឹកពោធិព្រឹក្សមានវណ្ណៈប្រាកដដូចជាកែវពពាឡ កែវទទឹម ក៏រុះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

បុះធ្លាក់មកបូជា ។ លុះដល់បឋមយាម ព្រះពោធិសត្តបាននូវបុព្វេនិវាសានុស្សតិញ្ញាណ មានប្រការដ៏ច្រើនដោយអំណាចព្រះអង្គរលឹកនូវខន្ធសន្តាន ដែលធ្លាប់អាស្រ័យនៅហើយក្នុងកាលមុន គឺទ្រង់រលឹកតាំងអំពីជាតិទី១ ទី២ ដរាបដល់សែនជាតិនឹងសំវដ្តកប្ប វិវដ្តកប្ប ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសព្រមទាំងគោត្រត្រកូលអាហារ ព្រមទាំងការសោយនូវសេចក្តីសុខទុក្ខព្រមទាំងកំណត់អាយុ ។

(២) មជ្ឈិមយាមសមន្តរេ លុះដល់មជ្ឈិមយាម ព្រះអង្គទ្រង់ជម្រះនូវទិព្វចក្ខុ បាននូវចុតូបបាតញ្ញាណឃើញដោយទិព្វចក្ខុនូវសត្វដែលច្យុតនឹងកើត ថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ដែលប្រព្រឹត្តទៅតាមយថាកម្ម គឺឃើញថា “ឱហ្ន៎! សត្វទាំងឡាយនេះប្រកបដោយកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈ ជាមនុស្សមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិកម្ម, នោះលុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងអបាយ ទុគ្គតិ វិនិតបាត នរក, មួយវិញទៀត សត្វទាំង-ឡាយដែលប្រកបដោយ កាយសុចរិត វចីសុចរិត មនោសុចរិត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាអ្នកមិនតិះដៀលនូវព្រះអរិយៈ ជាមនុស្សសម្មាទិដ្ឋិ សមាទាននូវសម្មាទិដ្ឋិកម្ម, នោះលុះទំលាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិសួគ៌ទេវលោក”

(៣) តទនន្តរំ ញាណំ ឱតារេត្វា លំដាប់អំពីមជ្ឈិមយាមនោះមក ព្រះមហាបុរសទ្រង់ញុំាងញាណឱ្យចុះកាន់បច្ចយាការៈ គឺបដិច្ចសមុប្បាទធម៌ ក្នុងយាមជាទីបំផុត ។ ព្រះមហាបុរសទ្រង់ពិចារណាថា “សត្វលោកដែលដល់នូវសេចក្ដីលំបាកដោយកើត ចាស់ ឈឺ ស្លាប់ ហើយកើតទៀត ព្រោះមិនបានដឹងនូវឧបាយ សម្រាប់រលាស់ខ្លួនបាកទុក្ខនេះ” ទើបព្រះអង្គមានបរិវិតក្កថា “អ្វីហ្ន៎មាន! ទើបជរានឹងមរណៈមាន? ជរានឹងមរណៈតើមានអ្វីជាបច្ច័យ? យោនិសោមនសិការៈក៏កើតមានដល់ព្រះអង្គថា “កាលបើជាតិមានហើយ, ជរានឹងមរណៈក៏មាន, ជរានឹងមរណៈមានជាតិជាបច្ច័យ ។

(៤) អបិស្សុ ឯតទហោសិ ទើបព្រះអង្គមានបរំវិតក្កទៅទៀតថា “អ្វីមាន, ទើបជាតិមាន? ជាតិតើមានអ្វីជាបច្ច័យ? ព្រះអង្គទ្រង់ជ្រាបថា “កាលបើភពមាន, ទើបជាតិមាន, ជាតិមានភពជាបច្ច័យ ។ ភពមានឧបាទានជាបច្ច័យ, ឧបា-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទានមានតណ្ហាជាបច្ច័យ, តណ្ហាមានវេទនាជាបច្ច័យ, វេទនាមានផស្សៈជាបច្ច័យ, ផស្សៈមានសឡាយតនៈជាបច្ច័យ, សឡាយតនៈមាននាមរូបជាបច្ច័យ, នាមរូបមានវិញ្ញាណជាបច្ច័យ, វិញ្ញាណមានសង្ខារជាបច្ច័យ, សង្ខារមានអវិជ្ជាជាបច្ច័យ ។ ព្រះអង្គពិចារណារកឫសគល់ នៃសេចក្តីទុក្ខឃើញដូច្នោះហើយ ទើបពិចារណាអនុលោមបណ្តោយទៅវិញថា "សង្ខារមានអវិជ្ជាជាបច្ច័យ, វិញ្ញាណមានសង្ខារជាបច្ច័យ, នាមរូបមានវិញ្ញាណជាបច្ច័យ, សឡាយតនៈមាននាមរូបជាបច្ច័យ, ផស្សៈមានសឡាយតនៈជាបច្ច័យ, វេទនាមានផស្សៈជាបច្ច័យ, តណ្ហាមានវេទនាជាបច្ច័យ, ឧបាទាន មានតណ្ហាជាបច្ច័យ, ភពមានឧបាទានជាបច្ច័យ, ជាតិមានភពជាបច្ច័យ, ជរានឹងមរណៈមានជាតិជាបច្ច័យ, សេចក្តីសោកខ្សឹកខ្សួលទុក្ខទោមនស្សតានតឹងក្នុងចិត្តក៏កើតឡើងព្រម" ។

បក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ដែលព្រះអង្គមិនធ្លាប់ស្តាប់ក្នុងកាលមុន ក៏កើតឡើង ដល់ព្រះអង្គ ។

(៥) អបិស្ស ឯតទហោសិ លំដាប់នោះ ព្រះពោធិសត្វទ្រង់មានបរិវិតក្កថា "កាលបើអ្វីហ្ន៎មិនមាន, ទើបជរានឹង

Websites: WatKhemaraRatanaram.org or WatKhmers.org

មរណៈមិនមាន? ការរលត់នូវជរាតឹងមរណៈព្រោះរលត់នូវអ្វី”? យោនិសោមនសិការៈកើតឡើងដល់ព្រះអង្គថា “ជរាមរណៈដែលនឹងរលត់ទៅព្រោះរលត់ជាតិ, ជាតិរលត់ទៅព្រោះរលត់ភព, ភពរលត់ទៅព្រោះរលត់ឧបាទាន, ឧបាទានរលត់ទៅព្រោះរលត់តណ្ហា ។ បេ ។ ការរលត់ទៅនៃកងទុក្ខនោះយ៉ាងនេះឯង ។ កាលដែលព្រះពោធិសត្តកំពុងពិចារណានូវបច្ចយាការៈដ៏ប្រកបដោយអង្គ១២ប្រការ ជាអនុលោមបដិលោម ដោយអំណាចនៃសេចក្តីវិនាស នឹងសេចក្តីចំរើនឡើងយ៉ាងនេះ, លោកធាតុទាំងមួយហ្មឺនក៏កម្បនាការ កំរើកអស់វារៈ១២ដង ដរាបដល់ទឹកទ្រទ្រង់ផែនដីជាទីបំផុត ។

(៦) មហាបុរិសោ ទសសហស្សលោកធាតុំ ឧន្នាទេត្វា ព្រះមហាបុរស ញុំាំងលោកធាតុមួយហ្មឺន ឱ្យកម្បនាការហើយ ព្រះអង្គក៏បានត្រាស់បំពោះសភាវធម៌ មានសង្ខតាសង្ខតធម៌ជាដើម ដោយបញ្ញាដែលកើតអំពីបារមីដ៏វិចិត្រដែលព្រះអង្គសន្សំមក, ព្រះអង្គប្រាសចាកផង្គុយជាទីប្រជុំនៃវាសនា ដល់នូវកិរិយារីករីសេស ដោយសព្វញ្ញុតញ្ញាណសម្បត្តិ ប្រកបដោយគុណរាប់មិនបាន ជាទីប្រជុំព្រមនៃមគ្គញ្ញាណដ៏ប្រសើរ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដូចជាផ្កាឈូករីក, ទ្រង់ប្រកបដោយសិរី សោភគ្គសម្បត្តិដ៏រុង-រឿងក្រៃពេក, ព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិធម៌ គឺទេវតា គ្រុឌ មនុស្ស ភុជង្គ គន្ធព្វ ញាំញីមិនបាន ក្នុងវេលារះឡើងនៃអរុណថ្ងៃ១រោចនោះ ។

(៧) តស្មិំ សព្វញ្ញុតំ បត្តេ នាកាលព្រះបរមពោធិសត្វដល់ហើយនូវភាវៈជាអង្គសព្វញ្ញូ, លោកធាតុទាំងមួយហ្មឺនសឹងប្រដាប់ដោយគ្រឿងប្រដាប់ គឺទង់ជ័យដែលទេវតាលើកឡើងក្នុងកណ្តាប់ចក្រវាឡខាងកើត ខាងលិច ខាងត្បូង ខាងជើង ។ ទង់ជាយទង់ជ្រុង ដែលទេវតាប្រតិស្ឋានតាំងពីលើផែនដីដរាបទល់នឹងព្រហ្មលោក ។ ដើមឈើប្រកបដោយផ្ការីកស្គុសស្គាយ ។ ផ្កាឈូកក៏រីកដាសពាសពេញ ។ ដើមឈើមែកឈើនឹងវល្លិ៍ក៏មានផ្កាសំយុងចុះ ។ ផ្កាឈូកដែលសំយុងចុះក្នុងអាកាសក៏មាន ។ ផ្កាឈូកដែលទំលាយផែនដីផែនថ្មផុះឡើងហើយរីកក៏មាន ។ លោកធាតុទាំងមួយហ្មឺនសឹងដេរដាសពាសពេញដោយផ្កាឈូក ។ ឯវំ ភគវា ព្រះដ៏មានព្រះភាគដែលទេវតាបូជាហើយដោយគ្រឿងសក្ការៈគណនាត្រារាប់មិនបានយ៉ាងនេះ!

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គបានដល់នូវសព្វញ្ញុតញ្ញាណហើយ ទើបទ្រង់បន្លឺនូវឧទានគាថា ដែលព្រះពុទ្ធទាំងពួងមិន បានលះបង់ថា:

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ
វិសំខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

សេចក្តីថា អាត្មាអញកាលមិនទាន់បានជួបប្រទះ (ពោធិញ្ញាណ) នៅឡើយ វង់តែស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ហើយអន្ទោលទៅកាន់សង្សារមានជាតិមិនតែមួយ, ជាតិគឺការកើតរឿយៗ រមែងនាំមកនូវសេចក្តីទុក្ខ, នែជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) យើងបានឃើញអ្នកច្បាស់ហើយ, អ្នកឯងនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ឱ្យយើងទៀតពុំបានឡើយ, ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នកឯង យើងបានបំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះគឺអវិជ្ជា របស់អ្នកឯងសោតទៀត យើងក៏បានបំបាក់ចោលហើយដែរ, ចិត្តរបស់យើងបានដល់នូវព្រះនិព្វានដែលមានសង្ខារទៅប្រាសហើយ, យើងបានដល់នូវព្រះ-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

អរហត្តគឺការអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

ព្រះអង្គ ក៏គង់លើរតនបល្ល័ង្កដែលទ្រង់បានត្រាស់នោះ អស់ ៧ថ្ងៃ ។ **ព្រះអង្គបានត្រាស់ក្នុងថ្ងៃពុធ ពេញបូណ៌មី ខែវិសាខ ឆ្នាំរកា ។**

(បប់អភិសម្ពោធិបរិច្ឆេទ ទី១១)

---

សន្តិកេ និទាន

ពោធិសព្វញ្ញូបរិច្ឆេទ ទី១២

(១) តេន ខោ បន សមយេន ឯកច្ចានំ ទេវតានំ បរិវិតក្កោ ឧទបាទិ ក៏ក្នុងសម័យនោះឯង បរិវិតក្កក៏កើតឡើងដល់ទេវតាជំពូកខ្លះថា “កិច្ចព្រះសិទ្ធត្ថប្របៃហលជាមានតែប៉ុណ្ណោះទេដឹង បានជាព្រះអង្គមិនលះអាល័យពីរតនបល្ល័ង្ក” ។ ព្រះអង្គទ្រង់ជ្រាបនូវបរិវិតក្កនៃទេវតាហើយ ទើបទ្រង់ហោះឡើងទៅកាន់អាកាស សំដែងនូវបាដិហារិយ៍កាត់បង់នូវសេចក្តីសង្ស័យនៃទេវតា ។ ឯបាដិហារិយ៍ដែលព្រះអង្គសំដែងនោះគឺ សំដែងគំនរភ្លើងនឹងទរនៃទឹក ឱ្យប្រព្រឹត្តទៅជាគូៗ គឺគំនរភ្លើងប្រព្រឹត្តទៅអំពីកាយខាងលើ ទរទឹកប្រព្រឹត្តទៅអំពីកាយខាងក្រោមជាដើម ដរាបដល់គំនរភ្លើងប្រព្រឹត្តទៅអំពីម្រាមព្រះបាទ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ **ប៊ិន សុផល**
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក **ជ្រុន ចន្ធី**

Websites: WatKhemaraRatanaram.org or WatKhmers.org

ទរទឹកប្រព្រឹត្តទៅអំពីចន្លោះម្រាមព្រះហស្តជាបរិយោសាន។

(២) ឯវំ ភគវា បច្ចេកពុទ្ធពុទ្ធសាវកានំ អសាធារណំ យមកប្បាដិហារិយំ ទស្សេត្វា ព្រះដ៏មានព្រះភាគ ទ្រង់សំដែងយមកប្បាដិហារិយ៍ជាគូៗ មិនបានទូទៅដល់ព្រះបច្ចេកពុទ្ធនឹងពុទ្ធសាវកដូច្នេះហើយ ទើបទ្រង់យាងចុះចាកអាកាសទៅគង់ នៅក្នុងចំណែកនៃទិសឦសាន ទ្រង់ព្រះបិន្តថា "សព្វញ្ញុតញ្ញាណ តថាគតបានហើយ លើរតនបល្ល័ង្ក" ទើបព្រះអង្គទ្រង់ទតរតនបល្ល័ង្កនោះដោយព្រះនេត្រ មិនបានប៉ប្រិចអស់៧ថ្ងៃ ។ ទីនោះមាននាមបញ្ញត្តិថា អនិមិសក-ចេតិយដ្ឋាន ។

(៣) តតោ បល្លង្កស្ស ច ឋិតដ្ឋានស្ស ច សំដាប់ពីនោះមក ព្រះអង្គនិម្មិតទីចង្ក្រមកែវដ៏វែងតាំងពីទិសបូព៌ដរាបដល់ទិសបស្ចិម ជាទីចន្លោះនៃរតនបល្ល័ង្កនឹងទីដែលព្រះអង្គឋិតនៅ, ព្រះអង្គយាងចង្ក្រមលើទីចង្ក្រមកែវនោះ ទ្រង់សោយវិមុត្តិសុខអស់ ៧ថ្ងៃទៀត ។ ទីនោះមាននាមបញ្ញត្តិថា រតន-ចេតិយដ្ឋាន ។

(៤) ចតុត្ថេ សត្តាហេ លុះដល់ថ្ងៃ ៧ ជាគំរប់ ៤ ដង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទេវតាទាំងឡាយនិម្មិត នូវផ្ទះកែវក្នុងបំណែកទិសពាយព្យអំពីពោធិព្រឹក្ស ។ ព្រះអង្គក៏យាងទៅគង់ក្នុងផ្ទះកែវនោះដោយព្រះភ្នែន ទ្រង់ពីចារណានូវអភិធម្មបិដកជាអនន្តន័យ គឺសមន្ត-បដ្ឋានដ៏វិសេស អស់ ៧ថ្ងៃ ។ ភិក្ខុទាំងឡាយដែលទ្រទ្រង់អភិធម្មនោះសំដែងថា ផ្ទះកែវមិនមាន, ទីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ពិចារណានូវសត្តប្បករណាភិធម្មនោះ មាននាមប្បញ្ញត្តិថារតនឃរដ្ឋាន ព្រោះហេតុនោះរតនឃរដ្ឋានមានភូមិភាគ គឺសតិ-បដ្ឋាន៤, ជាំបុះនូវសសរគឺឥទ្ធិបាទ៤, លើកឡើងនូវជញ្ជាំងគឺវិនយបិដក, ដាក់លើក្របគឺសម្មប្បធាន៤, តាំងទុកលើរតនឹងផ្ទៃគឺសមាបត្តិ៨, រៀបនូវរបៀបដ៏បូលខាងលើគឺសុត្តន្តបិដក, ប្រកបបូលដោយគ្រឿងប្រក់គឺអភិធម្មបិដក, ផ្ទះកែវរបស់ព្រះអង្គនោះជាវិការៈនៃព្រះសទ្ធម្មទាំងអស់ ។ អ្នកប្រាជ្ញគប្បីដឹងថារតនឃរៈនោះ ជាទីដែលព្រះអង្គពិចារណានូវបិដកទាំង៣ប្រកបដោយនិកាយ៥, អង្គ៩ ,ប្រដាប់ដោយធម្មក្ខន្ធ ៨៤.០០០ ។ ព្រះអង្គពិចារណានូវវិនយបិដក សុត្តន្តបិដក អភិធម្មបិដកដោយសព្វញ្ញុតញ្ញាណ ទើបព្រះអង្គមានរស្មីទាំង៦គឺខៀវ, លឿង, ក្រហម, ស, ហង្សបាទ ផ្លេកៗ (បម្រុះ) ផ្សាយចេញចាកព្រះកាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទូទៅសព្វទិសានុទិសទាំងពួង ។ ទ្រង់ពិចារណាដោយទំនងនេះអស់៧ថ្ងៃ ។ ទីនោះមាននាមបញ្ញត្តិថា រតនឃរចេតិយដ្ឋាន ។

(៥) បញ្ចម សត្តាហេ លុះដល់ថ្ងៃ៧ជាគំរប់៥ព្រះអង្គយាងចេញចាករតនឃរៈទៅកាន់ដើមអជបាលនិគ្រោធ ដល់ហើយព្រះអង្គក៏គង់ទ្រង់ពិចារណានូវព្រះសទ្ធម្ម ដែលព្រះអង្គបានត្រាស់ដឹង ប្រារព្ធដើម្បីធ្វើឱ្យវិចិត្រដោយអាការដ៏ច្រើន, ដ្បិតថា បុគ្គលទាំងឡាយដែលព្រះពុទ្ធគប្បីទូន្មានបានមាន៦ពួកដោយអំណាចនៃចរិតទាំង៦ប្រការ មានរាគចរិតជាដើម មានវិតក្កចរិត ជាបរិយោសាន, សត្វទាំងឡាយដែលផ្សេងគ្នា មាន៣ប្រការ ដោយអំណាចនៃឧគ្ឃដិតញ្ញូបុគ្គល វិបញ្ចិតញ្ញូបុគ្គល និង នេយ្យបុគ្គល ។ ព្រះអង្គទ្រង់ពិចារណាជ្រាបច្បាស់នូវសត្វដោយន័យដូច្នេះ ទើបទ្រង់ពិចារណានូវធម៌ដ៏វិចិត្រដែលព្រះអង្គត្រាស់ដឹង ទ្រង់សោយវិមុត្តិសុខគង់ក្រោមដើមជ្រៃនោះ ។ លំដាប់នោះ ទេវបុត្តមារជាអ្នកស្វែងរកនូវទោស ក៏ចូលទៅក្រាបទូលអារាធនាឱ្យព្រះអង្គបរិនិព្វាន ។ ព្រះអង្គតបថាមារអើយ, ភិក្ខុជាសាវ័កតថាគតមិនទាន់មាននៅឡើយ, បើសាវ័កតថាគតមាន បានទាំងប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ហើយ, តថាគត

Websites: WatKhemaraRatanaram.org or WatKhmers.org

ក៏មិនទាន់បរិនិព្វានដែរ ។ កាលបើព្រះអង្គមិនព្រម, មារក៏មាន
បិត្តទោមនស្សទៅអង្គុយក្នុងផ្លូវធំ គូសគំនូស១៦ លើផែនដីគិត
នូវន័យផ្សេងៗ មានទានបារមីដែលខ្លួនមិនបានកសាងជាដើម។
លំដាប់នោះមារធីតា ទាំង៣ គឺនាងតណ្ហា១ អរតី១ រាគា១
ចុះមករកបិតាឃើញកំពុងកើតទុក្ខ ក៏ធានាថានឹងទៅល្បួងលោម
បង់ព្រះអង្គ កាលបើបិតាឃាត់, ក៏មិនព្រម បបេសតែទៅ លុះ
ដល់ហើយក៏ក្លែងភេទផ្សេងៗ ល្បួងលោមបាញ់បំណោះក៏ត្រឡប់
ទៅកាន់ទេវលោកវិញ ។ ព្រះអង្គគង់សោយវិមុត្តិសុខក្នុង
ទីនោះ អស់៧ថ្ងៃ ។

(៦) អថ ខោ ភគវា អជបាលនិគ្រោធមូលា ឧដ្ឋាយ
លំដាប់នោះឯង ព្រះដ៏មានព្រះភាគក្រោកចាកគល់អជបាល-
និគ្រោធយាងទៅកាន់មុចលិន្ទស្រះ, លុះដល់ហើយទ្រង់គង់នៅ
ទៀបស្រះនោះដោយវិមុត្តិសុខ ។ មហាកាលមេឃក៏បង្អុរទឹក
ភ្លៀងឱ្យធ្លាក់ចុះមកក្នុងបក្ខវាទ្ស ។ ស្តេចនាគឈ្មោះមុចលិន្ទបេញ
ចាកស្រះឡើងមកនិម្មិតកាយដ៏ធំ ពេនព័ទ្ធជុំវិញ ហើយបើកពពារ
បាំងគ្របខាងលើព្រះសិរសាព្រះសាស្តា ដើម្បីការពារខ្យល់
ភ្លៀង កំដៅថ្ងៃ ។ ព្រះដ៏មានព្រះភាគគង់សោយវិមុត្តិសុខក្នុង

Websites: WatKhemaraRatanaram.org or WatKhmers.org

ទីនោះអស់៧ថ្ងៃ ។

(៧) សត្តមេ សត្តាហេ ក្នុងថ្ងៃ៧ជាគំរប់៧ផង ព្រះដ៏មានបុណ្យ យាងចាកទីនោះទៅគង់នៅក្រោមដើមកែសដោយឯកបល្ល័ង្ក អស់៧ថ្ងៃទៀត ដើម្បីសោយវិមុត្តិសុខ ។ រាប់ថ្ងៃតាំងពីព្រះអង្គគង់ក្រោមដើមកែស ផ្សំទាំងអស់ត្រូវជា៤៩ថ្ងៃគត់ ។ លំដាប់ពីនោះមក សក្កទេវរាជនាំយកផ្លែសម៉ទិព្វមកថ្វាយ ។ ព្រះសាស្តាទ្រង់ទទួលយកមកសោយ ។ ហេតុដែលព្រះអង្គសោយនូវផ្លែសម៉នោះ សរីរវលញ្ជៈក៏កើតមានឡើងដល់ព្រះអង្គ។ សក្កទេវរាជបានយកឈើស្ទន់នឹងទឹកខ្ពុរព្រះឱស្ឋទៅថ្វាយ ។ ព្រះអង្គទ្រង់ខ្ពុរព្រះឱស្ឋជម្រះស្រេចហើយ ទ្រង់គង់ក្រោមដើមកែសនោះ ។

(៨) តេន ខោ បន សមយេន ក្នុងសម័យនោះមានពាណិជ២នាក់ ជាបងប្អូននឹងគ្នា បងឈ្មោះតបុស្ស ប្អូនឈ្មោះភល្លិក បាននាំពួកឈ្មួញរទេះ៥០០ ផ្ទុកដោយទំនិញទៅលក់ឯឧត្តរាបថជនបទក្នុងមជ្ឈិមប្រទេស លុះដល់ដងព្រៃនោះមានទេវតាមួយអង្គ ជាញាតិសាលោហិតនៃពាណិជទាំងពីរនាក់អំពី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុជល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាតិមុន ដែលអាស្រ័យក្នុងដងព្រៃ ប្រាប់ពាណិជថា ម្នាលពាណិជ, ឥឡូវនេះព្រះពុទ្ធបានត្រាស់បរមាភិសេកហើយ, ព្រះអង្គគង់នៅក្រោមដើមកែស, អ្នកចូរចូលទៅកាន់សំណាក់ព្រះអង្គធ្វើនមស្សការ ហើយថ្វាយនូវសត្តុរជុំសត្តុវផង់ដល់ព្រះអង្គ នឹងបានផលប្រយោជន៍នាំមកនូវសេចក្ដីសុខ អស់កាលជាអង្វែង ។

(៩) អថ ខោ តបុស្សភល្លិកា វាណិជា លំដាប់នោះពាណិជទាំងពីរនាក់បានស្ដាប់ពាក្យទេវតា ក៏កើតសេចក្ដីជ្រះថ្លា ទើបកាន់យកសត្តុវនាំទៅថ្វាយព្រះអង្គ, ដល់ហើយថ្វាយបង្គំទូលថា "បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះអង្គទទួលនូវសត្តុវនៃយើងខ្ញុំ ដើម្បីប្រយោជន៍នឹងសេចក្ដីសុខអស់កាលជាយូរអង្វែង" ។ ព្រះអង្គទ្រង់ព្រះបិន្តាថា បាត្រតថាគតបាត់ទៅហើយក្នុងថ្ងៃដែលទទួលមធុបាយាស, តថាគតមិនគួរទទួលអាមិសដោយដៃ តថាគតនឹងបាននូវភាជនៈឯណាទទួល" ។ លំដាប់នោះ ចតុលោកបាលទាំង៤បានដឹងបរិវិតក្ក ក៏នាំយកបាត្រថ្មកែវឥន្ទនិល ៤មកថ្វាយ ។ ព្រះអង្គមិនទទួល ។ ចតុលោកបាលក៏បង្អោនបាត្រថ្មមានវណ្ណៈដូចសណ្ដែកបាយទៅថ្វាយម្ដងទៀត ។ ទើប

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់ទទួលដើម្បីអនុគ្រោះដល់ស្ដេចទាំង៤, ទ្រង់ផ្គួតលើគ្នា ហើយអធិដ្ឋាននូវបាត្រ១ ទើបទ្រង់ទទួលនូវសត្តុវហើយ សោយ ។ លំដាប់នោះពាណិជទាំងពីរនាក់ក៏សំដែងខ្លួនជា ឧបាសកដល់នូវទ្វេវាចិកសរណគមន៍ ។ ពាណិជទាំងពីរនាក់ នោះជាបឋមឧបាសក ក្នុងព្រះពុទ្ធសាសនា ។

(១០) អថ តេ វាណិជា លំដាប់នោះ ពាណិជទាំងពីរ នោះទូលសូមនូវវត្ថុជាទីធ្វើសក្ការបូជា ។ ព្រះសម្មាសម្ពុទ្ធទ្រង់បរា-មាសព្រះសិរសា ក៏ព្រះកេសធាតុ៨សរសៃជាប់នឹងព្រះហស្ដមក ព្រះអង្គព្រះរាជទានដល់ពាណិជទាំងពីរ ។ ឯពាណិជក៏ទទួល យកព្រះកេសធាតុ ទាំង៨សរសៃ នាំយកទៅកាន់នគរនៃខ្លួន, ដល់ហើយក៏រៀបចំតាក់តែងទីទួលសិង្គុត្តរ ធ្វើចេតិយបញ្ចុះទុក ធ្វើសក្ការបូជាតាមបណ្ដាំព្រះអង្គ ។ កាលដែលពាណិជនឹងបញ្ចុះ នោះ ព្រះបាទឧបលាបរាជ ជាឧបត្ថម្ភកៈប្រកបដោយសេចក្ដី អស្ចារ្យ, ពួកទេវតាមានសក្កទេវរាជជាដើម ក៏មកជួយរៀបចំ, ពួក មនុស្សមានព្រះបាទឧបលាបរាជជាដើម មកជួយខ្វល់ខ្វាយខ្វាយ ។ ឯព្រះកេសធាតុសោត ក៏សំដែងនូវបាដិហារយ៍ផ្សេងៗ ។ ទេវតានិងមនុស្ស ក៏ធ្វើសក្ការៈដោយវត្ថុមានមាសប្រាក់ជាដើម

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយចិត្តជ្រះថ្លា ។ ចេតិយនោះមាននាមបញ្ញត្តិថា សិង្គុត្តរ-ចេតិយ ។ ទីទួលនោះជាទីបញ្ចុះទុកនូវគ្រឿងបរិក្ខារព្រះពុទ្ធទាំង៤ព្រះអង្គក្នុងភទ្ទកប្បនេះគឺ បញ្ចុះធមក្រករបស់ព្រះកក្កុសន្ធ វត្ថពន្ធរបស់ព្រះកោនាគមន សាដករបស់ព្រះកស្សប និងព្រះកេសធាតុ ៨ សរសៃរបស់ព្រះគោតម ។

(បប់ពោធិសព្វញ្ញុបរិច្ឆេទ ទី១២)

---

## ព្រហ្មផ្សែសនបរិច្ឆេទ ទី១៣

(១) អថ ខោ ភគវា តម្ហា រាជាយតនមូលា ឧដ្ឋហិត្វា លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់ក្រោកបាកគល់រាជាយតនៈនោះ យាងទៅគង់ក្រោមដើមអជបាលនិគ្រោធវិញ ។ កាលដែលព្រះអង្គគង់ក្នុងទីនោះទ្រង់បរិវិតក្កថា “ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះ ជាគម្ភីរភាពជ្រាលជ្រៅឆ្ងាយទូលាយណាស់ ដែលព្រះពុទ្ធទាំងឡាយសន្សំហើយ ជាធម៌គឺសត្វទាំងឡាយឃើញដោយកម្រ ត្រាស់ដឹងដោយកម្រ ធម៌នេះល្អិតសុខុមណាស់ ឧត្តមប្រសើរណាស់ ដ៏ពេញដោយមិនសល់ គឺបណ្ឌិតជាតិគប្បីសំដែង” ព្រះអង្គបរិវិតក្កដូច្នេះហើយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ក៏ដល់នូវសេចក្តីខ្វល់ខ្វាយតិច មិនមានព្រះទ័យប្រាថ្នាដើម្បីសំដែងនូវធម៌ដល់សត្វទាំងឡាយ ទ្រង់គង់ស្ងៀមព្រងើយ ។

(២) អថ ខោ សហម្បតី ព្រហ្មា លំដាប់នោះ សហម្បតីព្រហ្មបានដឹងបរិវិតក្កនៃព្រះអង្គ ក៏បញ្ចេញនូវវាចាអស់វារៈ ៣ដងថា "ម្នាលអ្នកដ៏ចំរើន, សត្វលោកនឹងវិនាសសាបសូន្យមិនខានឡើយ" ។ មហាព្រហ្មដែលនៅក្នុងចក្កវាឡមួយម៉ឺនបានឮហើយ ក៏មកសួរគ្រប់ប្រការ ។ សហម្បតីព្រហ្មក៏ប្រាប់ហេតុហើយទើបនាំហោះចុះមក ចូលទៅកាន់សំណាក់ព្រះសាស្តា ដល់ហើយក៏លុតនូវជាណុមណ្ឌលដំកល់លើផ្ទៃប្រឹថពី ផ្គងនូវអញ្ជលីជាទីសមោធាននៃទសនខាដ៏រុងរឿង បីដូចផ្កានៅលើសិរសា ហើយងើបមុខមើលភក្ត្រានៃព្រះអង្គ ដ៏រុងរឿងដោយឆព្វណ្ណរង្សី ក្រាបអារាធនាដោយគាថាថា "សន្តីធ សត្ថាប្បវជក្ខជាតិកា" ដូច្នេះជាដើម ។

(៣) អថ ភគវា លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះទ័យប្រកបដោយសេចក្តីករុណា បានសវនាការនូវពាក្យនៃព្រហ្មហើយ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា ព្រហ្មេ ម្នាលសហម្បតីព្រហ្ម, តថាគតបរិវិតក្កថា ធម៌ជាគម្ភីរភាព តថាគត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រាស់ដឹងហើយ ពពួកសត្វទាំងឡាយត្រេកអរដោយតណ្ហា មិនអាចធ្វើឱ្យជាក់ច្បាស់នូវទីបំផុតនៃទុក្ខ គឺព្រះនិព្វានបានឡើយ, បដិច្ចសមុប្បាទធម៌ប្រកបដោយអង្គ១២ ក៏សត្វឃើញដោយកម្រ, កិរិយារម្ងាប់បង់នូវសង្ខារទាំងពួង និងការលះបង់នូវកិលេស និងការផ្ដាច់បង់នូវតណ្ហា ហើយដល់នូវព្រះនិព្វានក៏សត្វដឹងបានដោយកម្រ បើតថាគតសំដែងនូវធម៌ សត្វទាំងឡាយក៏មិនជឿនូវពាក្យតថាគត, សេចក្ដីនឿយព្រួយលំបាកទទេគង់មានដល់តថាគត, ហេតុដូច្នោះបានជាតថាគតមានសេចក្ដីខ្វល់ខ្វាយតិចក្នុង ការសំដែងធម៌ដល់សត្វ ។

(៤) ឯវំ យាវ តតិយំ បិ ភគវា ព្រះដ៏មានព្រះភាគកាលសហម្បតីព្រហ្មអារាធនាអស់វារៈ៣ដងដូច្នោះហើយ ព្រះអង្គក៏រមិលមើលនូវសត្វដោយទិព្វចក្ខុ ទ្រង់ឃើញនូវពួកសត្វខ្លះមានធូលីគឺរាគៈ ទោសៈ មោហៈ ក្នុងភ្នែកតិច, សត្វពួកខ្លះមានធូលីក្នុងភ្នែកច្រើន, ព្រះអង្គជ្រាបច្បាស់ហើយទើបមានព្រះពុទ្ធដីកាថា

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

វិហឹសសញ្ញី បគុណំ នភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ

ម្នាលព្រហ្ម, តថាគតមានការសំគាល់នូវសេចក្ដីនឿយ (កាយនិងវាចា) បានជាមិនទាន់សំដែងធម៌ដ៏ឧត្ដមដែលតថាគតបេះស្ទាត់ហើយ ដល់ពួកមនុស្សនិងទេវតា (ប៉ុន្តែឥឡូវនេះ) ទ្វារនិព្វានរបើកហើយ ពួកសត្វណាដែលមានសោតបសាទ ពួកសត្វនោះចូរបញ្ចេញសទ្ធា (ស្ដាប់ធម៌) ចុះ ។

សហម្បតីព្រហ្មបានស្ដាប់ព្រះពុទ្ធដីកា ធ្វើនូវឱកាសទទួលនឹងសំដែងធម៌ដល់សត្វដូច្នោះហើយ ក៏ធ្វើនូវអញ្ជលីថ្វាយបង្គំលា នាំព្រហ្មបរិវារបោះទៅឋានព្រហ្មលោកវិញ ។

(ចប់ព្រហ្មជ្ញេសនបរិច្ឆេទ ទី១៣)

---

## ធម្មបក្កបរិច្ឆេទ ទី១៤

(១) ឯវំ ភគវា តស្ស ព្រហ្មុនោ បដិញ្ញំ ទត្វា ព្រះដ៏មានព្រះភាគទ្រង់ប្រទាននូវ បដិញ្ញាដល់មហាព្រហ្មយ៉ាងនេះហើយ ក៏ទ្រង់ព្រះចិន្ដាថា "តថាគតគប្បីសំដែងនូវធម៌ដល់អ្នកណាជាមុន, បុគ្គលណានឹងបានត្រាស់ដឹងនូវធម៌ជាមុន" ព្រះអង្គបរិវិតក្កថា អាឡារតាបសកាលាមគោត្តនេះ ជាបណ្ឌិត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

មានធូលីគឺកិលេសក្នុងភ្នែកតិច, គួរតថាគតសំដែងធម៌ឱ្យជាមុន, តាបសនោះគង់ត្រាស់ដឹងនូវធម៌ពុំខាន ។ លំដាប់នោះទេវតាចូលទៅក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន, អាឡារតាបសកាលាមគោត្តធ្វើមរណកាលទៅបំនួន៧ថ្ងៃហើយ” ។ ព្រះបញ្ញាក៏កើតដល់ព្រះអង្គ ទ្រង់ជ្រាបថា “អាឡារតាបសធ្វើមរណកាលក្ស័យជីវិតកន្លងទៅ៧ថ្ងៃពិត” ។

(២) អថស្ស ឯតទហោសិ លំដាប់ពីនោះមកទៀត ព្រះដ៏មានព្រះភាគទ្រង់មានបរិវិតក្កថា តថាគតគប្បីសំដែងធម៌ដល់អ្នកណា ។ ទើបទ្រង់ជ្រាបថា “ឧទ្ទកតាបសរាមបុត្រនេះជាបណ្ឌិតមានធូលីក្នុងភ្នែកតិច គួរនឹងត្រាស់ដឹងនូវធម៌ដោយឆាប់” ។ លំដាប់នោះទេវតាចូលទៅក្រាបទូលដល់ព្រះអង្គថា “ឧទ្ទកតាបសរាមបុត្តនោះ ធ្វើមរណកាលក្នុងវេលាព្រលប់ទៅហើយ” ។ ព្រះអង្គទ្រង់ជ្រាបដោយបញ្ញាថា “មែនដូចពាក្យទេវតា” ទើបព្រះអង្គទ្រង់បរិវិតក្កថា “តាបសទាំងពីរនេះជាមនុស្សវិនាសធំ, បើតាបសនៅបានស្តាប់ធម៌ដែលតថាគតសំ-ដែង គង់នឹងត្រាស់ដឹងនូវធម៌ដោយពិតមិនខាន ។

(៣) អថស្ស ឯតទហោសិ លំដាប់នោះ ព្រះអង្គ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់មានបរិវិតក្កទៅទៀតថា "តថាគតគប្បីសំដែងធម៌ដល់អ្នកណាជាមុន, អ្នកឯណានឹងបានត្រាស់ដឹងនូវធម៌" ទើបទ្រង់បរិវិតក្កនឹងដល់បញ្ចវគ្គិយភិក្ខុថា "បញ្ចវគ្គិយភិក្ខុនេះ មានឧបការៈដល់តថាគត បានធ្វើការបំរើតថាគតអស់កាលដ៏យូរ, បើដូច្នោះគួរ តថាគតសំដែងធម៌ដល់បញ្ចវគ្គិយភិក្ខុនោះជាមុនចុះ", ព្រះអង្គទ្រង់បរិវិតក្កថា "បញ្ចវគ្គិយភិក្ខុទៅនៅក្នុងទីឯណា" ទើបទ្រង់ជ្រាបថា "បញ្ចវគ្គិយភិក្ខុទៅនៅក្នុងព្រៃឥសិបតនមិគទាយវ័នទៀបនគរពារាណសី" ព្រះអង្គគង់ក្នុងឧរុវេលាប្រទេសតាមសប្បាយ លុះដល់គ្រាក្រោយទ្រង់យាងទៅកាន់ចារិក ។

ឧបកាជីវកបានឃើញព្រះសម្មាសម្ពុទ្ធ ក៏ពោលពាក្យសរសើរផ្សេងៗ ។ ព្រះអង្គទ្រង់ សំដែងគាថា ថា "សព្វាភិភូ សព្វវិទូ" ដូច្នេះជាដើម លុះចប់ហើយឧបកាជីវកសួរថាសមណៈទៅកាន់ទីឯណា? ព្រះអង្គតបថា តថាគតទៅដែនកាសីដើម្បីសំដែងនូវធម្មចក្រ ។ ឧបកាជីវកបានស្តាប់ហើយក៏តបទៅថា "ម្នាលអាវុសោសមណៈ ពាក្យអ្នកពោលប្រពៃហើយ" ហើយក៏ងក់ក្បាលគំនាប់ ដើរចៀសទៅតាមប្រាថ្នារបស់ខ្លួន ។

(៤) អថ ខោ ភគវា អនុបុព្វេន ចារិកញ្ចរមានោ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

លំដាប់នោះ ព្រះដ៏មានព្រះភាគយាងទៅកាន់ចារិកតាមលំដាប់ ដល់ព្រៃឥសិបតនមិគទាយវ័ន ជាទីនៅនៃបញ្ចវគ្គិយ ។ ឯបញ្ចវគ្គិយភិក្ខុបានឃើញព្រះអង្គអំពីចម្ងាយ ក៏ធ្វើនូវបដិញ្ញានឹងគ្នាថា "ម្នាលគ្នាយើង ព្រះសមណគោតមមកដល់ហើយ យើងទាំងឡាយកុំថ្វាយបង្គំ កុំក្រោកទទួល កុំទទួលបាត្រចីវរ, តែជាពួកយើងត្រូវក្រាលអាសនៈទុក បើព្រះសមណៈអង្គុយក៏អង្គុយចុះ" ។ លុះព្រះអង្គយាងទៅដល់ បញ្ចវគ្គិយភិក្ខុអត់មិនបាន ភ្លេចពាក្យបដិញ្ញាអស់ ក៏ត្រឡប់ជាក្រោកអរ ទៅទទួលបាត្រចីវរធ្វើនូវកិច្ចទាំងពួងរាល់ៗគ្នា ហើយហៅព្រះអង្គដោយពាក្យដើមខ្លះ ដោយពាក្យថាអាវុសោខ្លះ ។

(៤) អរហំ ភិក្ខវេ តថាគតោ ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតឆ្ងាយបាកកិលេសហើយ ត្រាស់ដឹងនូវធម៌ដោយប្រពៃដោយខ្លួនឯងហើយ, អ្នកទាំងឡាយ ចូរដំកល់នូវសោតបសាទចាំស្តាប់នូវធម៌ឈ្មោះអមតៈ តថាគតនឹងប្រដៅ នឹងសំដែងនូវធម៌ដែលតថាគតត្រាស់ដឹង ។ កាលបើព្រះអង្គពោលដូច្នោះ, បញ្ចវគ្គិយភិក្ខុក៏ក្រាបទូលសួរថា "ម្នាលអាវុសោគោតម ខ្លួនអ្នកត្រាស់ដឹងនូវឧត្តរិមនុស្សធម៌

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយឬ? ព្រះអង្គតបទៅថា “ធម៌ដែលមានឈ្មោះថាអមតៈ តថាគតត្រាស់ដឹងហើយ, តថាគតសំដែងធម៌ដល់អ្នកទាំងឡាយ” ។ ព្រះអង្គក៏មិនអាចដើម្បីញ៉ាំងបញ្ចវគ្គិយភិក្ខុឱ្យដឹងច្បាស់បាននអស់វារៈជាគំរប់២ផង ។ តមកទើបបញ្ចវគ្គិយភិក្ខុទទួលស្តាប់ព្រះពុទ្ធដីកាក្នុងវារៈជាគំរប់៣ផង ។

(៦) អថ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុ ដោយព្រះពុទ្ធដីកាថា ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ ផ្លូវដ៏លាមកទាំងឡាយពីរនេះគឺបព្វជិតមិនគប្បីសេព, មគ្គប្រកបដោយអង្គ ៨ គឺបព្វជិតគប្បីសេព ព្រះអង្គក៏ទ្រង់ត្រាស់សំដែង ធម្មចក្កប្បវត្តនសូត្រប្រកបដោយអង្គ ៣ប្រការគឺ កាមសុខល្លិកានុយោគ១ អត្តកិលមថានុយោគ១ មជ្ឈិមាបដិបទា១ ប្រកបដោយសច្ចៈ៤ គឺ ទុក្ខសច្ចៈ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ១ ប្រកបដោយបរិវដ្ដ៣គឺ សច្ចញ្ញាណ១ កិច្ចញ្ញាណ១ កតញ្ញាណ១ ប្រកបដោយអាការៈ១២ គឺសច្ចៈនីមួយៗ មានអាការៈបីៗគ្រប់ទាំង៤ ។ ទេវតាទាំងឡាយបន្លឺនូវសំឡេងតៗ គ្នាទៅ ។ លោក-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ធាតុទាំង១ម៉ឺនក៏កំរើកញាប់ញ័រ ។ លំដាប់នោះ កោណ្ឌញ្ញ-ភិក្ខុបានត្រាស់ដឹងនូវលោកុត្តរធម៌ គឺសោតាបត្តិផល ។ ទេវតាទាំង១៨កោដិក៏បានធម្មចក្ខុគឺសោតាបត្តិផល ហើយត្រឡប់ទៅកាន់ឋានទេវលោកវិញ ។

ព្រះអង្គសំដែងធម្មចក្ក ក្នុងថ្ងៃបុណ្ណមីខែអាសាធឆ្នាំរកា ។

(បប់ធមចក្កបរិច្ឆេទ ទី១៤)

---

## យសបព្វជ្ជាបរិច្ឆេទ ទី១៥

(១) អថ ខោ ភគវា វិស្សំ ឱបគន្ត្វា លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់ចាំវស្សាក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់សំដែងធម្មីកថាដល់ភិក្ខុដ៏សេស ទ្រង់ប្រទានធម្មចក្ខុដល់វប្បៈក្នុងថ្ងៃ១រោច ប្រទានដល់ភទ្ទិយក្នុងថ្ងៃ២រោច ដល់មហានាមក្នុងថ្ងៃ៣រោច, ដល់អស្សជិក្នុងថ្ងៃ៤រោច ។ លំដាប់នោះ ភិក្ខុទាំង៥អង្គ ក៏សូមបព្វជ្ជាឧបសម្បទា ។ ព្រះអង្គទ្រង់ប្រទានឧបសម្បទាជាឯហិភិក្ខុ ដល់ភិក្ខុទាំង៥អង្គដោយព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយចូរមក អ្នកទាំងឡាយចូរប្រព្រឹត្តនូវព្រហ្មចរិយៈដើម្បីធ្វើនូវទីបំផុតនៃសេចក្តី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទុក្ខ”។ ឧបសម្បទាក៏សម្រេចដល់បញ្ចវគ្គិយភិក្ខុ។ ព្រះអង្គគង់នៅក្នុងវិហារសមាបត្តិរង់ចាំដើម្បីជម្រះនូវមន្ទិលនៃបញ្ចវគ្គិយ។

(២) កាឡបក្ខស្ស បញ្ចមិយំ តេសំ វិសេសតោ លុះដល់ថ្ងៃ៥រោច ព្រះអង្គឃើញឧបនិស្ស័យព្រះអរហត្តនៃភិក្ខុទាំង៥អង្គដោយវិសេស ព្រះអង្គប្រជុំភិក្ខុទាំង៥អង្គ ហើយសំដែងនូវអនត្តលក្ខណសូត្រដោយព្រះពុទ្ធដីកាថា “រូបំ ភិក្ខវេ អនត្តា” ដូច្នេះជាដើម បង្អួលនូវបញ្ចក្ខន្ធថាជាសភាវៈមិនបាន ប្រព្រឹត្តទៅក្នុងអំណាច ។ បញ្ចវគ្គិយភិក្ខុ ក៏មានចិត្តត្រេកអរនឹងភាសិតនៃព្រះអង្គ ។ ចិត្តបញ្ចវគ្គិយភិក្ខុសោតក៏រួចចាកអាសវៈ ។ ព្រះអរហន្ត៥អង្គ (៦អង្គនិងព្រះពុទ្ធជាម្ចាស់) ក៏កើតឡើងក្នុងលោក ។

(៣) តេន ខោ បន សមយេន ពារាណសិយំ យសោ នាម កុលបុត្តោ ក្នុងសម័យនោះ មានបុត្រនៃសេដ្ឋីម្នាក់ឈ្មោះយសកុលបុត្ត[១] នៅក្នុងប្រាសាទទាំង៣ ជាទីសប្បាយតាមឧតុកាល មានស្រីស្នំបំរើជាធម្មតា, ក្នុងកាលនោះ យសកុលបុត្តភ្ញាក់ក្រោកឡើងមុនគេបានឃើញជនទាំង

១ បុត្តនាងសុជាតា ដែលថ្វាយមធុបាយាស

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ឮងដេកលក់សំដែងវិប្បការៈផ្សេងៗ ក៏មានចិត្តនឿយណាយក្នុងឃរាវាស ទើបពាក់ស្បែកជើងមាស ដើរចុះចាកប្រាសាទចូលទៅ ក្នុងព្រៃឥសិបតនមិគទាយវ័នក្នុងរាត្រី ។ គ្រានោះព្រះដ៏មានបុណ្យទ្រង់យាងចង្ក្រម វេលាបច្ចូសសម័យ ទ្រង់ទតឃើញយសកុលបុត្តហើយ ត្រាស់ហៅថា "នែអ្នកដ៏ចំរើន, ទីនេះឥតមានទោសបៀតបៀនទេ" ។ យសកុលបុត្តស្ដាប់ហើយ ក៏ដោះស្បែកជើងដើរចូលទៅកាន់សំណាក់ព្រះសាស្ដាអង្គុយក្នុងទីដ៏សមគួរ ។ ភគវា អនុបុព្វីកថំ កថេសិ ព្រះដ៏មានព្រះភាគទ្រង់សំដែងអនុបុព្វីកថាចប់ហើយ យសកុលបុត្តបានសម្រេចសោតាបត្តិផល ។

(៤) អថ ខោ យសមាតា លំដាប់នោះ មាតាយសកុលបុត្តឡើងទៅលើប្រាសាទមិនឃើញកូន ក៏ទៅជំរាបស្វាមី ។ សេដ្ឋីបានស្ដាប់ហើយ ក៏ប្រើមនុស្សឱ្យទៅរកក្នុងទិសទាំង៤ ។ គហបតី ក៏ដើរទៅរកក្នុងព្រៃឥសិបតនមិគទាយវ័ន ដោយខ្លួនឯងបានឃើញស្បែកជើងមាសដែលកូនដោះបោល ក៏ដើរតាមដានទៅ ។ ព្រះពុទ្ធជាម្ចាស់ឃើញសេដ្ឋីដើរចូលមក ទ្រង់សំ-ដែងឫទ្ធិមិនឱ្យឃើញយសកុលបុត្ត ។ សេដ្ឋីដើរចូលទៅសួរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គមានព្រះពុទ្ធដីកាថា "អ្នកចូរអង្គុយក្នុងទីនេះចុះ គង់តែនឹងបានឃើញកូនអ្នក" ។ សេដ្ឋីបានស្ដាប់ហើយក៏ធ្វើតាម ។ ទើបទ្រង់ត្រាស់សំដែងអនុបុព្វីកថា ចប់ហើយសេដ្ឋីបានសម្រេចសោតាបត្តិផល សំដែងខ្លួនជាឧបាសកដល់នូវតេវាចិកសរណ-គមន៍ ។ សេដ្ឋីនោះជាឧបាសកដំបូងក្នុងព្រះពុទ្ធសាសនា ។ ព្រះពុទ្ធជាម្ចាស់ក៏រំសាយរិទ្ធិឱ្យឃើញ យសកុលបុត្តដែលអង្គុយនៅជិតព្រះអង្គ ។ សេដ្ឋីឃើញហើយក៏និយាយនឹងកូនថា "កូនអើយ មាតាអ្នកមានសេចក្ដីសោកខ្លាំងណាស់, ចូរអ្នកឱ្យនូវជីវិតដល់មាតាអ្នកផង" ។

(៤) អថ ខោ យសោ កុលបុត្តោ លំដាប់នោះ យសកុលបុត្តក៏រមិលមើលនូវព្រះដ៏មានបុណ្យ ។ ព្រះដ៏មានព្រះភាគមានព្រះពុទ្ធដីកានឹងគហបតីថា "ម្នាលគហបតី, យសកុលបុត្តក្ដី អ្នកក្ដី បានដឹងច្បាស់នូវធម៌ហើយ យសកុលបុត្តមិនគួរត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញឡើយ" ។ គហបតីក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន យសកុលបុត្តមិនគួរ ត្រឡប់ទេ, លាភសោតក៏យសបានដោយងាយ, តែថាថ្ងៃស្អែកនេះសូមព្រះអង្គយាងទៅទទួលភត្តនៃខ្ញុំព្រះករុណា មួយអន្លើដោយ

Websites: WatKhemaraRatanaram.org or WatKhmers.org

យសកុលបុត្តនេះ” ។ ព្រះដ៏មានបុណ្យទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គហបតីដឹងនូវហេតុនោះ ក៏ថ្វាយបង្គំលាធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ព្រះយសក៏សូមបព្វជ្ជាឧបសម្បទា ។ ព្រះសព្វញ្ញូទ្រង់ប្រទានបព្វជ្ជាឧបសម្បទាជាឯហិភិក្ខុ ។ ក្នុងសម័យនោះ មានព្រះអរហន្តបំនួនពអង្គ គឺព្រះពុទ្ធ១អង្គ បញ្ចវគ្គិយ៥អង្គ យសត្ថេរ១អង្គ ។

(៦) អថ ខោ ភគវា លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រៃចីវរនឹងបាត្រក្នុងបុព្វណ្ហសម័យ យាងចូលទៅកាន់ផ្ទះគហបតីមួយអន្លើដោយព្រះយសត្ថេរ ដល់ហើយទ្រង់ឡើងគង់លើអាសនាដែលគហបតីតាក់តែងទុក ។ បំណែកមាតានិងភរិយានៃព្រះយសក៏ចូលទៅថ្វាយបង្គំព្រះអង្គ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមហាករុណាទ្រង់សំដែងនូវអនុបុព្វីកថាដល់ស្រីទាំងឡាយនោះ លុះចប់កាលណា ស្រីទាំងពីរគឺមាតានិងភរិយានៃព្រះយស ក៏បានដល់សោតាបត្តិផល ហើយថ្វាយខ្លួនជាឧបាសិកាក្នុងកាលនោះ ។ ជនទាំងឡាយមានជីតានៃព្រះយសជាដើម ក៏អង្គាសព្រះយសនឹងព្រះសាស្តាដោយខាទនីយៈភោជនីយាហារដ៏ឧត្តមដោយដៃខ្លួន ហើយបវារណាចំពោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះសាស្ដា ទ្រង់ញុំាងជនទាំងនោះឱ្យរីករាយ ដោយធម្មីកថា ហើយយាងត្រឡប់វិញ ។

(៧) ពារាណសិយំ អនុសេដ្ឋិកុលស្ស បុត្តា គ្រហស្ថទាំងឡាយ ៤ នាក់ជាសំឡាញ់នៃយស សុទ្ធសឹងជាបុត្រានៃត្រកូលអនុសេដ្ឋីក្នុងនគរពារាណសី គឺវិមល១ សុពាហុ១ បុណ្ណជិ១ គវម្បតិ១ បានឮថាព្រះយសកុលបុត្តចេញសាងបព្វជ្ជា ក៏គិតនឹងទៅបួសតាម ទើបនាំគ្នាទៅកាន់សំណាក់ព្រះយស ។ ព្រះយសក៏នាំសំឡាញ់ទាំង៤នាក់ចូលទៅកាន់សំណាក់ព្រះសាស្ដា ក្រាបបង្គំទូលតាមដំណើរ ។ ព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅ សំដែងអនុបុព្វីកថាដល់កុលបុត្តទាំង៤នាក់ ។ កុលបុត្តទាំងនោះ ក៏សូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះអង្គទ្រង់ប្រទានបព្វជ្ជានឹងឧបសម្បទាដល់កុលបុត្តទាំង៤នាក់ ។

លំដាប់ពីនោះមកទៀត មានគ្រហស្ថ ៥០ នាក់ជាសំឡាញ់ព្រះយសដែរ បានឮដំណឹងដូច្នោះ ក៏បបួលគ្នាទៅកាន់សំណាក់ព្រះយស ។ ព្រះយសនាំទៅកាន់សំណាក់ព្រះសាស្ដា។ ព្រះដ៏មានជោគ ទ្រង់ទូន្មានប្រៀនប្រដៅសំដែងអនុបុព្វីកថា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កុលបុត្តទាំង៥០នាក់ក៏សូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះឈ្មោះមារទ្រង់ប្រទានបព្វជ្ជានឹងឧបសម្បទា ។ ភិក្ខុទាំងអម្បាលនោះ មានចិត្តរួចចាកអាសវៈទាំងអស់អង្គ ។ ក្នុងកាលនោះ មានព្រះអរហន្តចំនួន៦១ព្រះអង្គ ។

(៨) មុត្តោហំ សព្វបាសេហិ យេ ច ទិព្វា យេ ច មានុសា លំដាប់នោះ ព្រះសាស្តាមានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ, តថាគតរួចហើយចាកអន្ទាក់ទាំងពួង, ទេវតានិងមនុស្សទាំងឡាយឯណាមានក្នុងលោកនេះ, អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ចូរដោះទេវតានឹងមនុស្សទាំងនោះ ឱ្យរួចចាកអន្ទាក់ផងចុះ អ្នកចូរសំដែងនូវធម៌មានពីរោះខាងដើមនឹងកណ្តាលនឹងខាងចុង ឱ្យទេវតានឹងមនុស្សទាំងនោះស្តាប់ផងចុះ ដ្បិតសត្វទាំងឡាយដែលមានធូលីគឺកិលេសក្នុងភ្នែកតិច បើមិនបានស្តាប់ទេ មុខជាសាបសូន្យចាកព្រះសទ្ធម្មដ៏ប្រសើរ ចំណែកតថាគតនឹងទៅកាន់ប្រទេសឧរុវេលា អ្នកទាំងឡាយចូរទៅកាន់ចារិក ដើម្បីសំដែងនូវព្រហ្មចរិយធម៌ដល់សត្វទាំងពួង តាមន័យដែលតថាគតសំដែងហើយ តែអ្នកទាំងឡាយកុំទៅផ្លូវជាមួយគ្នាពីរនាក់ឡើយ" ។ ភិក្ខុទាំងឡាយក៏ទទួលតាមព្រះពុទ្ធ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដីកា ក្រាបបង្គំលាហើយចៀសចេញទៅ ។ លំដាប់នោះ មារាធិរាជមានចិត្តបាប ក៏ចូលទៅកាន់សំណាក់ព្រះសាស្តាក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គបានរួចចាកមារពន្ធន៍ទាំងពួងហើយ តែព្រះអង្គគង់មិន រួចពីដៃខ្ញុំ” ។ ព្រះពុទ្ធជាម្ចាស់ត្រាស់តបថា “ម្នាលមារអើយ, សេចក្តីប្រាថ្នាក្នុងរូប សំឡេង ក្លិន រស សម្ផស្ស តែតថាគតមិនមានឡើយ, តថាគតអាចកំចាត់បង់នូវមច្ចុមារបាន” ។ មារស្តាប់ហើយក៏កើតទុក្ខតូចចិត្តត្រឡប់វិលទៅវិញ ។

(ចប់យសបព្វជ្ជាបរិច្ឆេទ ទី១៥)

---

## ឧរុវេលគមនបរិច្ឆេទ ទី១៦

(១) អថ ខោ ភគវា ពារាណសិយំ យថាភិរន្តំ វិហរិត្វា គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនគរពារាណសីតាមសប្បាយ ហើយទ្រង់ស្តេចសំដៅទៅឧរុវេលាប្រទេស ។ ក្នុងសម័យនោះ មានកុមារ ៣០នាក់[១] ជាពួកដ៏ចំរើនជាសំឡាញ់នឹងគ្នា ព្រមទាំងភរិយាដើរត្រាច់ទៅក្នុងព្រៃ ។ ឯកុមារម្នាក់គ្មានភរិយា ។ កុមារទាំងឡាយជាសំឡាញ់នាំស្រី

---

១ ក្នុងអដ្ឋកថាវិន័យប្រាប់ថា ភទ្ទវគ្គិយកុមារទាំង៣០នាក់នេះ ជាបុគ្គលស្តេចអ្នកដែនកោសល ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវ៉ិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រួន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ពេស្យាម្នាក់មកឱ្យ ។ ស្រីពេស្យានោះ, កាលបើកុមារទាំង-ពួងធ្វេសប្រហែសដើរលេងព្រៃ, ក៏លួចយកនូវបង្វិចគ្រឿងប្រ-ដាប់រត់ចូលទៅក្នុងព្រៃ ។ បំណែកកុមារជាសំឡាញ់ ក៏ខ្វល់ខ្វាយជួយដើររក ស្រាប់តែបានជួបនឹងព្រះពុទ្ធជាម្ចាស់ដែលគង់នៅទៀបគល់ឈើ ហើយសាកសួររកស្រីនោះ។ ព្រះអង្គទ្រង់សួរថា "ស្រីនោះតើមានប្រយោជន៍ដូចម្តេចដល់អ្នក?" កុមារទាំងពួងក្រាបបង្គំទូលសព្វគ្រប់ប្រការ ។ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថា ។ កុមារទាំងឡាយបានស្តាប់ហើយ សូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទាដល់កុមារទាំង៣០នាក់ក្នុងព្រៃកប្បាសិកវ័ន ។

(២) អថ ខោ ភគវា លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិក ស្តេចទៅដល់ប្រទេសឧរុវេលា គង់នៅក្នុងទីនោះ ។ សម័យនោះ មានជដិល៣នាក់បងប្អូននឹងគ្នាគឺឧរុវេលកស្សប១, នទីកស្សប១, គយាកស្សប១ ។ ឧរុវេ-លកស្សបមានបរិវារ៥រយ នទីកស្សប មានបរិវារ៣រយ គយា-កស្សបមានបរិវារ២រយ ។ ព្រះដ៏មានព្រះភាគយាងទៅកាន់សំណាក់ឧរុវេលកស្សបសូមនៅក្នុងរោងភ្លើង ។ កស្សបទូល

Websites: WatKhemaraRatanaram.org or WatKhmers.org

ហេតុទាំងពួងថាមាននាគនៅ ។ ព្រះអង្គក៏បេះតែយាងទៅនៅ ។ ក្នុងរាត្រីនោះ ស្តេចនាគបណ្តាលជាភ្លើងឱ្យត្រូវកាយព្រះអង្គ ។ ព្រះអង្គក៏សំដែងជាផ្សែងជាភ្លើងឱ្យត្រូវកាយនាគ ។ នាគបាញ់។ ព្រះអង្គចាប់នាគដាក់ក្នុងបាត្រយកទៅបង្ហាញជដិល។ ឧរុវេលកស្សបឃើញហើយក៏កោតដែរ តែនៅប្រកាន់ថាមិនវិសេស ។

(៣) អថ ខោ ឧរុវេលកស្សបោ គ្រានោះ ឧរុវេលកស្សបនិមន្តដោយភត្តាហារដោយឃើញបាដិហារយ៍។ ព្រះអង្គយាងទៅគង់នៅនាដងព្រៃ ។ ស្តេចទាំងបួន ចុះមកគាល់ព្រះអង្គក្នុងបឋមយាម ។ សម្តេចសហស្សន័យ ចុះមកគាល់ក្នុងមជ្ឈិមយាម ។ មហាព្រហ្ម ចុះមកគាល់ក្នុងបច្ឆិមយាម បណ្តាលឱ្យព្រៃទាំងអស់រុងរឿងដោយរស្មីផ្សេងៗគ្នា ។ លុះដល់ព្រឹកឡើងឧរុវេលកស្សបទៅនិមន្តព្រះអង្គក៏ទូលសួរ ។ ព្រះអង្គតបទៅថា “កស្សបអើយ, ស្តេចទាំងបួនមកក្នុងបឋមយាម, ព្រះឥន្ទមកក្នុងមជ្ឈិមយាម, មហាព្រហ្មជាគ្រូអ្នកមកក្នុងបច្ឆិមយាម ដើម្បីស្តាប់ធម៌តថាគត” ។ កស្សបស្តាប់ហើយក៏និមន្តព្រះអង្គទៅសោយភត្តាហារ ។ បុនទិវសេ មហាយញ្ញោ លុះដល់ថ្ងៃក្រោយមកទៀត មហាយញ្ញក៏កើតឡើងដល់ឧរុវេល-

Websites: WatKhemaraRatanaram.org or WatKhmers.org

កស្សប គឺជនដែលនៅក្នុងដែនមគធៈ នាំខាទនីយៈភោជនីយៈមក ។ ឧរុវេលកស្សបគិតមិនចង់ឱ្យព្រះអង្គយាងមកក្នុងថ្ងៃនោះ ។ ព្រះអង្គជ្រាបបរិវិតក្កនៃកស្សបទាំងអស់ ។ លុះព្រឹកឡើង ព្រះអង្គយាងទៅខ្ពុរព្រះឱស្ឋឯព្រះអនោតត្ត ហើយយាងទៅទ្រង់បិណ្ឌបាតឯឧត្តរកុរុទ្វីប បានហើយទ្រង់យាងមកសោយទៀបស្រះអនោតត្ត ទើបយាងមកគង់ក្នុងដងព្រៃនោះវិញ ។

(៤) សាយណ្ហសមយេ លុះដល់វេលាថ្ងៃរសៀល ឧរុវេលកស្សបទៅកាន់សំណាក់ព្រះអង្គហើយទូលថា ហេតុអ្វីបានជាសមណៈមិនទៅក្នុងវេលាព្រឹកមិញនេះ? ព្រះអង្គក៏សំដែងហេតុទាំងពួងប្រាប់កស្សប ។ កស្សបក៏គិតថាសមណៈនេះគ្រាន់តែដឹងបរិវិតក្កប៉ុណ្ណោះ មិនមែនជាអរហន្តវិសេសដូចអញទេ ។ ក្នុងកាលនោះ សំពត់បង្សុកូលកើតឡើងដល់ព្រះតថាគត ។ ព្រះអង្គយាងទៅទោះយកសំពត់ ដែលជនរុំអសុភនាងបុណ្ណាទាសី យកទៅបោលក្នុងអាមកសុសាន ។ ព្រះអង្គបរិវិតក្កគិតនឹងលាង ។ ខណៈនោះ ព្រះឥន្ទ្របុះមកជីកស្រះបោក្ខរណីថ្វាយ ។ ព្រះអង្គគង់ហើយទ្រង់បរិវិតក្កថា តថាគតនឹងឈ្លីក្នុងទីណា ។ ព្រះឥន្ទ្រនាំផែនថ្មធំមក ។ ព្រះអង្គឈ្លីហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់បរិវិតក្កថា តថាគតនឹងពាក់ក្នុងទីណា ។ ទេវតាបង្អោនមែកថ្វាន់មកថ្វាយព្រះអង្គពាក់ ។ ទើបទ្រង់បរិវិតក្កថា តថាគតនឹងហាលក្នុងទីឯណា ។ ព្រះឥន្ទ្រក៏លើកផែនថ្មធំបង្អោន ទៅថ្វាយឱ្យហាល ។ ខណៈដែលព្រះអង្គធ្វើមហាបង្សុ-កូលកិច្ច ផែនដីក៏កំរើកអស់វារៈ ៣ ដង ។ លុះព្រឹកឡើងកស្សបទៅកាន់ សំណាក់ព្រះអង្គ បានឃើញសម្ភារៈមានថ្មជាដើម ក៏ទូលសួរ ។ ព្រះអង្គប្រាប់ហេតុសព្វគ្រប់ប្រការ ។ កស្សបក៏បរិវិតក្កថា មិនមែនអរហន្តវិសេសដូចអញទេ ។

(៥) តទនន្តរំ លំដាប់អំពីនោះមកទៀត ព្រះសាស្តាទ្រង់ធ្វើនូវបាដិហារិយ៍៤ប្រការ គឺព្រះអង្គបញ្ជូនកស្សបមក ទ្រង់ហោះទៅនាំផ្លែស្វាយពីព្រៃហិមវន្ត នាំផ្លែកន្ទួតព្រៃ នាំផ្លែសម៉ ទ្រង់យាងទៅកាន់ឋានតាវត្តិង្ស នាំយកនូវផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វបានមក ទ្រង់យាងមកគង់ក្នុងរោងភ្លើងមុនកស្សបអស់វារៈ៤ដង កស្សបក៏បរិវិតក្កដូចមុន ។ ឯកទិវសំ ជដិលា ក្នុងថ្ងៃមួយ ជដិលទាំងឡាយប្រាថ្នានឹងបង្កាត់ភ្លើង ពុះឧសមិនបែកទើបគិតថាហេតុដែលមានយ៉ាងនេះ ព្រោះឫទ្ធិមហាសមណៈពិត ។ ព្រះសព្វញ្ញូទ្រង់តបទៅថាអ្នកចូរពុះឧសតាមប្រាថ្នាចុះ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ខណៈនោះ ជដិលក៏ពុះឱសបែកទាំងអស់ ។ ថ្ងៃមួយជដិលប្រាថ្នានឹងបង្កាត់ភ្លើងៗ មិនឆេះ ក៏គិតដូចមុន ។ ព្រះអង្គទ្រង់ជ្រាប ក៏ត្រាស់អនុញ្ញាតឱ្យភ្លើងឆេះឡើង ។ ជដិលបូជាភ្លើងស្រេចហើយលត់ភ្លើងមិនរលត់ ក៏គិតដូចមុន ។ ព្រះអង្គទ្រង់អនុញ្ញាតឱ្យភ្លើងរលត់អស់ទៅ ។ កស្សប ក៏បរិវិតក្កដូចមុន ។

(៦) តស្មឹ សីតសមយេ ក្នុងសម័យដែលរងាដោយទឹកសន្សើមធ្លាក់ចុះច្រើននោះ ជដិលទាំងឡាយចុះងូតទឹកក្នុងនេរញ្ជរា ឡើងមកបានកិរិយារងាខ្លាំង ក៏សម្តេចព្រះអរហំទ្រង់និម្មិតបង្ក្រាន៥០០ ឱ្យពួកជដិលទាំងនោះអាំង ។ ម្លឹងដែរក៏ពួកជដិលនៅតែបរិវិតក្កដូចមុនទៀត ។ ថ្ងៃមួយមហាមេឃតាំងឡើងក្នុងកាលមិនគួរ បណ្តាលទឹកឱ្យធ្លាក់ចុះមកជន់លិចគ្រប់អន្លើ ។ ចំណែកព្រះមហាករុណាទ្រង់គង់ក្នុងទីឯណាទឹកមិនបានលិចនូវទីនោះ បែរជាមានសុទ្ធតែធូលីហុយឡើងវិញ ។ ឱរុវេលកស្សបគិតថា “មហាសមណៈប្រហែលជាលិចក្នុងទឹកស្ទឹងហើយ” ទើបជិះទូកជាមួយនឹងកូនសិស្សទៅមើលឃើញព្រះអង្គគង់ក្នុងទីមានទឹកជាកំផែងជុំវិញ ក៏ប្រាប់ទ្រង់ឡើងគង់លើទូក ។ ព្រះអង្គមិនឡើងហើយក៏ហោះទៅក្នុងអា-

Websites: WatKhemaraRatanaram.org or WatKhmers.org

កាសវិញ ចុះពីអាកាសមក ទើបឋិតនៅលើទូកឱរុវេលកស្សប ។ ឱរុវេលកស្សបក៏នៅតែមានបរិវិតក្កដូចមុនទៀត ។

(៧) តតេ បដ្ឋាយ ចាប់ដើមអំពីព្រះអង្គយាងចាកព្រៃឥសិបតនៈក្នុងរនោចខែកត្តិក មកគង់ឯប្រទេសឱរុវេលា រាប់ជាខែបានពីរខែ ដរាបដល់ពេញបូណ៌មីខែបុស្ស ។ ក្នុងរវាងនេះទ្រង់សំដែងបានឫទ្ធិបាដិហារិយ៍ផ្សេងៗចំនួន១៥០០បែប, ក៏ឱរុវេល-កស្សបនៅតែរឹងរូសដដែល ។ ព្រះសាស្ដាទ្រង់ព្រះបរិវិតក្កថា "តថាគតគួរញ៉ាំងជដិលនេះឱ្យតក់ស្លុត" ទើបមានព្រះពុទ្ធដីកានឹងកស្សបថា "ម្នាលជដិល, អ្នកមិនមែនជាអរហន្តវិសេសទេ ម្ដេចក៏ប្រកាន់ថាជាអរហន្តវិសេស?" កស្សបបានឮព្រះពុទ្ធដីកាក៏ខ្លាចក្រាបទៀបព្រះបាទា ហើយទូលសូមបព្វជ្ជានឹងឧប-សម្បទា ។ ព្រះសាស្ដាទ្រង់បង្គាប់ឱ្យទៅលាជដិលជាសិស្សទាំង ៥០០ ។ កស្សបទទួលតាម ។ ពួកកូនសិស្សក៏ព្រមបួលបួសផង ហើយយកគ្រឿងបរិក្ខារបណ្ដែតទឹកបោលទាំងអស់ ។ ព្រះសាស្ដាជាម្ចាស់ទ្រង់ករុណាប្រទានបព្វជ្ជា នឹងឧបសម្បទាជាឯហិភិក្ខុ ។ នទីកស្សបោ បន ចំណែកនទីកកស្សបក្ដី គយាកស្សបក្ដី បានឃើញគ្រឿងបរិក្ខារអណ្ដែតទឹកទៅដូច្នោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ក៏នាំទឹកស្សបនាំបរិវារ៣រយ គយាកស្សបនាំបរិវារ ២ រយ មកកាន់សំណាក់ឱរុវេលកស្សប ហើយសាកសួរដឹងហេតុទាំងពួង ក៏បណ្តែតគ្រឿងបរិក្ខារក្នុងទឹកទាំងអស់ ហើយសូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះសាស្តាប្រទានឧបសម្បទាជាឯហិភិក្ខុស្រេចហើយ ទើបទ្រង់សំដែងអាទិត្តបរិយាយសូត្រ លុះចប់ក៏ជដិលទាំង១ពាន់នាក់ បាតសម្រេចអរហត្ត ។

(៨) ភគវា តេសំ ឧបនិស្សយំ ញត្វា ឯព្រះ-ដ៏មានព្រះភាគ ទ្រង់ជ្រាបនូវឧបនិស្ស័យក្នុងបុរេជាតិ នៃជដិលទាំងនោះ ទ្រង់ប្រទានធម៌ទេសនាឱ្យឋិតនៅក្នុងមគ្គនឹងផល ព្រះអង្គមានព្រះខីណាស្រពជាបរិវារយាងទៅកាន់លដ្ឋិ-វនុយ្យានជាឧបចារនៃនគររាជគហ ដើម្បីដោះបដិញ្ញានៃព្រះ-បាទពិម្ពិសារ ។ នាយឱទ្យានបានឃើញព្រះអង្គ ក៏ទៅក្រាបបង្គំទូលព្រះរាជា ។ ព្រះមហាក្សត្រទ្រង់ជ្រាបហើយក៏យាងចេញពីនគរមួយអន្លើដោយព្រាហ្មណ៍នឹងគហបតី ១២ម៉ឺន ទៅកាន់ឧទ្យាន ដល់ហើយថ្វាយបង្គំស្រេចស្តេចគង់ក្នុងទីគួរមួយ ។ បំណែកព្រាហ្មណ៍នឹងគហបតីពួកខ្លះ ថ្វាយបង្គំហើយអង្គុយនៅ ពួកខ្លះថ្វាយបង្គំហើយ ក៏ពោលនូវសម្មោទនីកថាផ្សេងៗ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ពួកខ្លះក៏ស្ងៀម ពួកខ្លះក៏មានបរិវិតក្កថា ព្រះមហាសមណៈប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ឧរុវេលកស្សប ឬឧរុវេលកស្សបប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមហាសមណៈ អ្នកណាប្រសើរជាងអ្នកណា! លំដាប់នោះ ព្រះមហាករុណាទ្រង់ជ្រាបចិត្តវារៈដោយញាណព្រះអង្គ ទើបមានព្រះពុទ្ធដីកានឹងឧរុវេលកស្សប ឱ្យកាត់សេចក្ដីសង្ស័យនៃពួកព្រាហ្មណ៍នឹងគហបតី ។ ឧរុវេលកស្សបបានដឹងពុទ្ធាធិប្បាយ ក៏ហោះឡើងកាន់អាកាសកំពស់មួយដូវត្នោត ចុះមកថ្វាយបង្គំម្ដង ដរាបដល់កំពស់៧ដូវត្នោត ក៏បញ្ចេញវាចាថា "ព្រះពុទ្ធជាម្ចាស់ជាគ្រូនៃខ្ញុំ ខ្ញុំជាសាវ័កនៃព្រះពុទ្ធជាម្ចាស់" គ្រប់វារៈទាំង៧ដង ។ មហាជនមានចិត្តជ្រះថ្លានឹងបាដិហារិយ៍ ក៏ពោលសរសើរព្រះពុទ្ធគុណគ្រប់គ្នា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងនូវមហានារទ-ជាតកដោយពិស្ដារ លុះចប់ព្រាហ្មណ៍នឹងគហបតី ១១ម៉ឺនមានព្រះរាជាជាប្រធាន ក៏បានឋិតនៅក្នុងសោតាបត្តិផល ។ ព្រាហ្មណ៍នឹងគហបតី ១ម៉ឺនទៀត បានឋិតនៅក្នុងព្រះត្រៃសរណគមន៍ ។

(បប់ឧរុវេលគមនបរិច្ឆេទ ទី១៦)

---

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រួន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

# អគ្គសាវកបព្វជ្ជាបរិច្ឆេទ ទី១៧

(១) តេន ខោ បន សមយេន អឌ្ឍតេរសានិ ភិក្ខុសតានិ ... 

(១) តេន ខោ បន សមយេន អង្គារសកោដិ- មត្តា រាជគហវាសិនោ ក្នុងសម័យនោះឯង ជនទាំងឡាយ អ្នកក្រុងរាជគ្រឹះមានចំនួន១៨កោដិ( ១ ) ទោះបីអ្នកដែលបាន ឃើញព្រះសាស្តាហើយក្តី អ្នកដែលពុំទាន់បានឃើញក្តី ទាំងប្រុសទាំងស្រី សុទ្ធតែមានសេចក្តីប្រាថ្នា ចង់ទស្សនាការនូវ សម្តេចព្រះភគវន្តអនន្តញ្ញាណ ក៏បានប្រញាប់ប្រញាល់ចូលទៅកាន់ លដ្ឋិវនុយ្យានជាទីឋានដែលព្រះអង្គគង់នៅ ។ ទីឧទ្យាននេះ មានកន្លែងសល់បន្តោះ ពាសពេញដេរដាសសព្វទីទាំងអស់ ដោយប្រជាជននិករ ។

(២) តេន ខោ បន សមយេន សក្កោ ទេវានមិន្ទោ ក្នុងសម័យនោះ សម្តេចសក្កទេវរាជជាធំជាងទេវតាទាំងឡាយ ប្លែកភេទជាមាណពម្នាក់ ចូលមកក្នុងទីចំពោះព្រះភក្ត្រនៃព្រះ បរមសាស្តា ធ្វើទីដែលចង្អៀតឱ្យប្រាសចាកមហាជនដោយ

---

១ វិន័យបិដកត្រង់មហាខន្ធកៈមានសេចក្តីថា ព្រាហ្មនិងគហបតី ជារាជបរិញ្ញ មានចំនួន ១២ហ្មឺន ។ ក្នុងគម្ពីរបឋមសម្ពោធិ មានចំនួន ១៨កោដិដូច្នេះ គឺសំដៅ ដល់សាធារណជនទាំងពួង ទាំងអ្នកតាមមើលលោង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទេវានុភាព, កាលដែលព្រះសាស្ដាទ្រង់ស្ដេចចូលទៅកាន់ក្រុងរាជគ្រឹះ, មាណពនោះក៏បើកផ្លូវនាំមុខព្រះសាស្ដាទៅ ហើយច្រៀងសរសើរពុទ្ធគុណបណ្ដើរ ។ បណ្ដាជនទាំងឡាយឃើញហើយសួរគ្នាថា យីអើហ្ន៎! មាណពនេះមានរូបល្អអ៊ីម្ល៉េះ! គួរឱ្យពិតពិលរមិលមើល គួរជាទីជ្រះថ្លា ជាកូនចៅនរណា? មាណពនោះក៏ឆ្លើយឡើងជាបទព្រះគាថា ថា:

យោ ធីរោ សព្វធិ ទន្តោ សុទ្ធោ អប្បដិបុគ្គលោ
អរហំ សុគតោ លោកេ តស្សាហំ បរិចារកោ

សេចក្ដីថា: អ្នកប្រាជ្ញណា ទូន្មានឥន្ទ្រិយបានទាំងអស់ហើយ មានព្រះហឫទ័យស្អាត រកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវពោលគឺកិលេស មានដំណើរល្អក្នុងលោក ខ្ញុំឯងជាអ្នកបម្រើអ្នកប្រាជ្ញនោះ ។

ព្រះដ៏មានព្រះភាគមួយអន្លើដោយព្រះភិក្ខុសង្ឃ ទ្រង់យាងចូលទៅកាន់ព្រះរាជនិវេសន៍ នៃព្រះបាទមាគធសេនិយពិម្ពិសារ ។ ព្រះរាជាទ្រង់អង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឱ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារ ទើបទ្រង់ព្រះចិន្តាថា “វេឡុវ័នឧទ្យានមិនឆ្ងាយពេកមិនជិតពេក ជាទី

Websites: WatKhemaraRatanaram.org or WatKhmers.org

ល្មមទៅមកបានដោយងាយ, គួរអាត្មាអញថ្វាយឧទ្យាននេះ ដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន” ហើយទ្រង់ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា “ខ្ញុំព្រះអង្គសូមថ្វាយនូវឧទ្យានវេឡុវ័ន បំពោះព្រះអង្គនឹងព្រះភិក្ខុសង្ឃ” ។ ព្រះសាស្ដាក៏ទ្រង់ទទួល គង់នៅក្នុងឧទ្យានវេឡុវ័ននោះ ហើយទ្រង់អនុញ្ញាតអារាមដល់ព្រះភិក្ខុសង្ឃ ។

(៣) តេន ខោ បន សមយេន សញ្ជយោ បរិព្វាជកោ សម័យនោះ សញ្ជយបរិព្វាជក នៅអាស្រ័យក្នុងក្រុងរាជគ្រឹះមួយអន្លើដោយបរិព្វាជកបរិស័ទច្រើន ចំនួន ២៥០រូប ។ ព្រះសារីបុត្តនិងព្រះមោគ្គល្លាន ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់សញ្ជយបរិព្វាជកនោះដែរ ។ លោកទាំងពីររូបនោះបានប្ដេជ្ញានឹងគ្នាថា អ្នកណាបានដឹងនូវអមតធម៌មុន, អ្នកនោះគប្បីប្រាប់ដល់ម្នាក់ទៀត ។

កាលនោះ ព្រះអស្សជិស្លៀកស្បង់ប្រដាប់ដោយបាត្រនឹងចីវរអំពីព្រឹក ប្រកបដោយឥរិយាបថរម្យទមគួរជាទីជ្រះថ្លា ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ បរិព្វាជកឈ្មោះសារីបុត្តបានឃើញព្រះអស្សជិដ៏មានអាយុក៏គិតថា “ឱហ្ន៎! ជន

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំងឡាយឯណាជាអរហន្តក្តី បានដល់ហើយនូវអរហត្តមគ្គក្តី ក្នុងលោក, ភិក្ខុនេះប្រហែលជាពួកនៃជនទាំងនោះដែរ, គួរតែអាត្មាអញចូលទៅរកភិក្ខុនេះ, ប៉ុន្តែកាលនេះជាកាលមិនគួរដើម្បីសួរនូវភិក្ខុនេះឡើយ ព្រោះលោកកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត” គិតដូច្នេះហើយក៏ដើរតាមជាប់ពីក្រោយទៅ កាលបើព្រះអស្សជិទទួលបិណ្ឌបាតហើយត្រឡប់មកវិញ បរិព្វាជកឈ្មោះសារីបុត្តក៏ចូលទៅជិត ធ្វើនូវសេចក្តីរីករាយពោលនូវពាក្យជាទីត្រេកអរល្មមឱ្យកើតសេចក្តីស្និទ្ធស្នាលបាន ក៏សួរព្រះអស្សជិថា “បពិត្រលោកដ៏មានអាយុ, ឥន្ទ្រិយរបស់លោកក៏ស្រស់បស់, សម្បុររបស់លោកក៏ស្អាតផូរផង់ តើលោកបួសចំពោះអ្នកណា? អ្នកណាជាគ្រូរបស់លោក? ព្រះអស្សជិឆ្លើយថា “ម្នាលអាវុសោ, មានមហាសមណៈមួយព្រះអង្គ ជាសក្យបុត្តចេញចាកសក្យត្រកូលហើយទ្រង់ព្រះផ្នួស, ខ្ញុំឯងក៏បួសតាមព្រះមហាសមណៈនោះ ព្រះដ៏មានព្រះភាគនោះឯងជាគ្រូរបស់ខ្ញុំ” ។ បរិព្វាជកឈ្មោះសារីបុត្តសួរថា “ចុះគ្រូរបស់លោកម្ចាស់ពោលពាក្យដូចម្តេច? សំដែងធម៌ដូចម្តេច? ព្រះអស្សជិឆ្លើយថា “ម្នាលអ្នកដ៏មានអាយុ, អាត្មាអញជាភិក្ខុថ្មី ទើបនឹងចូលមកកាន់ធម៌វិន័យថ្មីៗ អាត្មាមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

អាចដើម្បីសំដែងធម៌ដោយពិស្តារបានទេ, តែថាអាត្មានឹងពោលនូវសេចក្តីយ៉ាងខ្លីឱ្យអ្នកស្តាប់" ។ បរិព្វាជកឈ្មោះសារីបុត្តទូលថា "សូមលោកម្ចាស់សំដែង ទោះបីតិចក្តី ច្រើនក្តី ឱ្យឃើញតែទំនងជាលំអានមកចុះ មិនបាច់ពោលព្យញ្ជនៈឱ្យច្រើនឡើយ" ។

(៤) អថ ខោ អាយស្មា អស្សជិ គ្រានោះ ព្រះអស្សជិដ៏មានអាយុ បានពោលនូវធម្មបរិយាយនេះថា:

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច ឯវំវាទី មហាសមណោ ។

សេចក្តីថា ធម៌ទាំងឡាយឯណាតែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះផង មួយទៀតទ្រង់ពោលនូវសេចក្តីរលត់នឹងឧបាយជាគ្រឿងរលត់ នូវធម៌ទាំងឡាយនោះផង, ព្រះមហាសមណៈមានវាទៈយ៉ាងនេះជាប្រក្រតី ។

បរិព្វាជកឈ្មោះសារីបុត្រ បានស្តាប់ធម្មបរិយាយនេះហើយ ក៏មានធម្មចក្ខុគឺសោតាបត្តិមគ្គញ្ញាណ ប្រាសចាកធូលីប្រាសចាកមន្ទិលហើយចូលទៅរកបរិព្វាជកឈ្មោះមោគ្គល្លាន ។ បរិព្វាជកឈ្មោះមោគ្គល្លានបានឃើញពីចម្ងាយ ក៏សួរថា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

“ឥន្ទ្រិយរបស់អ្នកស្រស់បស់អ្វីម្ល៉េះ, ប្រហែលជាអ្នកបានដឹងនូវអមតៈធម៌ហើយឬ? បរិព្វាជកឈ្មោះសារីបុត្តក៏ប្រាប់តាមដំណើរ ។ បរិព្វាជកឈ្មោះមោគ្គល្លានបានស្ដាប់ហើយ ក៏មានធម្មចក្ខុប្រាសចាកធូលី ទើបប្រឹក្សាគ្នាថា “យើងនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ, ព្រះអង្គនោះជាគ្រូរបស់យើង” ។ បរិព្វាជកឈ្មោះសារីបុត្តឆ្លើយថា “បរិព្វាជកចំនួន២៥០នាក់អាស្រ័យនឹងយើង បានឃើញយើងទើបនៅក្នុងទីនេះបាន យើងត្រូវលាបរិព្វាជកទាំងនោះសិន” ។ ទើបសារីបុត្តនឹងមោគ្គល្លាន ក៏ចូលទៅរកបរិព្វាជកទាំងនោះ ដល់ហើយនិយាយប្រាប់ថា “យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ” ។ បរិព្វាជកទាំងនោះឆ្លើយថា “បើលោកទាំងឡាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមហាសមណៈ, យើងទាំងឡាយទាំងអស់គ្នា ក៏នឹងជាបុគ្គលដូច្នោះដែរ” ។ សារីបុត្រនឹងមោគ្គល្លាន ក៏បបួលគ្នាចូលទៅកាន់សំណាក់សញ្ជយបរិព្វាជកពិតទូលតាមបំណងរបស់ខ្លួន ។ សញ្ជយបរិព្វាជកឆ្លើយថា “មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ យើងទាំង៣នាក់នឹងគ្រប់គ្រងរក្សាគណៈនេះ” ។ សារីបុត្រនឹងមោគ្គល្លាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជួន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទទួចនិយាយអង្វរករអស់វារៈពីរដងបីដង ក៏សញ្ជយបរិព្វាជក មិនព្រមយល់តាម ទើបសារីបុត្រនឹងមោគ្គល្លាន ក៏នាំពួក បរិព្វាជកទាំង ២៥០នាក់ នោះចូលទៅកាន់វត្តវេឡុវ័នទៅ ។ ចំណែកខាងសញ្ជយបរិព្វាជក ក៏មានសេចក្ដីទោមនស្សផ្ដុត ឡើងបណ្ដាលឱ្យក្ដៅក្រហាយ រហូតដល់ក្អួតឈាមចេញពីមាត់ ។

(៥) អទ្ទសា ខោ ភគវា សារីបុត្តមោគ្គល្លានេ ទូរ-តោវ អាគច្ឆន្តេ ទិស្វា ព្រះដ៏មានព្រះភាគទ្រង់ទតឃើញ សារីបុត្តនឹងមោគ្គល្លាន កំពុងដើរមកពីចម្ងាយលឹមៗ ក៏ទ្រង់ ត្រាស់ហៅភិក្ខុទាំងឡាយមកថា “ម្នាលភិក្ខុទាំងឡាយ, ជនជា សំឡាញ់នឹងគ្នាទាំងពីរនាក់នោះ ឈ្មោះកោលិត១ ឈ្មោះ ឧបតិស្ស១ នឹងមកដល់ឥឡូវនេះហើយ, ហ្នឹងហើយជាគូនៃ សាវ័ករបស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចំរើន ។

(៦) អថ ខោ សារីបុត្តមោគ្គល្លានា គ្រានោះ ព្រះសារីបុត្តនឹងមោគ្គល្លាន ចូលទៅកាន់សំណាក់ព្រះដ៏-មានព្រះភាគ សូមបព្វជ្ជានឹងឧបសម្បទាថា “បពិត្រព្រះអង្គ ដ៏ចំរើន យើងខ្ញុំទាំងឡាយគប្បីបាននូវបព្វជ្ជានឹងឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ” ។ ព្រះដ៏មានព្រះភាគទ្រង់

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយចូរមកចុះ, ធម៌តថាគតសំដែងហើយដោយប្រពៃ អ្នកទាំងឡាយចូរប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ" ។ ព្រះពុទ្ធដីកានេះឯងជាឧបសម្បទារបស់លោកដ៏មានអាយុទាំងនោះ ។

(៧) តេន ខោ បន សមយេន អភិញ្ញាតា មាគធិកា កុលបុត្តា សម័យនោះឯង កុលបុត្រទាំងឡាយអ្នកដែលមគធៈ ដែលមានឈ្មោះល្បីល្បាញៗ ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគដែរ ។ មនុស្សទាំងឡាយក៏ថ្កោលទោសឡើងថា "សមណគោតមប្រតិបត្តិដើម្បីធ្វើមនុស្សមិនឱ្យមានកូន ដើម្បីធ្វើឱ្យពួកស្រីៗ ទៅជាមេម៉ាយ ដើម្បីផ្តាច់វង្សត្រកូល ឥឡូវនេះបបួលជដិលចំនួន ១០០០នាក់ ហើយបបួលទាំងបរិព្វាជកចំនួន ២៥០នាក់ ជាពួកសញ្ជ័យទៅទៀតផង បបួលកុលបុត្រដែលមានឈ្មោះល្បីល្បាញៗ ទៀតផង តើតទៅទៀតនឹងនាំអ្នកណាទៅទៀត" ។ ភិក្ខុទាំងឡាយបានឮហើយ ក៏ទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា "ម្នាលភិក្ខុ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំងឡាយ សំដីនេះមិនមាននៅអស់កាលយូរប៉ុន្មានទេ យ៉ាងយូរណាស់ត្រឹម៧ថ្ងៃ កន្លងហួស៧ថ្ងៃទៅនឹងបាត់ទៅឯង ម្នាលភិក្ខុទាំងឡាយ បើគេចោទដូច្នោះទៀត អ្នកទាំងឡាយ ចូរចោទគេវិញថា "ព្រះតថាគតទាំងឡាយ មានសេចក្តីព្យាយាមមាំ ណែនាំសត្វដោយព្រះសទ្ធម្មដោយប្រពៃពិត, ហេតុដូចម្តេច ក៏មានសេចក្តីប្រណែនពួកអ្នកប្រាជ្ញដែលជាអ្នកណែនាំដោយធម៌ ។

(៨) អថាយស្មា មហាមោគ្គល្លានោ គ្រានោះព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅអាស្រ័យនូវស្រុកកល្លវាឡគ្រាមក្នុងដែនមគធៈ ក្នុងថ្ងៃទី៧រាប់ពីថ្ងៃដែលបួសមក លោកបានស្តាប់នូវធាតុកម្មដ្ឋាន បានសម្រេចនូវប្រជុំបីនៃមគ្គខាងលើហើយដល់នូវសាវកបារមីញាណ ។ ឯព្រះសារីបុត្រកន្លងកន្លះខែពីថ្ងៃដែលបួសមក លោកគង់នៅក្នុងគុហាឈ្មោះសុករខាតៈ បានស្តាប់នូវវេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាកំពុងសំដែងដល់ទីឃនខបរិព្វាជកជាក្មួយរបស់ខ្លួន ក៏បានសម្រេចនូវសាវកបារមីញាណ ដូចជាបុគ្គលបរិភោគភត្ត ដែលដួសមកដើម្បីបុគ្គលដទៃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្នុងថ្ងៃនោះឯង សម្តេចព្រះបរមសាស្តាទ្រង់ធ្វើនូវសាវកសន្និបាតក្នុងវត្តវេឡុវ័ន ទ្រង់ប្រទានទូវទីជាអគ្គសាវ័កដល់ព្រះថេរៈទាំងពីរនោះ ទ្រង់សំដែងនូវឱវាទបាតិមោក្ខក្នុងថ្ងៃ១៥កើត ខែ មាឃ(១) ឆ្នាំរកា ។

(បប់អគ្គសាវកបព្វជ្ជាបរិច្ឆេទ ទី១៧)

## កបិលវត្ថុគមនបរិច្ឆេទ ទី១៨

(១) ឯវំ ភគវា ទីហិ សាវកប្បមុខេហិ កាលដែលព្រះដ៏មានព្រះភាគគង់ក្នុងវត្តវេឡុវ័នមួយអន្លើ ដោយភិក្ខុសង្ឃជាច្រើន មានអគ្គសាវ័កទាំងពីរជាប្រធាន ក្នុងកាលនោះព្រះបាទសិរសុទ្ធោទន៍ទ្រង់ជ្រាបដំណឹងថា ព្រះអង្គគង់ក្នុងទីនោះ ទើបត្រាស់ព្រះរាជបញ្ជាឱ្យអាមាត្យម្នាក់នាំបរិវារ១ពាន់ ទៅនិមន្ត ។ អាមាត្យក៏ទទួលតាមព្រះរាជឱង្ការ នាំបរិវារទៅកាន់នគររាជគហៈចម្ងាយផ្លូវ៦០យោជន៍ ដល់ហើយក៏ចូលទៅស្តាប់ធម្មទេសនា លុះចប់បានសម្រេចអរហត្តទាំងអស់គ្នា ហើយចូលសូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះអង្គទ្រង់ប្រទានឯហិ

(១) ថ្ងៃនេះដែលពុទ្ធសាសនិកជនធ្វើបុណ្យមាឃបូជា ជាទីរឭកដល់សាវកសន្និបាត និងការសម្តែងបាតិមោក្ខដំបូង របស់ព្រះដ៏មានព្រះភាគ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុឧបសម្បទា ។ អាមាត្យទាំងអស់ភ្លេចមិនបានទូលតាមព្រះរាជបណ្តាំ ។ ទើបព្រះបាទសិរីសុទ្ធោទន៍បញ្ជូនអាមាត្យទៅទៀតតាមទំនងនេះ ទាំងពីអាមាត្យម្នាក់បរិវារ ១ពាន់ដរាបដល់អាមាត្យ៩នាក់បរិវារ៩ពាន់ អស់វារៈ៩ដង ។

អាមាត្យទាំងអម្បាលនោះ សម្រេចកិច្ចរបស់ខ្លួនហើយស្ងៀមនៅទាំងអស់ ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា "អាមាត្យដែលទៅមិននិមន្តព្រះអង្គទៀត ។ កាឡុទាយីអាមាត្យក៏ទទួលតាមព្រះរាជឱង្ការ ហើយសូមឱ្យព្រះអង្គអនុញ្ញាតឱ្យបួស, កាលបើព្រះរាជាទ្រង់ព្រម ទើបនាំបរិវារ១ពាន់ ទៅដល់វត្តវេឡុវ័ន បានស្តាប់ធម៌ក៏បានសម្រេចព្រះអរហត្តមួយអន្លើដោយបរិវារ ហើយសូមបព្វជ្ជានឹងឧបសម្បទា ។ ព្រះអង្គទ្រង់បំបួសជាឯហិភិក្ខុទាំងអស់ ។ កាឡុទាយិត្ថេរក៏គិតថា "អាត្មាអញបានសម្រេចមគ្គផលហើយ កាលនេះគួរព្រះសាស្តាយាងកាន់នគរកបិលព័ស្តុ ក្នុងថ្ងៃបុណ្ណមីខែផល្គុន" ទើបចូលទៅក្រាបបង្គំទូលព្រះអង្គ ពោលសរសើរនូវផ្លូវទៅកាន់នគរកបិលព័ស្តុ ដោយគាថា៦០ ហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទូលបវត្តិហេតុថា “បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទសិរីសុទ្ធោទន៍ ជាព្រះពុទ្ធបិតា និរាសចាកព្រះអង្គយូរហើយ ទ្រង់មានព្រះរាជហឫទ័យចង់ឃើញព្រះអង្គ ទ្រង់ប្រើខ្ញុំព្រះអង្គមកនិមន្ត សូមព្រះអង្គធ្វើនូវសេចក្ដីសង្គ្រោះដល់ព្រះញាតិវង្ស។

(២) សាធុ សាធុ ឧទាយិ ករិស្សាមិ ព្រះដ៏មានព្រះភាគទ្រង់ទទួលថា “ម្នាលឧទាយិ ប្រពៃហើយ, តថាគតនឹងធ្វើសេចក្ដីសង្គ្រោះដល់ញាតិ អ្នកចូរប្រាប់ដល់ភិក្ខុសង្ឃចុះ” ។ ព្រះថេរៈក៏ប្រាប់ដល់ភិក្ខុសង្ឃ ។ ព្រះដ៏មានបុណ្យមានភិក្ខុសង្ឃ ២ម៉ឺនអង្គជាបរិវារយាងចាកនគររាជគហៈទៅដល់កបិលវត្ថុបុរី ចម្ងាយផ្លូវ៦០យោជន៍ ។ បំណែកស្ដេចសក្យរាជមានពុទ្ធបិតាជាប្រធានបានឮដំណឹងថា ព្រះអង្គយាងមក មានសេចក្ដីសោមនស្សណាស់ ក៏ប្រជុំគ្នាតាក់តែងផ្លូវលើកទង់ រាយរាយផ្កាចាំទទួលព្រះអង្គ ហើយបញ្ជូនរាជកុមារីមានវ័យក្មេងជាងព្រះអង្គឱ្យទៅទទួលមុន ។ លំដាប់នោះព្រះសាស្ដាយាងឡើងកាន់ទូកឆ្លងទៅដល់ត្រើយនាយ ឡើងចាកទូកទ្រង់សំដែងរូបសិរី ផ្សាយទៅនូវឆព្វណ្ណរង្សី យាងចូលទៅកាន់និគ្រោធារាមមួយអន្លើដោយ ព្រះខីណាស្រព ២ម៉ឺនអង្គ ដល់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយគង់លើពុទ្ធាសនៈដ៏ប្រសើរ។ ស្តេចសក្យរាជទាំងពួងមាន ព្រះបាទសុទ្ធោទន៍ជាប្រធាន ប្រកាន់ខ្លួនថា ចាស់ជាងព្រះអង្គ ក៏មិនបានថ្វាយបង្គំ ។ គ្រានោះព្រះសាស្តាជ្រាបអធ្យាស្រ័យព្រះញាតិ ក៏ទ្រង់សំដែងយមកប្បាដិហារយ៍ និម្មិតទិបង្ក្រមកែវយាងចង្ក្រមក្នុងអាកាស ហើយនិម្មិតជាព្រះពុទ្ធមួយព្រះអង្គទៀតឱ្យដោះបញ្ហា ។ ទ្រង់ត្រាស់សួរបញ្ហា ។ ព្រះបាទសុទ្ធោ-ទន៍ឃើញបាដិហារិយ៍ មានបីតិសោមនស្សមិនអាចទប់បាន ក៏លើកអញ្ជលីថ្វាយបង្គំ ដើម្បីឱ្យព្រះអង្គអត់ទោស ។ ព្រះរាជាថ្វាយបង្គំក្នុងកាលនោះ ឈ្មោះតតិយវន្ទនា ។ ស្តេចសក្យរាជទាំងអស់ឃើញព្រះពុទ្ធបិតាថ្វាយបង្គំព្រះអង្គហើយ ទើបយាងចុះបាកអាកាសមកគង់លើពុទ្ធាសនៈវិញ ។ ខណៈនោះភ្លៀងបោក្ខរ-ព័ស្សក៏ធ្លាក់ចុះ ។ ព្រះអង្គប្រារព្ធភ្លៀងបោក្ខរព័ស្ស សំដែងនូវមហាវេស្សន្តរជាតក ។ លុះចប់ទេសនា ស្តេចសក្យរាជក៏ក្រោកបាកអាសនាថ្វាយបង្គំចៀសចេញទៅ នឹងមានអ្នកណាមួយនិមន្តព្រះអង្គឱ្យសោយក្នុងវេលាស្អែកទៀតក៏ទេ ។

(៣) បុនទិវសេ ភគវា លុះដល់ថ្ងៃស្អែកឡើង ព្រះដ៏មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះភាគទ្រង់មានភិក្ខុសង្ឃ២ម៉ឺនអង្គជាបរិវារ យាងចូលទៅកាន់នគរក្នុងភិក្ខាចារវេលា ត្រាច់ទៅដើម្បីបិណ្ឌបាត ផ្សាយទៅនូវរស្មី៦ពណ៌ព្រះអង្គឈរទៀបគោលថ្មឥន្ទខីលពិចារណាថា ព្រះពុទ្ធពីបូរាណចូលទៅកាន់នគរ ដើម្បីទទួលភិក្ខារបស់រាជត្រកូលមុនឬដូចម្ដេច? ព្រះអង្គជ្រាបថា "ព្រះពុទ្ធពីដើមរមែងត្រាច់ទៅតាមដល់លំដាប់ត្រកូល ទទួលភិក្ខាបំពេញបិណ្ឌបាតចារិកវត្ត"ជ្រាបហើយក៏បរតាមលំដាប់ផ្ទះដើម្បីបិណ្ឌបាត ។ មហាជនក្នុងនគរឃើញព្រះអង្គ ក៏ផ្អើលឆោឡោស្ទុះទៅមើលរាល់គ្នាពោលថា "ព្រះសិទ្ធត្ថរាជកុមារត្រាច់បរបិណ្ឌបាត" ។ ចំណែករាហុលមាតាឮសំឡេងកោឡាហល ក៏សួរស្រីបំរើ ។ ស្រីទាំងឡាយទូលថា "ព្រះភស្ដានាងមកដល់នគរ ហើយកាន់បាត្រត្រាច់សូមភិក្ខា" ។ នាងពិម្ពាបានស្ដាប់ក៏គិតថា "ព្រះអយ្យបុត្តកោសក់ កោពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាវពស្ត្រ កាន់បាត្រដើរបិណ្ឌបាតដូចម្ដេចទៅ" ទើបនាងក្រោកយ៉ាងប្រញាប់ បើកសីហបញ្ជរ ទតឃើញព្រះអង្គមានព្រះកាយរុងរឿងដោយ អសីត្យានុព្យញ្ជនៈជាដើម, ព្រះនាងក៏ស្លុតព្រះរាជហឫទ័យទ្រូញយំ ស្ទុះប្រញាប់ទៅក្រាបបង្គំទូលព្រះបាទសិរីសុទ្ធោទន៍ថា "បពិត្រ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះសម្មតិទេព ព្រះអយ្យបុត្តព្រះអង្គត្រាច់បិណ្ឌបាត” ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយក៏កើតសង្វេគ ទ្រង់ម្ទីម្ទាបុះបាក ប្រាសាទចូលទៅកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ទូលថា “មិនគួរ ព្រះអយ្យបុត្តដើរបិណ្ឌបាតដូច្នេះសោះ! ខ្ញុំនេះជាមនុស្សកំសត់ ទុគ៌តមិនអាចថ្វាយភត្តាហារដល់ភិក្ខុសង្ឃទាំងអស់ឬ? ព្រះ សាស្ដាត្រាស់តបថា “មហារាជ, បិណ្ឌបាតចារិកវត្តនេះជាវង្ស នៃតថាគត ពុំមែនជាវង្សនៃខត្តិយជាតិទាំងពួងទេ, ដ្បិតថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងចិញ្ចឹមជីវិតដោយភិក្ខាចារិកវត្ត នេះ” ទើបព្រះអង្គសំដែងធម៌មានបទថា ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ដូច្នេះជាដើមដល់ព្រះវរបិតា លុះចប់គាថា ព្រះវរបិតាឋិតនៅ ក្នុងសោតាបត្តិផល ។

(ចប់កបិលវត្ថុគមនបរិច្ឆេទ ទី១៨)

---

## ពិម្ពាពិលាបបរិច្ឆេទ ទី១៩

(១) ទុតិយទិវសេ ភគវា លុះដល់ថ្ងៃជាគំរប់ពីរ សម្ដេច ព្រះភគវន្តមុនីជាទីពឹងនៃលោក ទ្រង់សំដែងធម៌ដល់ព្រះនាង បជាបតិគោតមី ។ កាលបើចប់ទេសនា ព្រះមាតុច្ឆាក៏ឋិត នៅក្នុងសោតាបត្តិផល ។ ព្រះពុទ្ធបិតាបានឋិតនៅក្នុង

Websites: WatKhemaraRatanaram.org or WatKhmers.org

សកទាគាមិផល ។

លុះដល់ថ្ងៃទីបី ព្រះជិនស្រីទ្រង់យាងទៅកាន់រាជនិវេសន៍ ព្រះពុទ្ធបិតាក៏ថ្វាយយាគូនឹងភត្តាហារ ដល់ភិក្ខុសង្ឃនឹងព្រះពុទ្ធជាម្ចាស់ ហើយក្រាបទូលថា "បពិត្រព្រះសាស្តា, កាលព្រះអង្គធ្វើទុក្ករកិរិយា មានទេវតា១អង្គ មកឋិតនៅក្នុងអាកាស ប្រាប់ខ្ញុំថា "ព្រះរាជបុត្តព្រះអង្គមិនសោយអាហារអស់៦ថ្ងៃ មានព្រះកាយស្គាំងស្គមដួលដេកធ្វើមរណកាល ក្នុងទីបំផុតនៃទីចង្ក្រមទៅហើយ" កាលដែលខ្ញុំឮពាក្យទេវតា, ខ្ញុំក៏តបទៅវិញថា "យើងមិនជឿពាក្យអ្នកទេ, ឯព្រះរាជបុត្តយើងបើមិនបានត្រាស់ដឹងជារាបណា ក៏មិនធ្វើមរណកាលជារាបនោះ", ទេវតាក៏ប្រាប់ទៀតថា "ព្រះរាជបុត្តដែលខំធ្វើទុក្ករកិរិយាអស់ព្រះជន្មទៅហើយ, ខ្ញុំក៏នៅតែមិនជឿពាក្យទេវតាទៀត" ។ ព្រះសាស្តាមានព្រះពុទ្ធដីកាតបទៅវិញថា "បពិត្រមហារាជ, កាលពីដើមតថាគតកើតជាពោធិសត្វ, អាចារ្យទិសាបាមោក្ខនាំឆ្អឹងពពែមកបង្ហាញព្រះអង្គប្រាប់ថា "បុត្រនៃអ្នកធ្វើកាលកិរិយាទៅហើយ", ព្រះអង្គមិនជឿថួបកាលឥឡូវនេះដែរ" ។ កាលបេសម្រេចភត្តកិច្ចហើយ ព្រះសាស្តាទ្រង់សំដែងមហាធម្មបាលជាតក ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

លុះបប់ព្រះវរបិតាបានសម្រេចអនាគាមិផល ។ ទើបព្រះសាស្ដាទេសនាភត្តានុមោទនា ។ បំណែកព្រះនាងបជាបតិគោតមីនឹងស្រីបំរើ ក៏អង្គុយស្ដាប់ធម៌ទេសនាក្នុងទីនោះ ។

(២) សុទ្ធោទនមហារាជា ព្រះបាទសុទ្ធោទនមហា-រាជ ទ្រង់ទតព្រះនេត្រទៅក្នុងពួកនាងនារី មិនបានឃើញនាងពិម្ពាទេវី ទើបត្រាស់សួរថា “ថ្ងៃនេះនាងយសោធរាពិម្ពាទេវីទៅណា ក៏មិនមក”? ទើបព្រះរាជាទ្រង់ប្រើស្រីបំរើឱ្យទៅអញ្ជើញ ។ នាងបេសកាទៅដល់ប្រាសាទនាងពិម្ពា ឃើញនាងទ្រង់សំពត់កាសាវពស្ត្រគង់នៅ នាងបេសកានឹតឱកាសនឹងទូល ក៏អង្គុយស្ងៀម ។ នាងយសោធរាឃើញនាងបេសកាក៏មានព្រះសុវណ្ណីថា ព្រះពុទ្ធជាម្ចាស់ដែលអាចឱ្យសម្រេចប្រយោជន៍ទាំងពួង អស់សេចក្ដីករុណាដល់ពិម្ពាហើយឬ បានជាទ្រង់កាត់អាល័យអស់សេចក្ដីស្នេហា ឱ្យតែពិម្ពានៅកំព្រាជាមួយនិងកូន? តាំងពីព្រះអង្គចេញចោលពិម្ពាទៅសាងបព្វជ្ជាពិម្ពាមានតែសេចក្ដីទោមនស្សក្ដៅក្រហាយក្នុងចិត្ត ដរាបដល់សព្វថ្ងៃ, ពិម្ពាស៊ីថ្នាំពិសឱ្យក្ស័យទៅជាជាងរស់នៅ ។ នាងបេសកាទូលតបទៅថា “បពិត្រព្រះនាង, ឥឡូវនេះព្រះវរបិតា

WAT KHEMARARATANARAM

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យខ្ញុំម្ចាស់មកអញ្ជើញ ដ្បិតព្រះពុទ្ធជាម្ចាស់យាងមកធ្វើភត្តកិច្ច គង់នៅក្នុងរាជនិវេសន៍ កំពុងសំដែងធម៌" ។ នាងពិម្ពាទ្រង់ព្រះសណ្ដាប់ពាក្យនាងបេសកា ក៏លើកព្រះករគក់ឱរាទ្រង់ព្រះកន្សែងបរិទេវនាការពិលាប, ទើបតបទៅថា "ព្រះវរបិតាឱ្យមកហៅយើងឱ្យឡើងទៅមើលព្រះភស្ដាឬប្រការម្ដេច? នាងបេសកាទូលថា "ម្នាលនាងបេសកា, ខ្លួនយើងជាស្រីកាឡកណ្ណីមានឥន្ទ្រិយវិកលគ្រប់ប្រការ នឹងឡើងទៅគាល់ ក្រែងអាប់ព្រះបេស្ដា, កាលមុនៗ ព្រះភស្ដាធ្លាប់ចេញចូលមកកាន់ទីលំនៅជានិច្ច, ចុះហេតុអ្វី ឥឡូវនេះក៏ឱ្យពិម្ពាទៅគាល់ឯទីដទៃវិញ? ចូរនាងទៅក្រាបទូលព្រះវរបិតាតាមពាក្យយើងថា "នាងពិម្ពាជាស្រីកាឡកណ្ណី បានជាព្រះរាជបុត្រចេញបោលទៅសាងបព្វជ្ជា ហេតុនេះយើងមិនទៅគាល់ទេ, មួយទៀត ចូរនាងក្រាបទូលថា "ពិម្ពាសូមថ្វាយបង្គំលាស្លាប់ក្នុងថ្ងៃនេះហើយ " ។ នាងបេសកាក៏ត្រឡប់មកក្រាបបង្គំទូលគ្រប់ប្រការ ។

(៣) តំ សុត្វា មហារាជា ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់សេចក្ដី ដែលនាងបេសកាក្រាបបង្គំទូលដូច្នោះហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្ដេចទ្រង់ទូលព្រះសម្ពុទ្ធឱ្យទ្រង់ជ្រាបគុណនាងពិម្ពា សព្វប្រការ ស្ដេចទ្រង់អារាធនានិមន្ដព្រះអង្គឱ្យយាងទៅ ។ ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់សេចក្ដីអារាធនាព្រះពុទ្ធបិតា ក៏មានព្រះពុទ្ធដីកាថា "គួរណាស់, បើតថាគតមិនទៅកាន់និវេសន៍នាងពិម្ពាក្នុងថ្ងៃនេះទេ, នាងនឹងបែកហឫទ័យក្ស័យពិត, មួយទៀតរាហុលមាតានេះមានគុណដល់តថាគតជាច្រើន អំពីអតីតកាលមក" ទើបព្រះអង្គក្រោកចាកអាសនា ប្រទានបាត្រថ្វាយព្រះវរបិតាឱ្យស្ដេចតាមទៅផង ទ្រង់ឱ្យភិក្ខុសង្ឃគង់ចាំក្នុងព្រះរាជនិវេសន៍ ព្រះអង្គយាងទៅជាមួយអគ្គសាវ័កទាំងពីរអង្គ ទ្រង់មានព្រះពុទ្ធដីកានឹងអគ្គសាវ័កថា "រាហុលមាតានេះមានគុណដល់តថាគតជាច្រើន, បើនាងមកទ្របាទាតថាគត, អ្នកកុំឃាត់ឡើយ" ទើបព្រះអង្គផ្សាយរស្មី ស្ដេចយាងទៅកាន់ប្រាសាទនាងពិម្ពា ដល់ហើយទ្រង់គង់លើអាសនា បង្គាប់នាងទាសីឱ្យទៅទូលព្រះនាង ។ ព្រះនាងពិម្ពាទ្រង់ព្រះសណ្ដាប់ហើយក្រោកចាកមកឃើញព្រះអង្គ ក៏បរិទេវនាការចូលទៅទ្រព្រះបាទា ហើយសំដែងហេតុទាំងពួងទូលព្រះសាស្ដា យកព្រះកេសាទ្រព្រះបាទាសោកាយ៉ាងខ្លាំង ។ ព្រះសាស្ដាមានព្រះពុទ្ធដីកា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

នឹងព្រះវរបិតាថា “ បពិត្រមហារាជ, នាងយសោធរាដែលមានចិត្តស្នេហាចំពោះតថាគតក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យដូចកាលពីមុនឡើយ, កាលនាងកើតជាសត្វតិរច្ឆាននោះមានចិត្តស្នេហាលើសនេះ” ទើបទ្រង់សំដែងចន្ទកិន្នរីជាតកដោយពិស្ដារបន្ធោរបង់សេចក្ដីសោកនាងពិម្ពា, លុះចប់ទេសនានាងសម្រេចសោតាបត្តិផល ។ ព្រះសាស្ដាទ្រង់យាងទៅកាន់វិហារវិញ ។

(ចប់ពិម្ពាពិលាបបរិច្ឆេទ ទី១៩)

---

## សក្យបព្វជ្ជាបរិច្ឆេទ ទី២០

(១) បតុត្ថេ ទិវសេ ក្នុងថ្ងៃជាគំរប់បួន ព្រះសាស្ដាយាងទៅកាន់និវេសន៍នន្ទកុមារ ដើម្បីទទួលបិណ្ឌបាតក្នុងវេលាកំពុងធ្វើវិវាហមង្គល គេហប្បវេសនាភិសេក ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទើបប្រទានបាត្រឱ្យនន្ទកុមារ ហើយសំដែងមង្គលកថាស្រេចក៏យាងចេញមក, ព្រះអង្គមិនទទួលបាត្រពីនន្ទកុមារ ។ នន្ទកុមារមិនហ៊ានថ្វាយ ក៏កាន់បាត្រយាងទៅតាមក្រោយទៅ ។ ស្រីបំរើឃើញព្រះនន្ទយាងតាមក្រោយព្រះសម្ពុទ្ធទៅ ក៏ចូលទៅទូលព្រះនាងជនបទកល្យាណី ។ ព្រះនាងជ្រាបហេតុនោះក៏ចេញមកផ្ដាំឱ្យត្រឡប់មកឆាប់ ។ ព្រះនន្ទក៏

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

តាមដរាបតែដល់និគ្រោធារាម ។ ព្រះអរហំសម្មាសម្ពុទ្ធទ្រង់សួរព្រះនន្ទថា អ្នកបួសឬ? ព្រះនន្ទមិនហ៊ានប្រកែក ក៏ទទួលថាបួស ។ ព្រះអង្គទ្រង់បំបួសក្នុងថ្ងៃនោះ ។ លុះដល់ថ្ងៃជាគំរប់៧ ព្រះនាងពិម្ពាតាក់តែងរាហុលកុមារ ហើយបញ្ជូនឱ្យមកសូមកំណប់ទ្រព្យ ក្នុងវេលាដែលព្រះអង្គយាងបិណ្ឌបាត ។ រាហុលតាមទៅដល់វិហារ ។ ព្រះគិតប្រទានលោកុត្តរសម្បត្តិ ទើបទ្រង់បង្គាប់ឱ្យព្រះសារីបុត្តបំបួស ។

បំណែកអនាថបិណ្ឌិកសេដ្ឋី កាលដែលជួបនឹងព្រះអង្គកាលគង់នៅក្នុងនគររាជគហៈ បានថ្វាយទានដល់ព្រះអង្គនឹងភិក្ខុសង្ឃ ហើយអារាធនាព្រះអង្គឱ្យនិមន្តទៅនគរសាវត្ថី , គហបតីត្រឡប់ទៅ ក៏ធ្វើជេតវនវិហារទុកថ្វាយ ។

គ្រានោះ ព្រះសាស្តាយាងចេញចាកនគរកបិលវត្ថុទៅកាន់នគរសាវត្ថី ។ កាលដែលព្រះអង្គគង់ក្នុងជេតវនវិហារ, ព្រះនន្ទកើតអផ្សុកបង់សឹក ។ ព្រះអង្គបានជ្រាប ក៏លួងលោមឱ្យប្រព្រឹត្តព្រហ្មចរិយធម៌ ហើយនឹងឱ្យបានស្រីអប្សរ ។ ព្រះនន្ទខំប្រព្រឹត្តមិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត ទើបទៅដោះ បេ្តជ្ញានឹងព្រះសាស្តា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

(១) អថ ខោ ភគវា ចារិកំ ចរន្តោ លំដាប់នោះព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកជនបទ ទ្រង់គង់នៅក្នុងអនុបិយម្ពវ័នជិតស្រុកអនុបិយៈ ។ គ្រានោះ រាជត្រកូលដែលបានប្រេផ្លាថា នឹងថ្វាយព្រះរាជបុត្រ១អង្គៗ ជាបរិវារនោះបានចេញទ្រង់បព្វជ្ជាតាមជាច្រើន ។ បំណែកក្សត្រ ៦ព្រះអង្គគឺ ភទ្ទិយ១ អនុរុទ្ធ១ ភគុ១ កិម្ពិល១ អានន្ទ១ ទេវទត្ត១ មិនទាន់ចេញទ្រង់បព្វជ្ជានៅឡើយ ទើបសក្យៈទាំងពួងពោលថា "យើងរាល់គ្នាឱ្យកូនទៅបួសអស់ហើយ, ឯក្សត្រ៦ព្រះអង្គនេះមិនមែនជាព្រះញាតិទេដឹង បានជាមិនទៅបួស"។ លំដាប់នោះមហានាមសក្យៈជាបុត្រអមិត្តោទន មានព្រះបន្ទូលនឹងព្រះអនុរុទ្ធជាព្រះអនុជថា "ខ្លួនអ្នកក្តី ខ្លួនខ្ញុំឯងក្តី គួរទៅបួស" ។ អនុរុទ្ធតបទៅថា ទូលបង្គំពុំទៅទេ ។ មហានាមថា បើអ្នកមិនទៅបួស គួររៀនធ្វើការងារចុះ, ខ្ញុំនឹងទៅបួស ។ អនុរុទ្ធសួររឿងការងារ ។ មហានាមក៏សំដែងប្រាប់ការងារទាំងនោះមានកសិកម្មជាដើម ។ អនុរុទ្ធឃើញថាលំបាកណាស់ ។

ព្រះអនុរុទ្ធនេះជាក្សត្រប្រកបដោយសុខុមាលជាតិ ពុំដែលស្គាល់លំបាក, សូម្បីតែពាក្យថាគ្មានក៏ពុំដែលឮផង, បានជា

Websites: WatKhemaraRatanaram.org or WatKhmers.org

មានរឿងជាប់តមកថា ថ្ងៃមួយក្សត្រទាំង ៦ព្រះអង្គទ្រង់ក្រសាល អង្គុញជាមួយគ្នាភ្នាល់ដាក់នំថា “បើអ្នកណាចាញ់ ត្រូវយកនំមកសង” ។ អនុរុទ្ធបេះតែចាញ់រាល់ក្តា ក៏បញ្ជូនមនុស្សឱ្យទៅយកនំពីព្រះមាតា ដរាបដល់ព្រះមាតាប្រាប់ថានំគ្មានទេ ។ កាលអ្នកបំរើទៅក្រាបទូលតាមសេចក្តីនោះ, ព្រះអនុរុទ្ធក៏ប្រើឱ្យទៅយកនំគ្មាននោះមក ព្រោះពាក្យថាគ្មានព្រះអនុរុទ្ធមិនដែលឮ ។ ព្រះមាតាក៏ឱ្យយកភាជនៈទទេមកថ្វាយ ។ ទេវតាលបដាក់នំទិព្វក្នុងភាជនៈនោះ ។ អ្នកបំរើនាំយកទៅ ស្រាប់តែឃើញនំមានក្លិនប្លែក ។ ក្សត្រទាំង៦អង្គក៏នាំគ្នាសោយ ។ ព្រះអនុរុទ្ធសួរព្រះមាតាថា ហេតុអ្វីក៏ពីដើមមកទ្រង់ពុំប្រទាននំគ្មានដល់ទូលបង្គំ ? តាំងពីថ្ងៃនេះទៅ ទូលបង្គំពុំទទួលព្រះរាជទាននំដទៃទេ ។ ព្រះមាតាទ្រង់ព្រះសណ្តាប់ហើយក៏សួរអ្នកបម្រើ ។ អ្នកបំរើក្រាបទូលថា ភាជនៈដែលយកពីនេះទៅជាភាជនៈទទេលុះដល់ទៅទីក្រសាលអង្គុញ ក៏ស្រាប់តែឃើញនំពេញភាជនៈ ។ ព្រះមាតាទ្រង់ព្រះសណ្តាប់ហើយទ្រង់ព្រះចិន្តាថា “កូនអញបិតនៅជាយរាវាសដរាបណា ទេវតាក៏នឹងដាក់នំទិព្វឱ្យដរាបនោះមិនខាន” ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រឹន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

(៣) អចេកទិវសំ តយោ ខត្តិយា ថ្ងៃ ១ ជាខាងក្រោយមក ក្សត្រទាំង៣ព្រះអង្គសួរគ្នាថា ភោជនាហារកើតក្នុងទីឯណា? បំណែកកិម្ពិលឆ្លើយថា “ភោជនាហារកើតក្នុងជង្រុក” ។ ភទ្ទិយឆ្លើយថា “កើតក្នុងឆ្នាំង” ព្រោះឃើញគេដួសបាយអំពីឆ្នាំង ។ អនុរុទ្ធឆ្លើយថា “កើតក្នុងភាជន៍” លុះដល់គ្រាខាងក្រោយទើបជ្រាបថា “កើតអំពីស្រែ” ក៏មានសេចក្តីនឿយណាយក្នុងឃរាវាស ទើបបបួលគ្នាទាំង ៦អង្គសោយសម្បត្តិអស់ ៧ថ្ងៃហើយក៏ឱ្យបរិវារត្រឡប់មកវិញ ។ ក្សត្រទាំង ៦ អង្គនឹងឧបាលិកប្បកៈទៅដល់ដែនមល្លរដ្ឋ ក៏ដោះគ្រឿងអម្ពរឱ្យឧបាលិកប្បកៈយកទៅលក់ចិញ្ចឹមជីវិត ហើយយាងទៅ ។ ឧបាលិកប្បកៈទទួលបង្វិចត្រឡប់ដើរមកគិតថា “ធម្មតាសក្យ-រាជកាចណាស់ កាលបើឃើញអញបានគ្រឿងអម្ពរ មុខជាគិតថា “ឧបាលិនេះសម្លាប់រាជឱរសយកគ្រឿងអាភរណៈ“ ហើយនឹងធ្វើរាជទណ្ឌដល់អញពុំខាន ” ។ ឧបាលិគិតដូច្នោះហើយក៏យកបង្វិចព្យួរលើមែកឈើ ហើយទៅតាមក្សត្រទាំង ៦អង្គវិញ ។ ក្សត្រទាំង ៦អង្គឃើញឧបាលិមកដល់ក៏សួរសព្វគ្រប់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ទី

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រការ, កាលបើឧបាលិក្រាបទូលតាមដំណើរហើយ, ក៏នាំគ្នាទៅកាន់សំណាក់ព្រះសាស្ដា ទូលសូមឱ្យព្រះអង្គបំបួស ឧបាលិកប្បកៈជាមុន ដើម្បីបន្ទន់មានះរបស់ខ្លួន ។ ព្រះសាស្ដាក៏បំបួសឧបាលិមុនហើយ ទើបបំបួសក្សត្រទាំង៦អង្គជាខាងក្រោយ ។

បំណែកកភទ្ទិយបានសម្រេចវិជ្ជា ៣ ក្នុងវស្សានោះ ។ ព្រះអនុរុទ្ធបានទិព្វចក្ខុញ្ញាណ, គ្រាក្រោយកាលព្រះសាស្ដាទេសនាមហាបុរិសវិតក្កសូត្រ ក៏បានសម្រេចអរហត្តផល ។ ព្រះអានន្ទបានសម្រេចសោតាបត្តិផល ។ ព្រះភគុនឹងកិម្ពិលបំរើនវិបស្សនាបានសម្រេចព្រះអរហត្ត ។ ព្រះទេវទត្តបានរិទ្ធិជាបុថុជ្ជន ។ លំដាប់នោះព្រះពុទ្ធជាម្ចាស់ទ្រង់យាងទៅនគរកោសម្ពីមហាជននាំគ្រឿងសក្ការៈទៅថ្វាយ ក៏សួររកត្រឹមតែព្រះសាស្ដានឹងអសីតិសាវ័ក, ត្រង់ទេវទត្តឥតនរណាសួររកសោះ ។ ទេវទត្តអន់ចិត្តស្វែងរកពួកបានហើយ ព្យាយាមធ្វើកម្មអាក្រក់ជរាបដល់ព្រះធរណីស្រូបយកទៅ ។

(ចប់សក្យបព្វជ្ជាបរិច្ឆេទ ទី២០)

Websites: WatKhemaraRatanaram.org or WatKhmers.org

# មេត្តេយ្យព្យាករណបរិច្ឆេទ ទី២១

(១) និមន្តំ ពុទ្ធុប្បាទេ ក្នុងកាលពុទ្ធុប្បាទនៃព្រះសព្វញ្ញូជាម្ចាស់នៃយើងនេះ ព្រះមេត្តេយ្យពោធិសត្វមកកើតក្នុងផ្ទៃនៃនាងកញ្ញាទេវីជាអគ្គមហេសីនៃព្រះបាទអជាតសត្តុរាជ, លុះគ្រប់ទសមាសកាលណា ក៏ប្រសូតចាកឧទរព្រះមាតា បាននាមថា "អជិតកុមារ" មានវ័យចំរើនដោយលំដាប់មក ទើបមានព្រះរាជហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ អជិតកុមារបានឃើញពុទ្ធរូបសិរី បានស្តាប់ទេសនា ក៏គិតថា "បុគ្គលដែលមិនបានឱ្យទានរក្សាសីលជាដើម មិនអាចត្រាស់ដឹងសព្វញ្ញុតញ្ញាណបានឡើយ" ទើបលាព្រះបិតាទៅទ្រង់បព្វជ្ជា បានឧបសម្បទាមួយអន្លើដោយបរិវារ១ពាន់ ហើយបានរៀននូវព្រះពុទ្ធវចនៈបេះចាំប្រើនបង្ហាញព្រះត្រៃបិដកដល់ភិក្ខុជាច្រើន។

កាលដែលព្រះសាស្តា ទ្រង់ត្រឡប់មកកាន់នគរកបិលវត្ថុក្នុងលើកទី២ ទ្រង់គង់នៅក្នុងវត្តនិគ្រោធារាម, ព្រះនាងបជាបតិគោតមីទ្រង់ព្រះចិន្តាថា "អាត្មាអញគ្មានវត្ថុអ្វីថ្វាយព្រះពុទ្ធជាម្ចាស់ទេ គួរតែអញនឹងថ្វាយចីវរសាដក, បើនឹងទិញ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

សំពត់មានថ្លៃច្រើន ក៏ពេញជាគួរហើយ, តែបើអាត្មាអញត្បាញសំពត់ដោយដៃខ្លួនវិញ ទើបរឹតតែគួរជាង "ហើយព្រះនាងឱ្យជាងធ្វើផើងមាស៧ យកមកដាក់ដីដាំគ្រាប់ក្របាសស្រោចដោយទឹកដោះគោ, លុះដល់ក្របាសដុះឡើងមានផ្កាផ្លែ, នាងក៏បេះដោយព្រះហស្ត នាងយកមកធ្វើជាសំឡីរវៃជាអម្បោះដរាបដល់ត្បាញជាសំពត់ សាដកពីរផ្ទាំង, ១ផ្ទាំងៗ បណ្តោយ១៤ហត្ថ ទទឹង៥ហត្ថ ដូចគ្នាទាំងពីរផ្ទាំង ទើបនាងបត់សាដកនោះដាក់ក្នុងប្រអប់មាសព្រមទាំងសំពត់ដទៃផង ហើយឱ្យស្រីបរិវារកាន់ដើរតាមក្រោយទៅកាន់និគ្រោធារាម ដល់ហើយនាងថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានទៀបបាទាព្រះសម្មាសម្ពុទ្ធ, ព្រះនាងលើកសំពត់ថ្វាយ ក្រាបទូលតាមដំណើរ ដើម្បីឱ្យព្រះអង្គទទួលអនុគ្រោះដល់នាង ។

(២) សត្ថា តំ សុត្វា ព្រះសាស្តាទ្រង់ព្រះសវនាការហើយតបថា "បពិត្រព្រះនាងបជាបតិគោតមី, ចូរព្រះនាងថ្វាយសំពត់នេះដល់សង្ឃនឹងមានផលច្រើន" ។ ព្រះនាងបជាបតិគោតមី អង្វរអស់វារៈ២ដង៣ដង ក៏ព្រះសាស្តានៅតែបង្គាប់ឱ្យនាងថ្វាយដល់សង្ឃ ។ បំណែកពុទ្ធាធិប្បាយដែលឱ្យនាងថ្វាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់សង្ឃផ្ងប្ហោះព្រោះព្រះអង្គប្រាថ្នាដើម្បីសំដែងគុណ ព្រះសង្ឃដែលមានជាតំណមកខាងក្រោយ ។ ព្រះនាងបជាបតិគោតមី ... ព្រះនាងបជាបតិគ្ងប ព្រះរាជហឫទ័យ ក៏ទៅរកព្រះអានន្ទឱ្យជួយអង្វរ។ ព្រះអង្គក៏នៅតែមិនព្រមទទួល ទើបទ្រង់សំដែងបាដិបុគ្គលិកទាននឹងសង្ឃទាន ។ នាងទ្រង់ព្រះសណ្ដាប់ធម៌ទេសនាមានសេចក្ដីជ្រះថ្លា ទើបលើកសំពត់ថ្វាយដល់ព្រះសង្ឃ ដំកល់ទុកទៀបទីជិតព្រះសារីបុត្រ ។ ព្រះសារីបុត្រមិនទទួល ។ នាងនាំយកទៅប្រគេនព្រះថេរៈជាលំដាប់ៗ មិនមានអង្គណាមួយទទួលឡើយ ។ នាងនាំទៅដំកល់ទុកក្នុងទីជិតអជិតភិក្ខុទើបនឹងបួសថ្មីគង់ចុងអាសន៍បំផុត ។ អជិតភិក្ខុក៏ទទួលយកសំពត់នោះ ។ ព្រះនាងក៏កើតសេចក្ដីទោមនស្ស ។ ព្រះសាស្ដាជ្រាបហើយទ្រង់ឱ្យព្រះអានន្ទយកបាត្រមកថ្វាយ, កាលព្រះអានន្ទនាំបាត្រមក, ទ្រង់អធិដ្ឋានថា "សាវ័កទាំងពួងកុំឱ្យបានបាត្រនេះ, សូមឱ្យអជិតភិក្ខុបានបាត្រនេះចុះ" ទើបព្រះអង្គបោះបាត្រទៅក្នុងអាកាស ។ ព្រះសារីបុត្រទូលថា ខ្ញុំព្រះអង្គនឹងទៅរកបាត្រមកថ្វាយ ។ ព្រះអង្គក៏អនុញ្ញាត ។ ព្រះថេរៈទៅរកមិនឃើញ ។ ព្រះថេរៈទាំងអស់ទៅរកក៏មិនឃើញទៀត ។ លំដាប់នោះព្រះអង្គទ្រង់ត្រាស់

Websites: WatKhemaraRatanaram.org or WatKhmers.org

បង្គាប់ឱ្យអជិតភិក្ខុរកបាត្រ ។ អជិតក៏គិតថា “ព្រះថេរៈទាំងពួង ប្រកបដោយរិទ្ធិរកបាត្រព្រះអង្គមិនឃើញ, អាត្មាអញជាបុថុជ្ជន ក៏មិនអាចនឹងរកឡើយ “គិតហើយក៏ទទូលថា “ខ្ញុំព្រះអង្គនឹងរក បាត្រក្នុងវេលានេះ” ទើបអជិតភិក្ខុរមិលមើលអាកាសហើយ អធិដ្ឋានថា “អាត្មាអញបួសគ្មានប្រាថ្នាលាភ, ប្រាថ្នាតែ ប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងនឹង បម្លងសត្វលោក សូមឱ្យបាត្រព្រះអង្គមកឋិតនៅក្នុងដៃនៃយើង ដោយឆាប់” ។ ខណៈនោះបាត្រក៏ធ្លាក់ចាកអាកាសមកប្រតិស្ឋាន លើព្រះហស្ថអជិតភិក្ខុដោយហេតុជាអស្ចារ្យ ។ ព្រះមាតុច្ឆា ឃើញហើយមានព្រះរាជហឬទ័យសោមនស្ស ថ្វាយបង្គំចូល ទៅកាន់រាជនិវេសន៍វិញ ។ ព្រះសាស្តាក៏សំដែងបុព្វហេតុ ទាំងពួងនៃអជិតភិក្ខុ ហើយទ្រង់ព្យាករអជិតភិក្ខុថា នឹងបាន ជាអង្គព្រះអរិយមេត្តេយ្យ ។

(បប់មេត្តេយ្យព្យាករណបរិច្ឆេទ ទី២១)

---

## ពុទ្ធបិតុនិព្វានបរិច្ឆេទ ទី២២

(១) តតោ រាជគហំ ឧបនិស្សាយ លំដាប់នោះ ព្រះដ៏មានព្រះភាគ បេញចាកនិគ្រោធារាមទៅកាន់រាជគហនគរ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

គង់នៅក្នុងវេឡុវនវិហារមួយអន្លើដោយភិក្ខុសង្ឃ គង់ចាំវស្សាជាគំរប់៤ ដរាបអស់វស្សា លុះដល់វស្សាជាគំរប់៥ ព្រះអង្គយាងទៅគង់ក្នុងកូដាគារសាលាព្រៃមហាវ័ន ក្នុងនគរវេសាលី ដើម្បីអនុគ្រោះដល់វេនេយ្យជន ។ គ្រានោះ ព្រះបាទសិរីសុទ្ធោទន៍ ទ្រង់ប្រឈួនធ្ងន់ ។ សក្យរាជទាំងពួងមានព្រះនាងបជាបតិគោតមីជាដើម ចាំរក្សាព្រះរោគនោះ ក៏មិនអាចឱ្យរម្ងាប់ទៅបាន ។ ព្រះពុទ្ធបិតាក៏ផ្ទំបម្រះនៀលលើព្រះសយនាទ្រង់រលឹកដល់ព្រះសាស្តា ហើយមានព្រះបរិវិតក្កថា បើព្រះសាស្តាយាងមកស្ទាបព្រះសិរសា, ព្រះអានន្ទមកស្ទាបព្រះសរីរកាយ គឺផ្ទួងជំនីរសងខាង, ព្រះរាហុលមកបរាមាសព្រះបិដ្ឋិកាលឯណា, ទុក្ខវេទនារោគាពាធនៃអាត្មាអញក៏នឹងរម្ងាប់ទៅក្នុងកាលនោះ ។

ក្នុងបច្ចូសសម័យនៃថ្ងៃនោះ ព្រះសាស្តាទ្រង់រមិលរមើលនូវវេនេយ្យសត្វ បានជ្រាបហេតុថាព្រះពុទ្ធបិតាប្រឈួន ទ្រង់ព្រះបរិវិតក្កថា កាលនេះគួរតថាគតទៅប្រោសព្រះបិតាដែលកំពុងនឹកដល់តថាគត, ទើបព្រះអង្គហៅព្រះអានន្ទមកប្រាប់ហេតុគ្រប់ប្រការ ហើយបង្គាប់អានន្ទឱ្យប្រាប់ភិក្ខុទាំងពួង ។ ព្រះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

អានន្ទទូលព្រះពុទ្ធដីកា ។ កាលបើភិក្ខុសង្ឃមកដល់, ព្រះអង្គប្រាប់ហេតុស្រេចហើយ ទ្រង់នាំភិក្ខុសង្ឃ ៥០០អង្គ ទៅកាន់នគរកបិលភ័ស្តុ តាមអាកាស ដល់ហើយទ្រង់យាងចូលទៅកាន់ ព្រះរាជមន្ទីរ ទតឃើញព្រះវរបិតាមានព្រះកាយទុព្វលភាព ក៏ត្រាស់សួរព្រះរោគ ។ ព្រះពុទ្ធបិតាកាលទ្រង់ព្រះសណ្តាប់ព្រះពុទ្ធដីកា ក៏ស្រក់ព្រះជលនេត្រទូលថា ទុក្ខវេទនាខ្ញុំមានកំលាំងណាស់ស្ទើរនឹងដាច់ជីវិត ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់ហើយ ក៏លើកព្រះហស្តខាងស្តាំធ្វើសត្យាធិដ្ឋានថា "តថាគតខំបំពេញអភិនីហារសាងសមត្តិសបារមី អស់មួយអសង្ខេយ្យនឹងមួយសែនកប្បនេះ ដើម្បីប្រយោជន៍ដល់សត្វលោក "ទើបព្រះអង្គទ្រង់បរាមាសព្រះសិរព្រះវរបិតាដោយព្រះហស្តខាងស្តាំ ។ ទុក្ខវេទនាព្រះសិរក៏វិនាសបង់ទៅ ។ លំដាប់នោះ ព្រះអានន្ទថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយ ធ្វើសត្យាធិដ្ឋាន លើកព្រះហស្តខាងស្តាំស្ទាបព្រះហស្តព្រះរាជាខាងស្តាំ ។ ទុក្ខវេទនាក៏វិនាសទៅ ។ លំដាប់នោះ ព្រះអានន្ទតាំងសត្យាធិដ្ឋានហើយ លើកព្រះហស្តបរាមាសព្រះហស្តព្រះរាជាខាងឆ្វេងទៀត។ ព្រះរោគក៏វិនាសទៅ ។ ព្រះរាហុល

Websites: WatKhemaraRatanaram.org or WatKhmers.org

ធ្វើសត្យាធិដ្ឋានហើយ ស្នាមព្រះបិដ្ឋិព្រះរាជអយ្យកោដោយព្រះហស្តខាងស្តាំ ។ ទុក្ខវេទនាក៏វិនាសទៅទៀត ។

(២) តទា រាជា វិគតរោគោ ក្នុងកាលនោះព្រះពុទ្ធបិតាមានព្រះរោគាពាធប្រាសទៅហើយ ស្តេចក្រោកចាកសិរីសយ-នា មានព្រះបីតិសោមនស្សលើកព្រះករធ្វើអញ្ជលីចំពោះព្រះ-សាស្តា ។ សម្តេចព្រះភគវាទ្រង់ពិចារណាអាយុសង្ខារនៃពុទ្ធ-បិតា ក៏ជ្រាបថា នៅតែ៧ថ្ងៃទៀតនឹងសុគត ។ ព្រះរាជាក៏អារាធនាឱ្យព្រះអង្គសំដែងធម៌ ។ ព្រះសាស្តាទ្រង់សំដែងអនិច្ច-តាទិបដិសំយុត្តគឺព្រះត្រៃលក្ខណ៍, លុះចប់កាលណាព្រះពុទ្ធបិតាបានសម្រេចអរហត្តផល ។ ដល់ថ្ងៃជាគំរប់ ៧ ព្រះពុទ្ធបិតាក្រាបទូលព្រះសាស្តាថា អាយុសង្ខារខ្ញុំនេះតិចណាស់ ខ្ញុំសូមថ្វាយបង្គំលាព្រះសាស្តាចូលនិព្វាន សូមទ្រង់អនុញ្ញាត ។ បំណែកខត្តិយវង្សបានទ្រង់ព្រះសណ្តាប់ហើយ បរិទេវនាការទ្រហ៊ឹយំ ។ ព្រះពុទ្ធបិតាសូមស្មាលាទោសនឹងព្រះសាស្តាស្រេចហើយក៏បរិនិព្វានក្នុងកាលនោះ ។ ព្រះមុនិន្ទពិនលោកនាថទ្រង់សំដែងធម៌បន្ទោរបង់សោកនៃពួកសក្យរាជ ហើយមានព្រះពុទ្ធ-ដីកាបង្គាប់ព្រះមហាកស្សបត្ថេរ ឱ្យមើលទីបូជាព្រះភ្លើង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org
ព្រះមហាកស្សបត្ថេរក៏ទទួលតាមព្រះពុទ្ធដីកា ។ ក្នុងកាលនោះ ពពួកទេវតាក្នុងហ្មឺនលោកធាតុ មកប្រជុំព្រមគ្នា ។ កាលព្រះមហាកស្សបត្ថេរ បង្គាប់ឱ្យតាក់តែងជើងថ្កស្រេចហើយ ក៏ទៅក្រាបទូលព្រះបរមគ្រូ ។ ព្រះសាស្ដាទ្រង់លើកព្រះសិរសាព្រះពុទ្ធបិតាដោយព្រះហស្ត ទ្រង់ស្រោចដោយសុគន្ធ-វារីស្រេចហើយ លើកព្រះបរមសពដាក់ក្នុងមឈូសរតន៍, ទើបព្រះសាស្ដាលើកមឈូសដោយព្រះអង្គឯង នាំទៅកាន់ទីបូជា, ព្រះអង្គទ្រង់ឃាត់សក្កទេវរាជមិនឱ្យថ្វាយព្រះភ្លើងមុន, ទ្រង់ថ្វាយព្រះភ្លើងដោយព្រះអង្គឯង ។ ឯព្រះញាតិព្រះសាស្ដាទាំង ៦ នគរគឺ នគរ កបិលវត្ថុ១, ទេវទហៈ១, កោលិយៈ១, សក្ករៈ១ សុប្បវាសា១, វេរនគរ១ ក៏សោកសៅបរិទេវនាការ ក្នុងគ្រាដែលព្រះពុទ្ធបិតាទ្រង់ចូលនិព្វាន ទើបបបួលគ្នាមកប្រជុំព្រមក្នុងកបិលវត្ថុនគរទាំងអស់ ដើម្បីថ្វាយភត្តាហារដល់ព្រះសាស្ដានិងភិក្ខុសង្ឃ ។ ព្រះសព្វញ្ញូទ្រង់ទទួលយញ្ញទានស្រេចហើយ ទ្រង់ធ្វើអនុមោទនាសំដែងធម៌ប្រោសព្រះញាតិ ហើយយាងទៅគង់ក្នុងនិគ្រោធារាម ។ គ្រានោះព្រះនាងបជាបតិគោតមីទៅសូមបព្វជ្ជា ។ ព្រះអង្គមិនអនុញ្ញាត ទើបព្រះអង្គយាង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅគង់ក្នុងកូដាគារ សាលា ។ លំដាប់នោះ ព្រះនាងបជាបតិគោតមីទៅសូមបព្វជ្ជាទៀត បានឱ្យព្រះអានន្ទជួយអង្វរ ។ ព្រះអង្គក៏នៅតែមិនអនុញ្ញាត ។ គ្រានោះព្រះសាស្តាយាងទៅគង់ក្នុងនគរសាវត្ថី ។ ព្រះនាងបជាបតិគោតមីក៏នាំខត្តិយកញ្ញា៥០០ អង្គជាបរិវារតាមទៅសូមបព្វជ្ជា ព្រះពុទ្ធជាម្ចាស់ទ្រង់ករុណាក៏ប្រទានបព្វជ្ជាឧបសម្បទាដោយគរុធម៌៨ប្រការ ។

(បប់ពុទ្ធបិតានិព្វានបរិច្ឆេទ ទី២២)

---

## បរិនិព្វានបរិច្ឆេទ ទី២៣

## (ពុទ្ធាធិវាសនដ្ឋាន)

(១)សម្តេចព្រះភគវន្តអនន្តញ្ញាណ តាំងពីទ្រង់បានត្រាស់ជាព្រះពុទ្ធស្រេច ទ្រង់ត្រេចប្រកាសព្រះពុទ្ធសាសនា ដឹកនាំវេនេយ្យជនជាច្រើនតម្បន់ ឱ្យចូលកាន់ព្រះពុទ្ធសាសនាតាមវិហារនេះ ។ ទីឋានដែលព្រះអង្គធ្លាប់គង់ប្រកាសធម្មវិន័យនោះមាន១៨កន្លែងគឺ:

វស្សាទី១ ព្រះអង្គទ្រង់គង់ចាំវស្សានៅទីព្រៃឥសិបតនមិគទាយវ័នជិតក្រុងពារាណសី១, វស្សាទី២ ទី៣ ទី៤ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងវត្តវេឡុវនារាមជិតក្រុងរាជគ្រឹះ១, វស្សា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទី៥ ព្រះអង្គទ្រង់គង់ចាំវស្សា ក្នុងកូដាគារសាលាព្រៃមហាវ័ន ជិតក្រុងវេសាលី១, វស្សាទី៦ ព្រះអង្គគង់ចាំវស្សាលើ មកុលបព៌ត ក្នុងដែនមគធៈ១, វស្សាទី៧ ព្រះអង្គទ្រង់ឡើងទៅ គង់ចាំវស្សាក្នុងឋានតាវត្តិង្ស លើថ្មបណ្ឌុកម្ពលសិលាអាសន៍ ត្រាស់ប្រទានព្រះសត្តប្បករណាភិធម្ម៧គម្ពីរ ប្រោសពុទ្ធមាតា១, វស្សាទី៨ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងភេសកលាវ័នក្នុងតគ្គរាជ ជនបទ១ , វស្សាទី៩ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងព្រៃបាលិ-លេយ្យកៈ១, វស្សាទី១០ ទី១១ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងជង ព្រៃជិតស្រុកព្រាហ្មណ៍ឈ្មោះសាលេយ្យកគ្រាម១, វស្សាទី១២ ព្រះអង្គទ្រង់គង់ចាំវស្សានៅក្រោមដើមស្ដៅ ដែលនឡេរុ-យក្សរក្សា១, វស្សាទី១៣ ព្រះអង្គទ្រង់គង់ចាំវស្សានៅភ្នំបាលិ-លេយ្យកបព៌ត១, វស្សាទី១៤ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង ជេតវ័នវិហារ ជិតក្រុងសាវត្ថី១, វស្សាទី១៥ ព្រះអង្គទ្រង់គង់ ចាំវស្សាក្នុងវត្តនិគ្រោធារាម ជិតក្រុងកបិលភ័ស្ដុ ដើម្បីប្រោស ពួកព្រះញាតិ១, វស្សាទី ១៦ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង ស្រុកអាឡវី ដើម្បីប្រោសអាឡវកយក្ស១, វស្សាទី១៧ ទី១៨ ទី១៩ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងវេឡុវនារាម ជិតក្រុងរាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រិះ១, វស្សាទី២០ ដល់ទី២៩ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង ជេតវនមហាវិហារ ជិតក្រុងសាវត្ថី១, វស្សាទី៣០ ដល់ទី៣៥ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងវត្តបុព្វារាម១, វស្សាទី៣៦ ដល់ ទី៤៤ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងជេតវនមហាវិហារ ជិតក្រុង សាវត្ថី១, វស្សាទី៤៥ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងស្រុកវេឡុវ គ្រាម១ ។ រួមទីកន្លែងដែលព្រះអង្គធ្លាប់គង់ ត្រូវជា១៨កន្លែង រួមវស្សាទាំងអស់មានចំនួន៤៥វស្សា ។

(២) ក្នុងរវាង៤៥វស្សានេះ ព្រះអង្គទ្រង់បំពេញពុទ្ធ-កិច្ចទាំង៥ប្រការ ជាកិច្ចដែលព្រះពុទ្ធទាំងពួងតែងធ្វើក្នុងការ ប្រកាសសាសនា គឺ បុព្វណ្ហេ បិណ្ឌបាតញ្ច ក្នុងវេលាព្រឹក ទ្រង់ត្រាច់ទៅដើម្បីបិណ្ឌបាត១, សាយណ្ហេ ធម្មទេសនំ ក្នុង វេលារសៀលទ្រង់សំដែងធម្មទេសនា ដល់សាធារណជន១, បទោសេ ភិក្ខុឱវាទំ ក្នុងវេលាព្រលប់ទ្រង់ប្រទានឱវាទបំពោះ តែពួកភិក្ខុ១, អឌ្ឍរត្តេ ទេវបញ្ហនំ ក្នុងវេលាកណ្ដាលអធ្រាត្រ ទ្រង់ដោះស្រាយប្រស្នាតែពួកទេវតា១, បច្ចូសេ វ គតេ កាលេ ភព្វាភព្វេ វិលោកនំ ដល់វេលាបែកបច្ចូស ទ្រង់ ប្រមើលមើលនូវសត្វដែលមានភព្វនឹងឥតភព្វ១ ។ បើទ្រង់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org
ឃើញសត្វណាមានភ័ព្វ ហើយជាពុទ្ធវេនេយ្យ, នោះព្រះអង្គទ្រង់និមន្តទៅប្រោសដោយព្រះអង្គឯង, បើសត្វណាជាសាវក-វេនេយ្យ មាននិស្ស័យត្រូវសាវកអង្គណាប្រោសបាន, នោះព្រះដ៏ទ្រង់ញាណ ទ្រង់បាត់សាវកអង្គនោះឱ្យទៅប្រោស ។

(៣) ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ប្រព្រឹត្តទៅធ្វើពុទ្ធកិច្ចទាំង៥ប្រការនេះអស់៤៥វស្សា ។ ដល់បេញវស្សាទី៤៥ ព្រះអង្គទ្រង់និមន្តបេញ អំពីស្រុកវេឡុវ ត្រាប់ទៅកាន់ចារិកតាមលំដាប់ ដល់ថ្ងៃពេញបូណ៌មីខែមាឃ(១) ឆ្នាំម្សាញ់បញ្ចស័ក, ព្រះអង្គគង់នៅបាវាលចេតិយ ព្រះជិនស្រីទ្រង់ដាក់អាយុសង្ខារដោយព្រះពុទ្ធដីកាចំពោះមារថា “ម្នាលមារមានចិត្តបាប, ចូរអ្នកមានសេចក្ដីខ្វល់ខ្វាយតិចចុះ, ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេ កន្លងបីខែអំពីថ្ងៃនេះទៅតថាគតនឹងបរិនិព្វានហើយ” លុះព្រះដ៏មានព្រះភាគទ្រង់ដាក់អាយុសង្ខារដូច្នេះហើយក៏កក្រើកផែនដីយ៉ាងធំ គួរឱ្យភ្លូកភ្លឹកព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ ពួកសាវកទាំងឡាយមានព្រះអានន្ទជាដើម

(១) ថ្ងៃនេះដែលពួកពុទ្ធសាសនិកជនធ្វើបុណ្យមាឃបូជា ជាទីរឭកដល់ការដាក់អាយុសង្ខាររបស់ព្រះដ៏មានព្រះភាគ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ក៏កើតសង្វេគសោយសោក ជាទុក្ខក្ដុកក្ដួលគ្រប់ៗ អាត្មា ។ តមកសម្ដេចព្រះភគវា ទ្រង់ចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី, ត្រឡប់ពីបិណ្ឌបាត ទ្រង់ក្រឡេកទតក្រុងវេសាលីមានព្រះពុទ្ធដីកានឹងព្រះអានន្ទថា "តថាគតឃើញក្រុងវេសាលីម្ដងនេះជាទីបំផុតហើយ" ហើយទ្រង់ធ្វើពុទ្ធដំណើរ ទៅដល់ភណ្ឌគ្រាម ទ្រង់ត្រាច់ទៅកាន់ចារិកតាមលំដាប់ ដរាបដល់នគរកុសិនារា ទ្រង់ចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រដែលជាទីចូលទៅក្នុងក្រុងកុសិនារា ទ្រង់ត្រាស់នឹងព្រះអានន្ទថា "ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែឱ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះសាលព្រឹក្សទាំងគូរឱ្យតថាគតផង" ។ ព្រះអានន្ទក៏ទទួលធ្វើតាមព្រះពុទ្ធដីកា ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះសតិសម្បជញ្ញៈ ទ្រង់សម្រេចសីហសេយ្យាផ្ទៀងទៅខាងស្ដាំ យកព្រះបាទឆ្វេងមកដម្រួតលើព្រះបាទស្ដាំ ។

(៤) ក្នុងគ្រាដែលព្រះបរមសម្ពុទ្ធ ទ្រង់ផ្ទំលើអនុដ្ឋានសយនាជាទីចូលបរិនិព្វាននេះ ព្រះមហាអានន្ទបានក្រាបបង្គំទូលសួរនូវវត្តប្រតិបត្តិផ្សេងៗ ជាច្រើន ដែលត្រូវប្រព្រឹត្តធ្វើក្នុងកាលជាខាងក្រោយមកទៀត, ព្រះអានន្ទបានស្ដាប់ព្រះពុទ្ធតម្រាស់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រាស់ប្រាប់គ្រប់ប្រការ ហើយចូលទៅកាន់វិហារ ឈរតោងត្រដោកទ្វារយំរៀបរាប់ជាអនេកប្រការ ។ សម្តេចព្រះបរមសាស្តា ទ្រង់ឱ្យភិក្ខុទៅហៅព្រះអានន្ទមក ទ្រង់មានព្រះពុទ្ធដីកាសរសើរគុណសម្បត្តិរបស់ព្រះអានន្ទ ដោយប្រការជាច្រើន ហើយទ្រង់ឱ្យព្រះអានន្ទ ទៅថ្វាយដំណឹងដល់ពួកមល្លក្សត្រ ។ ពួកមល្លក្សត្រនឹងព្រះរាជបុត្រព្រះរាជសុណិសា ព្រមទាំងព្រះជាយារបស់មល្លក្សត្រ បានជ្រាបហើយ ក៏កើតទុក្ខតូចព្រះទ័យពោរពេញដោយសេចក្តីអាល័យ នាំគ្នាចូលទៅក្នុងសាលវ័នដើម្បីឱ្យទាន់ព្រះសាស្តា ទាំងពពួកទេវតា ក៏ចូលមកណែនណាន់តាន់តាប់ ។ ដល់បច្ឆិមយាមរាត្រី សម្តេចព្រះជិនស្រីទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា “ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ” ដូច្នេះហើយ ទ្រង់ចូលកាន់បឋមជ្ឈាន, ចេញចាកបឋមជ្ឈានចូលកាន់ ទុតិយជ្ឈាន, តតិយជ្ឈាន, ចតុត្ថជ្ឈាន, អាកាសានញ្ចាយតន សមាបត្តិ, នេវសញ្ញានាសញ្ញាយតនសមាបត្តិ, សញ្ញាវេទយិតនិរោធ, ទ្រង់ចេញចាកសញ្ញាវេទយិតនិរោធ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្ធី

Websites: WatKhemaraRatanaram.org or WatKhmers.org

ថយមកកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ជាបដិលោមប្រាសរហូតដល់បឋមជ្ឈាន ទើបចូលជាអនុលោមបណ្ដោយដល់ត្រឹមចតុត្ថជ្ឈាន, ចេញអំពីចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វានក្នុងចន្លោះនោះ ។

(៥) ពុទ្ធបរិស័ទទាំងឡាយ មានពួកមល្លក្សត្រអ្នកក្រុងកុសិនារាជាប្រធាន បានចាត់ការដើម្បីបូជាព្រះសរីរៈព្រះដ៏មានព្រះភាគ, មនុស្សព្រមទាំងទេវតា ធ្វើសក្ការបូជាដោយរបាំចម្រៀងភ្លេងប្រគំផ្កាកម្រងនឹងគ្រឿងក្រអូបអស់វេលា៦ថ្ងៃ, ដល់ថ្ងៃជាគំរប់៧ក៏រំកិលព្រះបរមសរីរៈ ដើម្បីហែរចេញទៅទិសខាងត្បូង ហើយនឹងបូជាខាងត្បូងព្រះរាជវាំង ក៏រំកិលព្រះសរីរៈពុំកម្រើកសោះ ។ មល្លក្សត្រ៨ព្រះអង្គដែលជាប្រធាន បានទូលសួរព្រះអនុរុទ្ធ ថ្វាយព្រះពរថា "ព្រោះតែខុសទាស់នឹងបំណងទេវតា" ទើបព្រមព្រៀងគ្នារំកិលព្រះបរមសរីរៈ ហែចេញទៅទិសខាងជើង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើងកាត់ ពាក់កណ្ដាលក្រុងចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងព្រះបរមសរីរៈ ព្រះដ៏មានព្រះភាគ ក្នុងមកុដពន្ធន(១)

---

(១) មកុដពន្ធនចេតិយនេះ គឺសាលាជាមង្គលសម្រាប់តែងព្រះអង្គរបស់ពួកមល្លរាជ បានជាហៅមកុដពន្ធនៈ, ហៅថាចេតិយព្រោះគេធ្វើវិចិត្ររចនាក្បូរក្បាច់វិសេសណាស់ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេតិយរបស់ពួកមល្លក្សត្រឰដ៏ខាងកើតទីក្រុង ។

(៦) កាលដែលពួកមល្លក្សត្រថ្វាយព្រះភ្លើង, ព្រះមហាកស្សប កំពុងនិមន្តមកពីដែនបាវា ពុំទាន់ដល់មកនៅឡើយ ។ ភ្លើងក៏ពុំឆេះ ។ លុះព្រះមហាកស្សបនិមន្តមកដល់ ព្រះបាទាទាំងគូនៃព្រះទសពលក៏លៀនចេញពីមឈូសមាស ។ ព្រះមហាកស្សបនឹងភិក្ខុទាំង៥០០ជាបរិវារ ថ្វាយបង្គំព្រះបាទារួចស្រេច ជើងថ្ករក៏ឆេះឯង ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ក៏សុះអស់គ្មានកំញម ដូចជាប្រេងដែលភ្លើងឆេះ នៅសល់តែព្រះអដ្ឋិធាតុសុទ្ធ ។ ពួកមល្លក្សត្រអ្នកក្រុងកុសិនារា ដែលមានពួកអ្នកកាន់លំពែង ពួកទាហានដំរី ទាហានសេះ ទាហានរថ នឹងពួកយោធាគ្រប់ដំណែងហោមរោមជាបរិវារ បានរើសព្រះអដ្ឋិធាតុព្រះឈ្មោះមារ ទៅធ្វើសក្ការបូជាដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រង នឹងគ្រឿងក្រអូបទាំងឡាយអស់៧ថ្ងៃទៀតក្នុងសណ្ឋាគារ ។

(៧) គ្រានោះព្រះបាទមាគធអជាសត្តុវេទេហីបុត្តព្រះចៅក្រុងរាជគ្រឹះ, ពួកក្សត្រលិច្ឆវីអ្នកក្រុងវេសាលី, ពួកក្សត្រសក្យៈអ្នកក្រុងកបិលវត្ថុ, ពួកក្សត្រថូលិអ្នកក្រុងអល្លកប្ប, ពួក

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្សត្រកោឡិយៈ អ្នកក្រុងរាមគ្រាម, ព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីបៈ នឹងពួកក្សត្រអ្នកក្រុងបាវាបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយក្នុងក្រុងកុសិនារា ក៏បញ្ជូនទូតមក ដើម្បីសុំចែកព្រះសារីរិកធាតុ ។ ពួកមល្លក្សត្រពុំព្រមចែកឱ្យ ក៏ជជែកគ្នាស្ទើរតែនឹងកើតសង្គ្រាមមួយក្នុងរឿងនេះ ។ ទើបទោនព្រាហ្មណ៍និយាយឡើងថា "គួរតែស្រុះស្រួលព្រមព្រៀងនិយាយរកគ្នា " ហើយក៏ចែកព្រះសារីរិកធាតុឱ្យជា ៨ចំណែកស្មើគ្នា, ឯទោណអាចារ្យដែលជាមេចំណែក បានត្រឹមតែតុម្ពមួយ គឺជារង្វាល់ដែលវាល់ព្រះធាតុនោះប៉ុណ្ណោះ ។

ឯពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័នក៏បញ្ជូនទូតទៅដើម្បីសុំចែកព្រះសារីរិកធាតុដែរ ។ ពួកមល្លក្សត្រថា ព្រះសារីរិកធាតុយើងចែកគ្នាអស់ហើយ, ចូរអ្នកទាំងឡាយនាំយកព្រះអង្គារ(ធ្យូង)អំពីកន្លែងដែលថ្វាយព្រះភ្លើងនេះទៅចុះ ។ ពួកក្សត្រមោរិយៈទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែងដែលថ្វាយព្រះភ្លើងនោះទៅ ។

(៨) គ្រានោះព្រះបាទមាគធអជាសត្តុវេទេហីបុត្ត ក៏ធ្វើព្រះស្តូប ធ្វើការបូជាព្រះសារីរិកធាតុព្រះដ៏មានព្រះភាគ ក្នុងក្រុងរាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រឹះ ។ ពួកក្សត្រលិច្ឆវីអ្នកក្រុងវេសាលី ធ្វើអ្នកក្រុង វេសាលី ។ ពួកក្សត្រសក្យៈអ្នកក្រុងកបិលវត្ថុ ធ្វើក្នុងក្រុងកបិលវត្ថុ ។ ពួកក្សត្រថូលិអ្នកក្រុងអល្លកប្បៈ ធ្វើក្នុងក្រុងអល្លកប្បៈ ។ ពួកក្សត្រកោឡិយៈអ្នករាមគ្រាម ធ្វើក្នុងរាមគ្រា ។ ព្រាហ្មណ៍អ្នកវេដ្ឋទីបៈ ធ្វើក្នុងដែនវេដ្ឋទីៈ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ធ្វើក្នុងក្រុងបាវា ។ ពួកមល្លក្សត្រអ្នកក្រុងកុសិនារា ធ្វើក្នុងក្រុងកុសិនារា ។ ទោណព្រាហ្មណ៍ ក៏ធ្វើក្នុងក្រុងកុសិនារាដែរ ។ ពួកក្សត្រមោរិយៈអ្នកក្រុងបិប្ផលិវ័ន ធ្វើក្នុងក្រុងបិប្ផលិវ័ន ។ រួមព្រះស្តូបដំកល់ព្រះសារីរិកធាតុទាំងអស់មាន៨, ជាគំរប់៩នឹងស្តូបដែលដំកល់ព្រះតុម្ពៈ, ជាគំរប់១០ នឹងព្រះស្តូបដែលដំកល់ព្រះអង្គារ ។

(ចប់បរិនិព្វានបរិច្ឆេទ ទី២៣)

*ចប់ពុទ្ធប្បវត្តិកថា ជាប្រវត្តិទី១ នៃពុទ្ធសាសនា*

---

មានរឿងសង្គីតិប្បវត្តិជាប្រវត្តិទី២ នឹងពុទ្ធឃោសប្បវត្តិ

ជាប្រវត្តិទី៣ តទៅទៀត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយ ភិក្ខុ ប៊ិន សុផល
ជួយកែសម្រួលទម្រង់ និង ផ្ទៀងអក្ខរាវិរុទ្ធ ដោយ លោក ជ្រុន ចន្នី